សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# មូលដ្ឋានគ្រឹះនៃការវិនិយោគលើ មូលបត្រកម្មសិទ្ធិ

ស្រាវជ្រាវពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ពៅ ផនមន្លា**
**សែម សក្ដា**

សាស្ត្រាចារ្យណែនាំ
លោក **ឈាង ហ៊ុយ**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ
ជំនាន់ទី ១១

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ពៅ ផនមន្ថា** និង **សែម សក្កា** ជានិស្សិតថ្នាក់បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ ឆ្នាំទី៤ ជំនាន់ទី១១ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៤-២០១៨ សូមសម្តែងនូវការដឹងគុណនិងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរគឺ លោកឪពុក និង អ្នកម្តាយដែលបានផ្តល់កំណើត ព្រមទាំងបានយកចិត្តទុកដាក់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅតម្រង់ទិស ប្រកបដោយសេចក្តីស្រលាញ់ពេញចិត្ត និង ព្រហ្មវិហារធម៌។ លោកទាំងពីរបានធ្វើការតស៊ូគ្រប់យ៉ាង ដើម្បីទំនុកបម្រុងយើងខ្ញុំក្នុងការសិក្សាទាំងផ្នែកស្មារតី និង សម្ភារៈរហូតដល់ពួកយើងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រី សាស្ត្រាចារ្យ និង បុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចគ្រប់រូប ដែលបានខិតខំយកចិត្តទុកដាក់បង្ហាត់បង្រៀនអប់រំ និងផ្ទេរ ចំនេះដឹងផ្សេងៗមកអោយយើងខ្ញុំដើម្បីយកមកប្រើប្រាស់នាពេលអនាគត។
- ជាពិសេស យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូសាស្ត្រាចារ្យ **ឈាង ហ៊ុយ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការស្រាវជ្រាវនិងការសរសេរសារណាបញ្ចប់ការសិក្សានេះ។ លោកសាស្ត្រាចារ្យបានខិតខំបង្ហាត់បង្ហាញ ផ្តល់យោគបល់ល្អៗ និងបានយកពេលវេលា ដ៏មានតម្លៃ ដើម្បីណែនាំក្រុមយើងខ្ញុំ អោយខិតខំប្រឹងប្រែងបំពេញកិច្ចការមួយនេះអោយបញ្ចប់ទៅដោយភាពរលូន។
- រៀមច្បង ដែលបានបន្សល់ទុកនូវ ស្នាដៃល្អៗ សម្រាប់ធ្វើជាឯកសារក្នុងការស្រាវជ្រាវបន្ថែម។ មិត្តរួមថ្នាក់ទាំងអស់ដែលបានតែងតែជួយលើកទឹកចិត្ត និងផ្តល់នូវគំនិតល្អៗ ដល់ពួកយើងខ្ញុំ។
- ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួង និងជូនពរដល់អ្នកមានគុណទាំងអស់អោយជួបប្រទះតែសុភមង្គលនិងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

វិស័យមូលបត្រ គឺជាវិស័យមួយដែលថ្មីសម្រាប់ប្រជាជនកម្ពុជា។ វាបានដើរតួយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេស ដោយ វាបានអនុញ្ញាតអោយ ក្រុមហ៊ុន សាជីវកម្ម សហគ្រាស សាធារណៈអាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម។ ម្យ៉ាងទៀតប្រជាជនដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពហុវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំជាមួយមូលបត្រដែលមានហានិភ័យទាបក្នុងវិស័យមូលបត្រ។ ទោះបីជា វិស័យមូលបត្រកំពុងតែសន្សឹមៗរីកចំរើនទៅមុខក៏ដោយ ក៏ប៉ុន្តែចំណេះដឹងផ្នែកវិនិយោគលើវិស័យមូលបត្ររបស់ប្រជាជនកម្ពុជានៅមានកម្រិតនៅឡើយ។

ដូចនេះ ហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវ និងរៀបចំសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រស្តីពី **“មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ”** នេះឡើង។ ប្រធានបទមួយនេះចង់ផ្តោតសំខាន់ ទៅលើកត្តាសំខាន់ៗមួយចំនួនដែលវិនិយោគិនមួយចំនួនត្រូវដឹងមុនសម្រេចចិត្តទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនណាមួយ។ លើសពីនេះទៀតនៅក្នុងប្រធានបទនេះបានបង្ហាញអោយវិនិយោគិនដឹងពីអត្ថប្រយោជន៍នៃការវិនិយោគមូលបត្រ និងទិដ្ឋភាពវិស័យមូលបត្រនៅកម្ពុជា ព្រមទាំងអនុសាសន៍មួយចំនួនដែលជាគំនិតផ្ទាល់ខ្លួនរបស់ពួកខ្ញុំ។

ក្រុមយើងខ្ញុំ សង្ឃឹមថាប្រធានបទមួយនេះនឹងអាចក្លាយជាជំនួយសម្រាប់ការណែនាំ និងផ្តល់ចំណេះដឹងអំពីការវិនិយោគមូលបត្រ ទៅដល់វិនិយោគិន សាធារណជន និងសិស្សនិស្សិតដែលមានបំណងចង់ស្វែងយល់ពីការវិនិយោគលើមូលបត្រកម្មសិទ្ធិនេះ។ ក្រុមយើងខ្ញុំពិតជាសង្ឃឹមថា សារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំមួយនេះ អាចរួមចំណែកតូចមួយក្នុងការអភិវឌ្ឍ វិស័យសេដ្ឋកិច្ច តាមរយៈការចែករំលែកចំណេះដឹងដល់ប្អូនៗសិស្សនិស្សិតជំនាន់ក្រោយដែលបានចាប់អារម្មណ៍ក្នុងការវិនិយោគក្នុងវិស័យមូលបត្រនេះ។

ជាការពិតណាស់ ទោះបីជា កិច្ចការនេះត្រូវបានធ្វើដោយការផ្ចិតផ្ចង់យ៉ាងណាក៏ដោយ កំហុសអក្ខរាវិរុទ្ធ ភាពខ្វះចន្លោះនានាតែងតែកើតមានដោយអចេតនាជាមិនខាន។ ហេតុដូចនេះក្រុមយើងខ្ញុំសូមសេចក្តីសណ្តោសប្រណី និងអធ្យាស្រ័យជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ គណៈកម្មាការ ការពារសារណា ព្រមទាំងមិត្តអ្នកអាន ទាំងឡាយ ចំពោះកំហុសអចេតនាទាំងឡាយ ដោយក្តីអនុគ្រោះ។ ក្រុមយើងខ្ញុំ នឹងទទួលយកនូវ រាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយដោយក្តីសោមនស្សរីករាយ។

# មាតិកា


បញ្ជីរូប ..... v

បញ្ជីឧបសម្ព័ន្ធ ..... vii


## សេចក្ដីផ្ដើម


១. លំនាំបញ្ហា ..... ១

២. ចំណោទបញ្ហា ..... ២

៣. គោលបំណងនៃការស្រាវជ្រាវ ..... ២

៤. ទំហំ និង ដែនកំណត់ ..... ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ៣

៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤


## ជំពូកទី ១
## រំលឹកទ្រឹស្ដី


១.១. ការវិនិយោគ ..... ៥

  ១.១.១. ដូចម្ដេចដែលហៅថាការវិនិយោគ? ..... ៥

  ១.១.២ .ប្រភេទនៃការវិនិយោគ ..... ៥

  ១.១.៣. ប្រភេទនៃវិនិយោគិន ..... ៦

១.២. ប្រវត្តិទីផ្សារមូលបត្រ ..... ៦

១.៣. តើទីផ្សារមូលបត្រជាអ្វី ..... ៧

  ១.៣.១. ទីផ្សារដំបូង ..... ៧

  ១.៣.២. ទីផ្សារបន្ទាប់ ..... ៨

១.៤. អ្វីទៅជាមូលបត្រ ..... ៩

  ១.៤.១. មូលបត្ររដ្ឋ ..... ៩

  ១.៤.២. មូលបត្រមហាជន ..... ៩

១.៥. អ្វីទៅជាមូលបត្រមូលបត្រកម្មសិទ្ធិ ..... ១០

  ១.៥.១. ភាគហ៊ុនធម្មតា ..... ១១

  ១.៥.២. ភាគហ៊ុនបុរិមា ..... ១១

១.៦. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ........ ១១
១.៦.១. ចំពោះសេដ្ឋកិច្ច ........ ១១
១.៦.២. ចំពោះវិនិយោគិន ........ ១២

## ជំពូកទី ២

## ទីផ្សារមូលបត្រនៅកម្ពុជា

២.១. ប្រវត្តិសង្ខេបនៃផ្សារមូលបត្រកម្ពុជា ........ ១៤
២.២.រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ១៥
២.២.១. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ........ ១៥
២.២.២. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រ ........ ១៦
២.៣ ចក្ខុវិស័យ និងបេសកម្ម ........ ១៧
២.៤. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ ........ ១៨
២.៤.១. ការបើកគណនី និង នីតិវិធីក្នុងការជួញដូរ ........ ១៨
២.៤.២. ថ្លៃ និង ម៉ោងជួញដូរ ........ ២០
២.៤.៣. ប្រភេទបញ្ជា ........ ២១
២.៤.៤. វិធីសាស្ត្រជួញដូរ ........ ២៣
២.៤.៤.១. វិធីសាស្ត្រដេញថ្លៃ ........ ២៣
២.៤.៤.២. វិធីសាស្ត្រជួញដូរតាមការចរចា ........ ២៤
២.៤.៥.ដែនកំណត់ថ្លៃ ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ ........ ២៤
២.៥. សមាជិក និង អ្នកចូលរួមនៅក្នុងផ្សារមូលបត្រកម្ពុជា ........ ២៥

## ជំពូកទី ៣

## មូលដ្ឋាននៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ

៣.១. ការវិភាគមូលដ្ឋាន ........ ២៧
៣.១.១. ការវិភាគស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ........ ២៧
៣.១.១.១. គោលគំនិត ........ ២៧
៣.១.១.២. នយោបាយ ........ ២៧
៣.១.១.៣. អថេរម៉ាក្រូសេដ្ឋកិច្ច(Macro Economy Variable) ........ ២៨
៣.១.១.៤. ព្រឹត្តិការណ៍មិនបានព្រៀងទុក ........ ២៨

៣.១.២. ការវិភាគលើវិស័យនៃភាគហ៊ុនជួញដូរ ........ ២៩
៣.១.២.១ កម្លាំងជំរុញអោយមានការប្រកួតប្រជែង (Porter's Five Force of Competitive Position) ........ ២៩
៣.១.២.២. ខ្សែកោងនៃកំណើនអាជីវកម្ម (Industry Growth Curve) ........ ៣១
៣.១.៣. ការវិភាគលើក្រុមហ៊ុន ........ ៣២
៣.១.៣.១. ការវិភាគគុណភាព(Qualitative Analysis) ........ ៣២
៣.១.៣.២. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ........ ៣២
៣.១.៤ ការវិភាគលើអនុបាតភាគហ៊ុន ........ ៣៩
៣.១.៤.១. អនុបាតនៃថ្លៃភាគហ៊ុន/ចំណូល ........ ៣៩
៣.១.៤.២. អនុបាតនៃថ្លៃ/ ចំណូល/ កំណើន ........ ៤០
៣.១.៤.៣. អនុបាតនៃថ្លៃភាគហ៊ុន និង ការលក់ ........ ៤១
៣.១.៤.៤. ទិន្នផលភាគលាភ (Dividend Yield) ........ ៤២
៣.១.៤.៥. តម្លៃគណនេយ្យក្នុងមួយឯកតា ........ ៤២
៣.១.៤.៦. ផលនៃមូលធន ........ ៤៣
៣.២. ការវិភាគតាមលក្ខណៈបច្ចេកទេស ........ ៤៤
៣.២.១. គំនូសក្រាហ្វិក ........ ៤៤
៣.២.១.១. ក្រាហ្វិកបន្ទាត់ ........ ៤៤
៣.២.១.២. ក្រាហ្វិករបារ ........ ៤៥
៣.២.១.៣. ក្រាហ្វិកទៀន ........ ៤៥
៣.២.២. ការវិភាគលើគម្រូនៃក្រាហ្វិកភាគហ៊ុន ........ ៤៧
៣.២.២.១. លក្ខណៈក្បាល និង ស្មា ........ ៤៧
៣.២.២.២. លក្ខណៈកំពូលពីរ ........ ៤៨
៣.២.២.៣. លក្ខណៈបាតពីរ ........ ៤៩
៣.២.២.៤. លក្ខណៈកំពូលបី និងបាតបី ........ ៥០
៣.២.២.៥. លក្ខណៈរួមតូច ........ ៥២
៣.២.២.៦. លក្ខណៈ Flag and Pennant ........ ៥៤
៣.២.៣. សូចនករទីផ្សារ ........ ៥៥

៣.២.៣.១. មធ្យមរំកិល (Moving Average) ..................................................... ៥៥
៣.២.៣.២. សូចនករ Moving Average Convergence-Divergence.................. ៥៩
៣.២.៣.៣. សូចនករ On Balance Volume (OBV) .......................................... ៦៥
៣.២.៣.៤. សូចនករ Relative Strength Index (RSI)....................................... ៦៧
៣.២.៣.៥. សូចនករ Bollinger Bands ............................................................ ៦៨
៣.៣. ស្វែងយល់ហានិភ័យនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ ............................................ ៧០
៣.៣.១. ហានិភ័យជាប្រព័ន្ធ.......................................................................... ៧០
៣.៣.២. ហានិភ័យមិនជាប្រព័ន្ធ .................................................................... ៧០

**សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន ..........................................................................................................៧៣
២. ការផ្តល់អនុសាសន៍ ......................................................................................................... ៧៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីរូប

រូបភាពទី ១ ៖ ភាពខុសគ្នារវាងការវិនិយោគលើមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល ........... ១០
រូបភាពទី ២ ៖ រចនាសម្ព័ន្ធនៃក្រុមប្រឹក្សាភិបាល .................................................................. ១៦
រូបភាពទី ៣ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា.................................. ១៧
រូបភាពទី ៤ ៖ នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ............................................................. ១៩
រូបភាពទី ៥ ៖ ម៉ោងជួញដូរមូលបត្រកម្មសិទ្ធិ ........................................................................២០
រូបភាពទី ៦ ៖ ការប្រៀបធៀបរវាងបញ្ជាដែនកំណត់ និង បញ្ជាទីផ្សារ ......................................២២
រូបភាពទី ៧ ៖ កត្តាទាំង៥ ដែលជំរុញអោយមានការប្រកួតប្រជែងក្នុងទីផ្សារ............................២៩
រូបភាពទី ៨ ៖ ខ្សែកោងកំណើន.......................................................................................... ៣១
រូបភាពទី ៩ ៖ របាយការណ៍ប្រាក់ចំនេញរបស់ក្រុមហ៊ុនរដ្ឋាករទឹកក្រុងភ្នំពេញនៅត្រីមាសទី ៤ ឆ្នាំ ២០១៧ ........................................................................................................៣៣
រូបភាពទី ១០ ៖ តារាងតុល្យការណ៍របស់ក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅត្រីមាសទី៤ ឆ្នាំ ២០១៧ ....................................................................................................... ៣៥
រូបភាពទី ១១ ៖ របាយការណ៍លំហូរសាច់ប្រាក់ក្រុមហ៊ុន រដ្ឋាករទឹកក្រុងភ្នំពេញ ......................៣៧
រូបភាពទី ១២ ៖ក្រាហ្វិកបន្ទាត់នៃភាគហ៊ុនរបស់ក្រុមហ៊ុន Apple,Inc. ....................................... ៤៤
រូបភាពទី ១៣ ៖ គម្រូក្រាហ្វិករបារ ..................................................................................... ៤៥
រូបភាពទី ១៤ ៖ ក្រាហ្វិករបារនៃភាគហ៊ុនរបស់ក្រុមហ៊ុន Google............................................. ៤៥
រូបភាពទី ១៥ ៖ គម្រូក្រាហ្វិកទៀន ..................................................................................... ៤៦
រូបភាពទី ១៦ ៖ ក្រាហ្វិកទៀនរបស់ភាគហ៊ុនក្រុមហ៊ុន IBM ................................................... ៤៦
រូបភាពទី ១៧ ៖ គម្រូក្បាល និង ស្មា នៃភាគហ៊ុនរបស់ក្រុមហ៊ុន CNET Networks, Inc............ ៤៧
រូបភាពទី ១៨៖ លក្ខណៈកំពូលពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន Gillette Co. ................................ ៤៨
រូបភាពទី ១៩ ៖ លក្ខណៈកំពូលពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន Ford ......................................... ៤៩
រូបភាពទី ២០ ៖ លក្ខណៈបាតពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន United Technologies Corp. .......... ៥០
រូបភាពទី ២១ ៖ លក្ខណៈកំពូលបីនៃភាគហ៊ុនរបស់ក្រុមហ៊ុន Champion Enterprise Inc............ ៥១
រូបភាពទី ២២ ៖ លក្ខណៈបាតបីនៃភាគហ៊ុនរបស់ក្រុមហ៊ុន Anadarko Petroleum Corp. ........... ៥១
រូបភាពទី ២៣ ៖ លំនាំរូមតូចក្នុងទិសដៅកើនឡើងនៃភាគហ៊ុនរបស់ក្រុមហ៊ុន Dell.................... ៥២
រូបភាពទី ២៤ ៖ លំនាំរូមតូច(ទិសដៅធ្លាក់ចុះ)នៃភាគហ៊ុនរបស់ក្រុមហ៊ុន Rowan Companies .. ៥៣

រូបភាពទី ២៥ ៖ លក្ខណៈ Flag នៃភាគហ៊ុនរបស់ក្រុមហ៊ុន  Hewlett-Packard.......................... ៥៤
រូបភាពទី ២៦ ៖ លក្ខណៈ Pennant នៃភាគហ៊ុនរបស់ក្រុមហ៊ុន Dell........................................ ៥៥
រូបភាពទី ២៧ ៖ ក្រាហ្វិក SMA និង EMA នៃភាគហ៊ុនរបស់ក្រុមហ៊ុន Intel Corp. ..................... ៥៦
រូបភាពទី ២៨ ៖ ក្រាហ្វិក 50-day SMA និង 50-day EMA នៃភាគហ៊ុនរបស់ក្រុមហ៊ុន IBM........ ៥៧
រូបភាពទី ២៩៖ Golden Cross និង Death Cross នៃភាគហ៊ុនរបស់ក្រុមហ៊ុន Home Depot, Inc. ៥៨
រូបភាពទី ៣០ ៖ Support និង Resistance របស់ 200-day SMA (ភាគហ៊ុនក្រុមហ៊ុន NYSE)...... ៥៩
រូបភាពទី ៣១ ៖ ខ្សែ MACD និង Signal Line របស់ក្រុមហ៊ុន PowerShares QQQ Trust........... ៦០
រូបភាពទី ៣២ ៖ លក្ខណៈវិជ្ជមាន និង អវិជ្ជមាននៃ MACD របស់ក្រុមហ៊ុន Home Depot ........... ៦១
រូបភាពទី ៣៣ ៖ ករណី Signal Line Crossovers របស់ក្រុមហ៊ុន IBM...................................... ៦២
រូបភាពទី ៣៤ ៖ ករណី Centerline Crossovers របស់ក្រុមហ៊ុន Cummins .............................. ៦៣
រូបភាពទី ៣៥ ៖ Bullish Divergence នៃភាគហ៊ុនរបស់ក្រុមហ៊ុន Google, Inc........................... ៦៤
រូបភាពទី ៣៦ ៖ Bearish Divergence នៃភាគហ៊ុនរបស់ក្រុមហ៊ុន Gamestop Corp.................. ៦៥
រូបភាពទី ៣៧ ៖ On Balance Volume នៃភាគហ៊ុនរបស់ក្រុមហ៊ុន Wal-Mart Stores ................. ៦៦
រូបភាពទី ៣៨ ៖ ករណី Overbought និង Oversold នៃភាគហ៊ុនរបស់ក្រុមហ៊ុន McDonalds ...... ៦៨
រូបភាពទី ៣៩ ៖ Upper Bands និង Lower Bands របស់ភាគហ៊ុនក្រុមហ៊ុន Apple.................... ៦៩

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ ៖ ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
ឧបសម្ព័ន្ធទី ២ ៖ អនុក្រឹត្យថ្មីស្តីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
ឧបសម្ព័ន្ធទី ៣ ៖ ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
ឧបសម្ព័ន្ធទី ៤ ៖ ប្រកាសស្តីពីការដាក់ឲ្យអនុវត្តវិធានសមាជិកភាព
ឧបសម្ព័ន្ធទី ៥ ៖ ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រា

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

វិស័យហិរញ្ញវត្ថុ ដែលមានរួមមានវិស័យធនាគារ វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ គឺជាសរសៃឈាមសេដ្ឋកិច្ច ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវភាពរស់រានរបស់សេដ្ឋកិច្ចក្នុងប្រទេសមួយ តាមរយៈការផ្តល់ជាយន្តការមួយសម្រាប់ប្រមូលប្រភពហិរញ្ញវត្ថុ រួមទាំងទ្រង់ទ្រាយធំ និងមធ្យម ព្រមទាំងរយៈពេលខ្លី មធ្យម និងវែង ដើម្បីធ្វើហិរញ្ញប្បទាន គម្រោងវិនិយោគនានា និង ធ្វើអោយមានភាពសម្បូរបែបនៃប្រភពធនធានដែលមានក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចមាន សន្ទុះកាន់តែខ្លាំង។

ដោយមើលឃើញពីភាពចាំបាច់នៃតួនាទីវិស័យហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យនេះ ដោយបានដាក់ចេញនូវ "**ចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០០១-២០១០**" ហើយបានធ្វើបច្ចុប្បន្នភាពទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥**" ហើយទើបនឹងត្រូវបានបន្តបច្ចុប្បន្នភាពទៅជា "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១០-២០២០**"។ "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២**" របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យនេះផងដែរ។ តាមរយៈផែនការយុទ្ធសាស្ត្រទាំងនេះគម្រោងនៃការបង្កើតទីផ្សារមូលបត្រត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១២ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុអោយបានរឹងមាំ ។ នាពេលបច្ចុប្បន្ននេះ មានក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិចំនួន ៥ រួមមានកំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) កំពង់ផែស្វយ័តភ្នំពេញ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

ដូចបានរៀបរាប់វិស័យមូលបត្រកំពុងតែអភិវឌ្ឍខ្លួនទៅមុខជាបន្តបន្ទាប់ ក៏ប៉ុន្តែការចូលរួមពីសំណាក់ប្រជាពលរដ្ឋកម្ពុជានៅមានកម្រិតនៅឡើយ។ កត្តាមួយក្នុងបណ្តាកត្តាទាំងឡាយ គឺមកពី កង្វះការយល់ដឹងឲ្យទូលំទូលាយ ពីការវិនិយោគលើវិស័យនេះ។ ដើម្បីដោះស្រាយចំណោទបញ្ហានេះ គណៈកម្មការមូលបត្រ និង ផ្សារមូលបត្រកម្ពុជា បានស្វះស្វែងបង្កើតជាវគ្គបណ្តុះបណ្តាល ពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា និង ការផ្សព្វផ្សាយនានាជាសាធារណៈពីវិស័យនេះ។

ហេតុដូចបានរៀបរាប់នេះ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសសិក្សាពី ប្រធានបទ

"**មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ**" ដើម្បីចូលរួមដោះស្រាយបញ្ហាកង្វះខាតចំណេះដឹងក្នុងវិស័យដ៏មានសារៈសំខាន់មួយនេះ។

## ២. ចំណោទបញ្ហា

ដូចបានបកស្រាយខាងលើ ផ្សារមូលបត្រកម្ពុជាកំពុងបន្តការរីកចម្រើនទៅមុខជាលំដាប់ ដោយឡែកការយល់ដឹង ទៅលើការវិនិយោគលើវិស័យមួយនេះនៅមានកម្រិតនៅឡើយ។

ប្រធានបទនេះនឹងធ្វើការផ្តោតសំខាន់ទៅលើថា តើអ្វីជាការវិនិយោគលើមូលបត្រកម្មសិទ្ធិ? តើអ្វីខ្លះដែលវិនិយោគិនគួរស្វែងយល់អំពីមូលដ្ឋានគ្រឹះនៃការវិនិយោគ? តើមានកត្តាអ្វីខ្លះដែលមានឥទ្ធិពលទៅលើបម្រែបម្រួលតម្លៃនៃមូលបត្រកម្មសិទ្ធិ? ហើយថាតើអ្វីខ្លះដែលអាចជាហានិភ័យនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងជារួមនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីចូលរួមជាចំណែកក្នុងការលើកតម្កើន និង ពង្រឹងចំណេះដឹងទាក់ទងទៅនឹង មូលបត្រកម្មសិទ្ធិ ព្រមការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុនេះ ជូនទៅប្រជាពលរដ្ឋកម្ពុជាដែលមានគោលគំនិតចង់ធ្វើការជួញដូរមូលបត្រនេះ។

ក្រៅពីគោលបំណងរួមខាងលើ ប្រធានបទនេះក៏មានគោលបំណងជាក់លាក់ដូចជា៖

- ស្វែងយល់ពីប្រភេទផ្សេងៗនៃការវិនិយោគ
- ស្វែងយល់ពីទីផ្សារមូលបត្រ
- ស្វែងយល់ពីនិយមន័យ និង ប្រភេទនៃមូលបត្រ
- ស្វែងយល់ពីប្រវត្តិសង្ខេបនៃផ្សារមូលបត្រកម្ពុជា ចក្ខុវិស័យ បេសកម្ម និង រចនាសម្ព័ន្ធចាត់តាំង
- ស្វែងយល់ពីរបៀបនៃការជួញដូរមូលបត្រកម្មសិទ្ធិ
- ស្វែងយល់ពីការវិភាគតាមលក្ខណៈមូលដ្ឋាន
- ស្វែងយល់ពីការវិភាគតាមលក្ខណៈបច្ចេកទេស
- ស្វែងយល់ពីកត្តាដែលអាចមានឥទ្ធិពលដល់បម្រែបម្រួលតម្លៃភាគហ៊ុន និងប្រភេទនៃហានិភ័យផ្សេងៗក្នុងការវិនិយោគលើភាគហ៊ុន

## ៤. ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ

ក្នុងគោលដៅធ្វើឲ្យការសិក្សាស្រាវជ្រាវមួយនេះ អាចសម្រេចទៅបាន ប្រកបខ្លឹមសារពេញលេញ និង ច្បាស់លាស់ ប្រធានបទនេះ នឹងផ្តោតលើតែ "មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ" និងផ្អែកលើទិន្នន័យដែលប្រមូលបានត្រឹមឆ្នាំ ២០១៨។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះអាចប្រព្រឹត្តទៅបាន ដោយជោគជ័យ ក្រុមយើងខ្ញុំបានអនុវត្តវិធីសាស្ត្រប្រមូលទិន្នន័យ ពីរ យ៉ាងគឺ

- ទិន្នន័យចម្បង (Primary Data)៖ ប្រភពទិន្នន័យចម្បងគឺការសាកសួរដោយផ្ទាល់ជាមួយបុគ្គលិករបស់ផ្សារមូលបត្រកម្ពុជាទទួលបន្ទុកបណ្តុះបណ្តាលពីការវិនិយោគលើ មូលបត្រកម្មសិទ្ធិអំពី មូលដ្ឋានគ្រឹះមួយចំនួនដែលវិនិយោគិនប្រើប្រាស់។
- ទិន្នន័យបន្ទាប់បន្សំ (Secondary Data)៖ ទិន្នន័យបន្ទាប់បន្សំដែលប្រមូលមកគឺមានប្រភពចេញពី ច្បាប់ អនុក្រឹត ប្រកាស បទបញ្ញត្តិ ឯកសារក្នុងបណ្ណាល័យ គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា និង ឯកសារនានានៅតាមប្រព័ន្ធអ៊ិនធើណែត រួមមាន Investopedia, The StockCharts ជាដើម។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺ បានពាំនាំនូវសារៈសំខាន់ ជាច្រើន ដូចជា៖

- ចំពោះអ្នកស្រាវជ្រាវផ្ទាល់៖
  - អាចរំលឹកទ្រឹស្តីដែលបានរៀនពីមុនមកឡើងវិញ។
  - ស្គាល់នូវបទប្បញ្ញត្តិរបស់ទីផ្សារមូលបត្រមួយចំនួន ដែលទាក់ទងនឹងប្រធានបទខាងលើ
  - អាចទទួលបាននូវចំណេះដឹងបន្ថែមដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ នឹងបានទទួលបទពិសោធន៍ជាច្រើនក្នុងការងារ។
- ចំពោះផ្សារមូលបត្រកម្ពុជា
  - អាចទទួលបាននូវគំនិតថ្មីៗ និង មើលឃើញ នូវចំនុចខ្វះខាតដើម្បីយកទៅកែតម្រូវពីអនុសាសន៍របស់អ្នកសរសេរសារណា។
- ចំពោះវិនិយោគិន
  - ទទួលបានចំនេះដឹងបន្ថែមក្នុងការវិនិយោគមូលបត្រ អោយទទួលបានការជោគជ័យកាន់តែច្រើន។

- ចំពោះសេដ្ឋកិច្ច និង សង្គមជាតិ

- ធ្វើអោយវិស័យមូលបត្រមានប្រជាប្រិយភាពខ្លាំងជាងមុន ជាហេតុធ្វើអោយសេដ្ឋកិច្ច និង សង្គមជាតិរីកចម្រើនជាងមុនផងដែរ។

- ចំពោះមិត្តនិស្សិតជំនាន់ក្រោយ

- សារណានេះនឹងក្លាយជាឯកសារមួយដែលមានប្រយោជន៍ជាចំណេះដឹងសំរាប់មិត្តនិស្សិត ដែលចង់ដឹងនិង សិក្សាអំពីវិស័យមូលបត្រនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទសិក្សាស្រាវជ្រាវមួយនេះ ត្រូវបានរៀបចំបែងចែកជា ៣ ជំពូក គឺ

សេចក្តីផ្តើម

ជំពូកទី ១ ៖ រំលឹកទ្រឹស្តី

ជំពូកទី ២ ៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ជំពូកទី ៣ ៖ មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ

សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

# ជំពូកទី ១
# រំលឹកទ្រឹស្តី

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. ការវិនិយោគ

### ១.១.១. ដូចម្តេចដែលហៅថាការវិនិយោគ?[1]

វិនិយោគគឺជាការ (ដាក់ទុន) ផ្តល់ប្រភពធនធាន នាពេលបច្ចុប្បន្នដោយសង្ឃឹមថានឹងទទួលបានមកវិញនូវប្រភពធនធានកើនឡើង រឺ ធ្វើអោយដំណើរការរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើងនាពេលអនាគត។

ការវិនិយោគគឺជាការប្រើប្រាស់ ឬ ការចំនាយមូលនិធិដោយរំពឹងថានឹងទទួលបានចំណូល ឬការកើនឡើងជាទុន(Increase in Capital)អំពីវិនិយោគនោះនាពេលអនាគត។

អ្នកវិនិយោគដែលបានវិនិយោគទៅលើភាគហ៊ុន Stock របស់ក្រុមហ៊ុនណាមួយគឺមានការរំពឹងទុកដូចៗគ្នាគឺចង់បានប្រាក់ចំនេញច្រើន(ភាគលាភ) និងការកើនឡើង ឬចំនេញជាមូលធន (Capital Gain) ទៅលើភាគហ៊ុនដែលបានវិនិយោគនោះ នៅពេលដែលគេត្រូវការលក់ភាគហ៊ុនទាំងនោះចេញទៅវិញ។

### ១.១.២. ប្រភេទនៃការវិនិយោគ

ការវិនិយោគត្រូវបានបែងចែកជា២ប្រភេទដូចខាងក្រោមគឺៈ[2]

- **ការវិនិយោគពិត( Real Investment)** : គឺជាការបណ្តាក់ទុនទៅលើអចលនាទ្រព្យ(Real Estate) ដូចជាសង់សណ្ឋាគារ ផ្ទះសំណាក់ សម្រាប់ជួល រឺទិញដីផ្ទះសម្រាប់លក់ចេញទៅវិញដើម្បីប្រាក់ចំនេញ។
- **ការវិនិយោគហិរញ្ញវត្ថុ (Financial Investment)** : គឺជាការបណ្តាក់ទុនវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុ (Financial Instrument) ដែលមានដូចជា ភាគហ៊ុន សញ្ញាបណ្ណ័ក្រុមហ៊ុន សញ្ញាបណ្ណ័រដ្ឋាភិបាល ។ល។

---

[1] សាស្ត្រាចារ្យ ឈាង ហ៊ុយ (២០១៥-២០១៦),*មូលដ្ឋានគ្រឹះនៃវិនិយោគ*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,ទំព័រ ១

[2] សាស្ត្រាចារ្យ ឈាង ហ៊ុយ (២០១៥-២០១៦),*មូលដ្ឋានគ្រឹះនៃវិនិយោគ*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,ទំព័រ ៣

### ១.១.៣ ប្រភេទនៃវិនិយោគិន

នៅក្នុងក្របខណ្ឌនៃកិច្ចដំណើរការវិនិយោគមួយ គេបែងចែកប្រភេទអ្នកចូលរួមវិនិយោគជា២ក្រុមធំៗគឺ អ្នកវិនិយោគមានលក្ខណៈជាបុគ្គល (Indiviual Investors) និង អ្នកវិនិយោគមានលក្ខណៈ ជាស្ថាប័ន (Institutional Investors)។

- អ្នកវិនិយោគមានលក្ខណៈជាបុគ្គល (Indiviual Investors) គឺសំដៅទៅលើអ្នកវិនិយោគដែលចាត់ចែង និងគ្រប់គ្រងមូលនិធិផ្ទាល់ខ្លួន។
- អ្នកវិនិយោគមានលក្ខណៈជាស្ថាប័ន (Institutional Investors) គឺជាប្រភេទ នៃអ្នកវិនិយោគ

ប្រកបដោយវិជ្ជាជីវៈដែលគ្រប់គ្រង និងចាត់ចែងមូលនិធិសម្រាប់ស្ថាប័នមួយ។

## ១.២ ប្រវត្តិទីផ្សារមូលបត្រ[3]

ទីផ្សារមូលបត្រមានប្រវត្តិតាំងពីយូរយារណាស់មកហើយ។ វាបានកើតចេញពីសកម្មភាពនៃការដោះដូរជាលើកដំបូងលើផលិតផលកសិកម្ម និងផលិតផលផ្សេងៗទៀត។ ពាណិជ្ជករនៅទីផ្សារអឺរ៉ុប នៅក្នុងមជ្ឈឹមសម័យមានការងាយស្រួលក្នុងការប្រើប្រាស់ឥណទានដែលទាមទារអោយមាននូវឯកសារពង្រាងដោយមានឯកសារគាំទ្រ ដូចជា ប័ណ្ណ លិខិតផ្លាស់ប្តូរ។ ផ្សារភាគហ៊ុនបារាំងត្រូវរកឃើញកាលពីសតវត្សទី១២ នៅពេលដែលការធ្វើជំនួញបានកើតឡើងជារូបភាពជាលិខិតផ្លាស់ប្តូរពាណិជ្ជកម្ម។ ដើម្បីគ្រប់គ្រងនូវទីផ្សារដែលទើបតែចាប់ផ្តើម លោកហ្វីលីបឌឺហ្វែរ (Phillip The fair 1268 – 1314)បានបង្កើតនូវជំនាញមួយនៃការផ្លាស់ប្តូរដូចជាអ្នកនាំមុខគេនៃឈ្មួញកណ្តាលហ៊ុនបារាំងទើប ឬជាភ្នាក់ងារផ្លាស់ប្តូរ។ ប្រហែលជាពេលនោះដែរ ពាណិជ្ជករបានចាប់ផ្តើម ប្រមូលផ្តុំគ្នានៅមុខផ្ទះនៃគ្រួសារ Van der Buerse ដើម្បីទំនាក់ទំនងក្នុងការធ្វើជំនួញដោយគេហៅថា Bourse ដែលមានន័យថាផ្សារភាគហ៊ុន (Stock Exchange)។ ការចាប់ផ្តើមស្ថាប័ននៃផ្សារហ៊ុនក៏បានកើតឡើងក្នុងអំឡុងសតវត្សទី១៦ និង១៧នៅក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ធំផ្សេងទៀតនៅទូទាំងពិភពលោក ដូចជា អាំស្ទ័រដាំ ចក្រភពអង់គ្លេស ដាណឺម៉ាក អាឡឺម៉ង់។

ផ្សារមូលបត្រនៅក្នុងសហរដ្ឋអាមេរិក បានចាប់ផ្តើមជាមួយនឹងការធ្វើជំនួញដែលមានការឡើងចុះឆាប់រហ័សក្នុងការចេញបោះផ្សាយថ្មីៗរបស់រដ្ឋាភិបាល។ នៅក្នុង១៧៩១ ផ្សារភាគហ៊ុនដំបូងរបស់អាមេរិកត្រូវបានបង្កើតឡើងនៅ រដ្ឋហ្វីឡាដេផ្យា។ ផ្សារភាគហ៊ុននៅក្នុងទីក្រុងញ៉ូវយ៉កត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៧៩២ នៅពេលដែលពាណិជ្ជករ និងឈ្មួញកណ្តាលចំនួន ២៤នាក់បានសម្រេចចិត្តយកកម្រៃជើងសារនៅពេលដើរតួនាទីជាភ្នាក់ងារសម្រាប់មនុស្សផ្សេងទៀត

[3] ហាស់ វាសនា (២០០៧), *ផ្សារភាគហ៊ុនគឺជាអ្វី?*, ទំព័រទី៥-៩

ហើយដើម្បីផ្តល់ការពេញចិត្តទៅអោយគ្នាទៅវិញទៅមក។ ដោយបានធ្វើជំនួញរបស់ពួកគេនៅក្រោមដើមឈើមួយនៅផ្លូវ វ៉លស្ទ្រីតលេខ ៦៨។ ក្នុងឆ្នាំ១៨១៧ អ្នកគួកជេរនៅទីក្រុងញ៉ូយ៉កបានសម្រេចចិត្តចាត់ចែងជាផ្លូវការនូវក្រុមប្រឹក្សាផ្សារភាគហ៊ុន។ ឆ្នាំ១៨៦៣ ផ្សារភាគហ៊ុនញូយ៉កបានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ ខ្លួន។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ផ្សារភាគហ៊ុនមួយចំនួនត្រូវបានគេរៀបចំឡើងហើយផ្សារហ៊ុនមួយចំនួនក្នុងចំណោមនោះ ដែលចាត់ទុកជាអ្នកនាំមុខគេគឺផ្សារភាគហ៊ុន អា-មេរិក (American Stock Exchange) ហើយក៏ជាផ្សារហ៊ុនដ៏ធំបំផុតទីពីរនៃសហរដ្ឋអាមេរិក។

## **១.៣. តើទីផ្សារមូលបត្រជាអ្វី**?

ទីផ្សារមូលបត្រគឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និង ឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន " សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ"។ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូល បត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។[4]

### **១.៣.១. ទីផ្សារដំបូង** ( Primary Market )

ទីផ្សារដំបូង (Primary Market) គឺជាទីផ្សារដែលធ្វើការជួញដូរមូលបត្រដែលទើបនឹងបោះផ្សាយលក់ ឬគេអាចហៅថាជាទីផ្សារបោះផ្សាយមូលបត្រ។ ប្រភពមូលធនសំខាន់របស់ទីផ្សារនេះគឺជាប្រភពប្រាក់សន្សំរបស់សាធារណៈជន ក៏ដូចជាអង្គការមិនមែនស្ថាប័នហិរញ្ញវត្ថុមួយចំនួនទៀតដែរ។ ទីផ្សារដំបូងអនុវត្តនូវមុខងារសំខាន់បំផុតរបស់ទីផ្សារមូលធននោះ គឺជាមុខងារសេដ្ឋ-កិច្ចមានន័យថាយកមូលធនពីអ្នកមានមូលធនលើសទៅផ្តល់អោយអ្នកដែលខ្វះមូលធនឬ គៀងគរមូលធនដែលទំនេរយកទៅវិនិយោគ។

ទីផ្សារដំបូង គឺជាកន្លែងបោះផ្សាយ ពីព្រោះកន្លែងនេះជាកន្លែងទិញ លក់បណ្តាមូលបត្រដែលទើបបោះផ្សាយលើកដំបូង រវាងអ្នកបោះផ្សាយ (អ្នកលក់) និងអ្នកវិនិយោគ(អ្នកទិញ)។

តួនាទីចំបងរបស់ទីផ្សារដំបូង គឺបង្កើតទំនិញអោយទីផ្សារជួញដូរ និងធ្វើអោយកើនមូលធនវិនិយោគដល់វិស័យសេដ្ឋកិច្ច។ តួនាទីនោះគឺ ៖[5]

- ទី១ គឺជាដំណើរការនៃមូលបត្រ ដើម្បីប្រមូលនូវមូលធនពេលត្រូវការ។

---

[4] អ៊ឹង អ៊ូ (២០១២),*គុណសម្បត្តិ និងគុណវិបត្តិរបស់ទីផ្សារមូលបត្រដល់សេដ្ឋកិច្ច*,ភ្នំពេញ

[5] ជីង លីជូ និងកុសល សម្បត្តិ (២០១១),*ឧបករណ៍ហិរញ្ញវត្ថុដែលត្រូវប្រើប្រាស់ក្នុងទីផ្សារមូលបត្រកម្ពុជា*,សកសវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ ២២

- ទី២ គឺជាដំណើរការហិរញ្ញវត្ថុដោយផ្ទាល់ ដែលផ្ទេរប្រាក់ទៅជាទំរង់មូលធនរយៈពេលមធ្យម និងរយៈពេលវែង។

ប្រតិបត្តិការនៃដំណើរការលក់មូលបត្រក្នុងទីផ្សារដំបូងចែកចេញជាពីរប្រភេទគឺ៖

- ការដាក់លក់ជាសាធារណៈ (Public Offering) : ការដាក់លក់មូលបត្រគឺធ្វើឡើងសាធារណៈ ដែលតម្រូវអោយមានការចុះបញ្ជីនៅគណៈកម្មការមូលបត្រ ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានមួយចំនួនដូចជារបាយការណ៍ហិរញ្ញវត្ថុ ប្រវត្តិក្រុមហ៊ុន និងថ្លៃមូលបត្រជាដើម។

- ការដាក់លក់ជាលក្ខណៈឯកជន(Private Offering) : ការដាក់លក់ធ្វើឡើងតាមរយៈការចរចារជាមួយ អតិថិជនពិសេសដោយមិនតម្រូវអោយមានការចុះបញ្ជីនៅគណៈកម្មការមូលបត្រ និងមិនចាំបាច់ធ្វើការផ្សព្វផ្សាយព័តមានជាសាធារណៈនោះទេ។

**១.៣.២. ទីផ្សារបន្ទាប់** ( Secondary Market )

ទីផ្សារបន្ទាប់ គឺជាទីផ្សារដែលធ្វើការជួញដូរមូលបត្រទាំងឡាយ ដែលធ្លាប់បានធ្វើការជួញដូរម្តងរួចហើយនៅក្នុងទីផ្សារដំបូង។ ទីផ្សារនេះជាចំណែកមួយដ៏សំខាន់នៃទីផ្សារមូលបត្រ ដោយភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងទីផ្សារដំបូង។

ទីផ្សារបន្ទាប់អនុវត្តនូវបណ្តាមុខងារដូចជា៖

- បង្កើតលក្ខណៈងាយស្រួលដើម្បីលក់ឧបករណ៍ហិរញ្ញវត្ថុ ក្នុងគោលបំនងប្រមូលនូវសាច់ប្រាក់ និងបង្កើតនូវឧបករណ៍ហិរញ្ញវត្ថុ។ មានន័យថា បង្កើតនូវលក្ខណៈងាយស្រួលក្នុងការផ្ទេរសាច់ប្រាក់ទៅជាឧបករណ៍ហិរញ្ញវត្ថុ និងផ្ទេរពីឧបករណ៍ហិរញ្ញវត្ថុទៅជាសាច់ប្រាក់ (សន្ទនីយភាពសាច់ប្រាក់)។
- រកផលចំនេញពីការកាន់កាប់នូវមូលបត្រ(ទទួលបានភាគលាភ ឬការប្រាក់)។
- កំណត់តម្លៃមូលបត្រអោយបានសមស្រប នៅលើមូលដ្ឋានដេញថ្លៃដោយសេរី (ការប្រកួតប្រជែងដោយសេរី)។

នៅលើទីផ្សារបន្ទាប់គេអាចប្រតិបត្តិការតាមពីរវិធីគឺ៖

- Organized Exchange or Market : ប្រតិបត្តិការតាមមូលដ្ឋានជួញដូរ គឺជាមជ្ឈដ្ឋានជួញដូរមានទីតាំងត្រឹមត្រូវ មានវិធាន និងបទបញ្ញត្តិសម្រាប់គ្រប់គ្រងត្រឹមត្រូវ។
- OTC (Over The Counter Market) : គឺតាមរយៈការទិញ លក់មូលបត្រដែលធ្វើការជួញដូរ

មូលបត្រនៅកន្លែងផ្សេងគ្នា និងក្នុងតម្លៃព្រមព្រៀងគ្នា។ ទីផ្សារនេះមិនមានវិធាន និងបទបញ្ញត្តិគ្រប់គ្រងដូច Organized Exchange ទេ។

## ១.៤. អ្វីទៅជាមូលបត្រ?

មូលបត្រគឺជាលិខិតស្នាមដែលចេញដោយក្រុមហ៊ុន ហើយ ដែលជាគំរូប័ណ្ណមួយលក់ជាសាធារណៈលើការដោះដូរ នៅលើទីផ្សារមូលបត្រ រឺបានទទួលបានស្គាល់ក្នុងវិស័យណាមួយដែលក្នុងវិស័យនោះមូលបត្រត្រូវបានបោះផ្សាយ រឺត្រូវបានលក់ជាវូបិយវត្ថុសម្រាប់ធ្វើការវិនិយោគ។[6]

មូលបត្រត្រូវបានគេបែងចែកជា២ប្រភេទធំៗគឺ ៖

### ១.៤.១. មូលបត្ររដ្ឋ

មូលបត្ររដ្ឋគឺជាបណ្ណ រឺ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលពីការបោះផ្សាយក្នុងនាមរដ្ឋាភិបាល។[7] ក្នុងន័យនេះមូលបត្ររដ្ឋសំដៅតែនៅលើមូលបត្របំណុលតែប៉ុណ្ណោះ។ រដ្ឋបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុដើម្បីគៀងគរមូលធន យកមកប្រើប្រាស់ទៅលើវិស័យណាមួយក្នុងសង្គមដែល នៅមានការខ្វះខាតចរិការ ដូចជាសាងសង់ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យជាដើម។

### ១.៤.២. មូលបត្រមហាជន

មូលបត្រមហាជន សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត រឺ នីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលត្រូវបានអនុញ្ញាតអោយបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងប្រទេសកម្ពុជា[8]។ មូលបត្រមហាជនមានដូចជា៖

- **មូលបត្រកម្មសិទ្ធ** គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិពីសាធារណៈជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួល នូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។

---

[6] មាត្រា ១៦១ លេខ ៩ ចំនុច ខ នៃ *ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម*។

[7] ញាន វណ្ណៈ, *ហិរញ្ញប្បទានរបស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយៈទីផ្សារមូលបត្រ*,(ភ្នំពេញ,២០០៧) ទំព័រ ៦៩។

[8] ច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន, (២០០៧), *ឧបសម្ពន្ធ័ច្បាប់ស្តីពីការបោះផ្សាយនិងជួញដូរមូលបត្រមហាជន សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ*

- **មូលបត្របំណុល** គឺជាប្រភេទមូលបត្របំណុល ដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុលមានកាតព្វកិច្ចបង់ឱ្យវិនិយោគិននូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើមនៅពេលដែលសញ្ញាបណ្ណនោះដល់កាលកំណត់សង ដែលហៅថា "តលាប្រទិទាន"។ ជំនួសឱ្យការខ្ចីប្រាក់ពីធនាគារ ក្រុមហ៊ុនឬអង្គភាពមួយអាចបោះផ្សាយសញ្ញាបណ្ណទៅឲ្យវិនិយោគិនដោយផ្ទាល់ នៅពេលដែលក្រុមហ៊ុននោះត្រូវការសាច់ប្រាក់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីៗ,បន្តប្រតិបត្តិការក្រុមហ៊ុនរឺដើម្បីទូទាត់បំណុល។

រូបភាពទី ១ ៖ ភាពខុសគ្នារវាងការវិនិយោគលើមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល

| សញ្ញាបណ្ណ | ភាគហ៊ុន |
|---|---|
| • ក្លាយជាម្ចាស់បំណុល | • ក្លាយជាម្ចាស់កម្មសិទ្ធិ |
| • សិទ្ធិទាមទារទ្រព្យសម្បត្តិខ្ពស់ជាង | • សិទ្ធិទាមទារទ្រព្យសម្បត្តិទាបជាង |
| • ការវិនិយោគមានរយៈពេលកំណត់ (maturity) | • ការវិនិយោគគ្មានកាលកំណត់ លើកលែងក្រុមហ៊ុនត្រូវបិទទ្វាជម្រះបញ្ជី |
| • ចំណូលការប្រាក់ថេរនិងទៀងទាត់ បង់ដោយអ្នកបោះផ្សាយ | • ការទូទាត់ភាគលាភផ្អែកលើគោលនយោបាយនិងទិន្នផលអាជីវកម្មរបស់ក្រុមហ៊ុន |
| • ថ្លៃមានបម្រែបម្រួលតិចតួច | • ថ្លៃមានបម្រែបម្រួលខ្ពស់ជាង |
| • មិនសូវមានសន្ទនីយភាព | • មានសន្ទនីយភាពខ្ពស់ជាង |
| • ឯកតាបញ្ហាអប្បបរមាគឺ ១ឯកតានៃសញ្ញាបណ្ណ (មានតម្លៃចារឹកស្មើនឹង១០០.០០០រៀល) | • ឯកតាបញ្ហាអប្បបរមាគឺ ១ភាគហ៊ុន |

ប្រភព ៖ គេហទំព័រ ផ.ម.ក(២០១៨), (www.csx.com.kh)

## ១.៥. អ្វីទៅជាមូលបត្រកម្មសិទ្ធិ?

មូលបត្រកម្មសិទ្ធិ គឺផលិតផលទ្រព្យកម្មសិទ្ធិ ជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិពីសាធារណៈជន។ វារួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិននៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួល នូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបាន តាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួល និងតាមរយៈថ្លៃភាគហ៊ុន

ដែលបានដាក់ថ្លៃនៅលើទីផ្សារ។ មានមូលបត្រ២ប្រភេទដែលអាចដាក់ជួញដូរនៅលើផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)៖

### ១.៥.១. ភាគហ៊ុនធម្មតា

ភាគហ៊ុនធម្មតាគឺជាភាគហ៊ុនដែលមានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈ ភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។

### ១.៥.២. ភាគហ៊ុនបុរិមា

ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ភាពខុសគ្នារវាងភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតាគឺ អ្នកកាន់កាប់ភាគហ៊ុនបុរិមានឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា។

## ១.៦. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

### ១.៦.១. ចំពោះសេដ្ឋកិច្ច[9]

ទីផ្សារមូលបត្រ (Securities Market) គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ ដែលគេ តែនិយាយថាទីផ្សារមូលបត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់ រាល់បម្រែបម្រួលនៃ បរិបទជាតិ និង អន្តរជាតិ (សេដ្ឋកិច្ច-សង្គម និងនយោបាយ) វានឹងធ្វើអោយមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។

ខាងក្រោមនេះគឺជាអត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ៖

- ទីផ្សារមូលបត្រជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រគឺជាមធ្យោបាយមួយប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ពូនផ្តុំជាមូលធនធំមួយ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។

[9] គេហទំព័រគណៈកម្មាមូលបត្រកម្ពុជា(២០១៨),*សំនួរ-ចម្លើយ*

- ទីផ្សារមូលបត្រគឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម។
- ទីផ្សារមូលបត្រគឺជាឧបករណ៍មួយដើម្បីទាក់ទាញនិងស្រូបយកនូវមូលធនពីបរទេស។
- ទីផ្សារមូលបត្រជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធិភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួញជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចរាចរឬចលនារស់រវើក។
- ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។ល។

**១.៦.២. ចំពោះវិនិយោគិន**[10]

ទីផ្សារមូលបត្រកម្ពុជា គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ក្រុមហ៊ុនបោះផ្សាយ និង វិនិយោគិននានាដូចខាងក្រោមៈ

**(ក) ឱកាសវិនិយោគ និងប្រាក់ចំណេញ**

ជំនួសឱ្យ ឬ បន្ថែមលើការបើកអាជីវកម្មដោយខ្លួនឯង ការកាន់កាប់ភាគហ៊ុនផ្តល់ឱ្យវិនិ-យោគិន នូវឱកាសក្នុងការចូលរួមចំណែកក្នុងអាជីវកម្មមួយដែលមិនតម្រូវឱ្យមានជំនាញនិងបទពិសោធន៍ពាក់ព័ន្ធ ឬការតាមដានត្រួតពិនិត្យជាប់ជាប្រចាំឡើយ។ ទន្ទឹមនឹងនេះ ប្រាក់ចំណេញពីការជួញដូរ និងភាគលាភទទួលបានពីការកាន់កាប់ភាគហ៊ុនអាចមានចំនួនច្រើនលើសផលវិនិយោគដទៃទៀត។

**(ខ)លទ្ធភាពក្នុងការវិនិយោគ**

ដោយវិនិយោគិនតូចៗផ្សារភាគហ៊ុនអនុញ្ញាតឱ្យវិនិយោគិនដែលមានប្រាក់តិចតួច អាចក្លាយជាម្ចាស់(មួយផ្នែក)នៃ ក្រុមហ៊ុនធំៗ និងទទួលបានផលចំណេញដូចវិនិយោគិនជាអ្នកមាននិងជាស្ថាប័នផងដែរ ទៅតាមសមមាត្រភាគហ៊ុនដែលពួកគេកាន់កាប់។

**(គ) ការលើកទឹកចិត្តផ្នែកពន្ធ**

- ចំពោះអ្នកវិនិយោគមូលបត្រដែលទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាមរយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូង ឬ បន្ទាប់ ត្រូវបានទទួលការលើកលែងចំពោះពន្ធប្រថាប់ត្រា។[11]
- មិនមានពន្ធលើចំណេញមូលធន (capital gain)
- មិនមានពន្ធលើភាគលាភសម្រាប់និវេសនជនកម្ពុជា ចំណែកអនិវេសនជន ពន្ធលើភាគលាភត្រូវបន្ថយមកត្រឹម៧% (ពីអត្រាដើម ១៤%។ អ្នកវិនិយោគសាធារណៈត្រូវបានការកាត់បន្ថយ

[10] គេហទំព័រក្រុមហ៊ុនផ្សារហ៊ុនកម្ពុជា(២០១៨),*សំនួរ-ចម្លើយ*

[11] ប្រការ ៥ (៧) នៃ ប្រកាសលេខ ២៧៣ សហវប្រ.ក *ស្តីពីការប្រមូលពន្ធប្រថាប់ត្រា*

ពន្ធកាត់ទុក ៥០(ហាសិប)ភាគរយ លើការប្រាក់ និង/ឬ ភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធ និងមូលបត្របំណុលសម្រាប់រយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។[12]

**(ឃ) ពិពិធកម្មនៃសំណុំវិនិយោគនិងចំណូលបន្ថែម**

ក្រៅពីប្រភពចំណូលចម្បងដូចជាប្រាក់ខែឬប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀតក្នុងទម្រង់ជាការប្រាក់ដែលបានពីការដាក់ប្រាក់សន្សំមានកាលកំណត់ ចំណូលពីការជួល ឬចំណេញពីអចលនទ្រព្យ លោកអ្នកអាចវិនិយោគក្នុងផ្សារភាគហ៊ុនដើម្បីធ្វើពិពិធកម្មសំណុំវិនិយោគ និងដើម្បីទទួលបានចំណូលបន្ថែម។ បន្ថែមពីលើនេះ ថ្លៃសេវាសម្រាប់ការជួញដូរមូលបត្រមានកម្រិតទាប ដោយស្ថិតក្នុងរង្វង់ ០,៥% នៃតម្លៃជួញដូរតែប៉ុណ្ណោះ

[12] អនុក្រឹត្យស្តីពី *ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ*

# ជំពូកទី ២
# ក្រុមហ៊ុនផ្សារមូលបត្រ
# កម្ពុជា

# ជំពូកទី ២

# ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.១. ប្រវត្តិសង្ខេបនៃផ្សារមូលបត្រកម្ពុជា

ផ្សារមូលបត្រកម្ពុជា បានចុះបញ្ជីស្របច្បាប់នៅក្រសួងពាណិជ្ជកម្ម នាថ្ងៃទី ២៣ ខែ កុម្ភះ ឆ្នាំ ២០១០ ដែលមានឈ្មោះពេញ គឺ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ដែលមានអាសយដ្ឋាន អាគារ ផ.ម.ក វិថី ព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់ វត្តភ្នំ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ផ.ម.ក មាននាយកដ្ឋានសរុបចំនួន៦ និងបុគ្គលិកសរុប៣៦នាក់។[13]

ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រទេសកម្ពុជាដោយឈរលើគោលដៅ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "**ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា**"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "**ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា**" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារ មូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បី បង្កើតផ្សារមូលបត្រ ( "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ) ស្របតាមច្បាប់ស្តីអំពី សហគ្រាស សាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយ ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា

[13] ផ្សារមូលបត្រកម្ពុជា(ផ.ម.ក), *សង្ខេបអំពីក្រុមហ៊ុន*

ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិករ រក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

សង្ខេបខ្លីៗអំពីប្រវត្តិផ្សារមូលបត្រកម្ពុជា៖

- ១៨ មេសា ២០១២ ៖ ពិធីប្រកាសបើកការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ២៨ កុម្ភៈ ២០១១ ៖ ការទទួលបានការអនុញ្ញាតធ្វើជា ប្រតិបត្តិករទីផ្សារ ប្រតិបត្តិករប្រព័ន្ធ ផាត់ទាត់ និង ទូទាត់មូលបត្រ និង ប្រតិបត្តិកររក្សាទុកមូលបត្រ ពី គ.ម.ក
- ២៣ កុម្ភៈ ២០១០ ៖ ចុះបញ្ជីពាណិជ្ជកម្ម
- ២៣ មីនា ២០០៩ ៖ កិច្ចព្រមព្រៀង "ក្រុមហ៊ុនចំរុះ"រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាង ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។
- ២១ មករា ២០០៨ ៖ អនុស្សរណៈយោគយល់អំពីការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា
- ០៦ កញ្ញា ២០០៧ ៖ ការដាក់អោយដំណើរការគម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា
- ២០ វិច្ឆិកា ២០០៦ ៖ អនុស្សរណៈយោគយល់អំពីការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា

## ២.២.រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា[14]

### ២.២.១. រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

[14] ផ្សារមូលបត្រកម្ពុជា (ផ.ម.ក),*រចនាសម្ព័ន្ធគ្រប់គ្រង*

សមាជិកចំនួន ៤ រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូប ត្រូវបាន តែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀត ត្រូវបាន តែងតាំងដោយក្រុមហ៊ុន ផ្សារមូលបត្រកូរ៉េ។

រូបភាពទី ២ ៖ រចនាសម្ព័ន្ធនៃក្រុមប្រឹក្សាភិបាល




ប្រភព ៖ គេហទំព័រ ផ.ម.ក (www.csx.com.kh)

សមាជិកនៃក្រុមប្រឹក្សាភិបាលមានដូចជា៖

- **ឯ.ឧ. បណ្ឌិត ហ៊ាន សាហ៊ីប** ជាប្រធានក្រុមប្រឹក្សាភិបាលអគ្គលេខាធិការរងនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- Mr. Lee Ihn Soo ជាអនុប្រធានក្រុមប្រឹក្សាភិបាលអគ្គនាយករងនៃក្រុមហ៊ុនផ្សារមូល បត្រកម្ពុជា(តំណាងតែងតាំងនៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ)
- **លោក ហុង សុហួរ** ជាសមាជិកអគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- **លោក វ័ត្ន សារុធ** ជាសមាជិកអគ្គនាយករងនៃធនាគារជាតិនៃកម្ពុជា
- **លោក ហ៊ឹម ហ៊ាន** ជាសមាជិក ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃ ក្រសួង ពាណិជ្ជកម្ម
- Mr. KI-JOON YOON ជាសមាជិកអគ្គនាយករងជាន់ខ្ពស់នៃនាយកដ្ឋាន Global Business Management នៃក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ
- Mr. HWI-SHIG CHO សមាជិក

### ២.២.២. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានធ្វើការ និងបែងចែកការទទួលខុសត្រូវទៅតាមផ្នែក តួនាទី និងជំនាញរៀងៗខ្លួនក្នុងការបង្ករភាពងាយស្រួល និង ប្រសិទ្ធិភាពការងារកាន់តែខ្ពស់។ ដោយបានបែងចែកទៅជា០៦ នាយកដ្ឋានទៀតដែលមានដូចជា៖

១. នាយកដ្ឋាន ប្រតិបត្តិការទីផ្សារមូលបត្រ

២. នាយកដ្ឋាន ព័ត៌មានវិទ្យា

៣. នាយកដ្ឋាន ផាត់ទាត់ និងទូទាត់មូលបត្រ

៤. នាយកដ្ឋាន រក្សាទុកមូលបត្រ

៥. នាយកដ្ឋាន ចុះបញ្ជី និងការផ្តល់ព័ត៌មាន

៦. នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

រូបភាពទី ៣ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា




ប្រភព ៖ គេហទំព័រ ផ.ម.ក (២០១៨), (www.csx.com.kh)

## **២.៣. ចក្ខុវិស័យ និងបេសកម្ម**[15]

ចក្ខុវិស័យរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាគឺ "ដើម្បីកសាងនូវ មហាវិថី ហិរញ្ញវត្ថុសម្រាប់កម្ពុជា"។

ចំនែកឯ បេសកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានដូចខាងក្រោម៖

- ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិន ទាំងក្នុងស្រុក និងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផល និង សេវាកម្មដ៏ទំនើបជាច្រើនប្រភេទ សម្រាប់អ្នកចូលរួមទីផ្សារទាំងអស់

[15] ផ្សារមូលបត្រកម្ពុជា (ផ.ម.ក), *ចក្ខុវិស័យ និងបេសកម្ម*

- ដើម្បីដាក់ឲ្យដំណើរការនូវ សហគ្រាសសាធារណៈមួយ ដែលមានស្វ័យចិរភាពក្រោមមគ្គុទេស៍ដឹកនាំរបស់រាជរដ្ឋាភិបាល

## ២.៤. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ[16]

### ២.៤.១. ការបើកគណនី និង នីតិវិធីក្នុងការជួញដូរ

#### ក. នីតិវិធីក្នុងការបើកគណនី

- **ជ្រើសរើសក្រុមហ៊ុនមូលបត្រ**

វិនិយោគិនត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង ១០ ដែលជាសមាជិករបស់ ផ.ម.ក. ហើយក្រុមហ៊ុនមូលបត្រនោះនឹងជួយវិនិយោគិនក្នុងការបើកគណនីជួញដូរ។

- **បើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រដែលបានជ្រើសរើស**

ឯកសារតម្រូវដើម្បីបើកគណនីជួញដូរ រួមមាន៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ភ្ជាប់ជាមួយរូបថត៤×៦មួយសន្លឹក
- លេខអត្តសញ្ញាណវិនិយោគិន (ក្រុមហ៊ុនមូលបត្រអាចជួយធ្វើការស្នើសុំពីគណៈកម្មការមូលបត្រកម្ពុជា)

បន្ថែមពីនេះ យ៉ាងហោចណាស់មួយថ្ងៃបន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. បាន។

#### ខ. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

វិនិយោគិនអាចដាក់បញ្ជាបាន លុះត្រាតែមានសាច់ប្រាក់យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសារមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។

[16] ផ្សារមូលបត្រកម្ពុជា (ផ.ម.ក), *ទិដ្ឋភាពទូទៅនៃការជួញដូរ*

រូបភាពទី ៤ ៖ នីតិវិធីនៃការជួញដូរមូលបត្រកម្មសិទ្ធិ




ប្រភព ៖ គេហទំព័រ ផ.ម.ក (២០១៨), (www.csx.com.kh)

(១) វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រ នឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីគណៈកម្មការមូលបត្រកម្ពុជា។

(២) វិនិយោគិនផ្តល់សេចក្តីបង្គាប់ឲ្យដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 ទៅកាន់ក្រុមហ៊ុនមូល បត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬ មធ្យោបាយអេឡិចត្រូនិចនានា។

(៣) ក្រោយពីត្រួតពិនិត្យមូលបត្រ និងសាច់ប្រាក់នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) អ្នកតំណាងនៅក្នុងទីផ្សារដាក់បញ្ជាតាមការបង្គាប់មកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0។ សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

(៤) ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន។

(៥) ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦)ក្រុមហ៊ុនមូលបត្របញ្ជាក់លទ្ធផលនៃការជួញដូរដែលពាក់ព័ន្ធជាមួយអតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃT+0។

(៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គងត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំនុចទី៥និងទី៦នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ ផ.ម.ក. ។

### ២.៤.២. ថ្ងៃ និង ម៉ោងជួញដូរ

#### ក. ថ្ងៃជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែង ថ្ងៃឈប់សម្រាកជាសាធារណៈ។

#### ខ. ម៉ោងជួញដូរ

ម៉ោងជួញដូរត្រូវបានកំណត់តាមវិធីសាស្ត្រជួញដូរដូចខាងក្រោម៖

- **វិធីសាស្ត្រដេញថ្លៃ**

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង៨:០០ព្រឹក ដល់ម៉ោង១១:៣០ព្រឹក ដែលបែងចែកទៅតាមវគ្គដូចខាងក្រោម៖

រូបភាពទី ៥ ៖ ម៉ោងជួញដូរមូលបត្រកម្មសិទ្ធិ

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងជួញដូរ | វិធីសាស្ត្រដេញថ្លៃ |
|---|---|---|---|
| វគ្គបើក | ៨:00 - ៩:00 | ៩:00 | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:00 - ១១:00 | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១១:00 - ១១:៣0 | ១១:៣0 | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រភព ៖ គេហទំព័រ ផ.ម.ក (២០១៨), (www.csx.com.kh)

**ចំណាំ៖** ប្រសិនបើគ្មានការផ្គូផ្គងបញ្ជានៅម៉ោង៩:០០នាទីព្រឹកទេ នោះវគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

- **វិធីសាស្រ្តជួញដូរតាមការចរចា**

ចំពោះវិធីសាស្រ្តជួញដូរតាមការចរចា ម៉ោងជួញដូរគឺចាប់ពីម៉ោង ៩:០០ នាទីព្រឹក ដល់ម៉ោង ១១:៣០ នាទីព្រឹក។

### ២.៤.៣. ប្រភេទបញ្ជា

បញ្ជាចំនួន៣ប្រភេទសំខាន់ៗដែលត្រូវដាក់ឱ្យដំណើរការនៅ ផ.ម.ក. មានដូចខាងក្រោម៖

- **បញ្ជាដែនកំណត់ (Limit Order)៖** ជាបញ្ជាដែលថ្លៃបញ្ជាទិញគឺជាថ្លៃដែលហ៊ានទិញខ្ពស់បំផុត ហើយថ្លៃបញ្ជាលក់គឺជាថ្លៃដែលហ៊ានលក់ទាបបំផុត។ ឧទាហរណ៍៖ បញ្ជាដែនកំណត់ទិញដែលមានថ្លៃ៥.០០០រៀល អាចជួញដូរបាននៅថ្លៃ៥.០០០រៀល ឬទាបជាងនេះ ចំណែកបញ្ជាដែនកំណត់លក់ដែលមានថ្លៃ៥.០០០រៀល អាចជួញដូរបាននៅថ្លៃ ៥.០០០រៀល ឬខ្ពស់ជាងនេះ។
- **បញ្ជាទីផ្សារ (Market Order)៖** ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិមួយភ្លាមៗ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទ-នីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូងឡើយ។ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌ២គឺ លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល និងលក្ខខណ្ឌជួញដូរ ហើយលុបចោល។ លក្ខខណ្ឌទាំងពីរនេះអាចប្រើប្រាស់បានតែក្នុងវិធីសាស្រ្តដេញថ្លៃដោយយកថ្លៃច្រើន និងនៅពេលដែលមានបញ្ជាផ្ទុយគ្នានៅផ្នែកម្ខាងទៀត។
  - លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល (Fill or Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាមៗ ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុង ភ្លាមៗ។ ឧទាហរណ៍៖ បញ្ជាទិញភាគហ៊ុន ក នៃបញ្ជាទីផ្សារតាមលក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល ដែលមានបរិមាណចំនួន២០០ អាចផ្គូផ្គងបានលុះត្រាតែបរិមាណនៃបញ្ជាលក់ម្ខាងទៀតមានចំនួនច្រើនជាង ឬស្មើ២០០ ។
  - លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាមៗ ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុង ឬមួយផ្នែកភ្លាមៗ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចោលភ្លាម ។ឧទាហរណ៍៖ បញ្ជាទិញភាគហ៊ុន ខ នៃបញ្ជាទីផ្សារតាមលក្ខខណ្ឌជួញដូរ ហើយលុបចោល ដែលមានបរិមាណចំនួន ២០០ ត្រូវបានផ្គូផ្គងជាមួយបញ្ជាលក់នៃ គ្រប់បរិមាណមូលបត្រ(ឧទាហរណ៍ ចំនួន

៥០)។ បរិមាណភាគហ៊ុនដែលនៅសល់បន្ទាប់ពីការផ្គូផ្គងចំនួន ១៥០ នឹង ត្រូវលុបចោលភ្លាមដោយស្វ័យប្រវត្តិ។

រូបភាពទី ៦ ៖ ការប្រៀបធៀបរវាងបញ្ជាដែនកំណត់ និង បញ្ជាទីផ្សារ

| លក្ខណៈ | បញ្ជាដែនកំណត់ | បញ្ជាទីផ្សារ |
|---|---|---|
| អាទិភាព | ជាទូទៅ មានអាទិភាពថ្លៃទាបជាងបញ្ជាទីផ្សារ លើកលែងនៅដែនកំណត់ថ្លៃខាងលើ ឬខាងក្រោម ដែលអាទិភាពពេលវេលាត្រូវបាន អនុវត្ត។ | ជាទូទៅ មានអាទិភាពថ្លៃខ្ពស់ជាងបញ្ជាទីផ្សារ លើកលែងនៅដែនកំណត់ថ្លៃខាងលើ ឬខាងក្រោម ដែលអាទិភាពពេលវេលាត្រូវបានអនុវត្ត។ |
| គោលការណ៍ផ្គូផ្គង | អាទិភាពថ្លៃ និងអាទិភាពពេលវេលាត្រូវបានអនុវត្ត | អាទិភាពថ្លៃ និងអាទិភាពពេលវេលាត្រូវបានអនុវត្ត |
| លក្ខខណ្ឌភ្ជាប់ជាមួយ | គ្មាន | លក្ខខណ្ឌជួញដូរទាំងស្រុងឬលុបចោល និងលក្ខខណ្ឌជួញដូរហើយលុបចោល ត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន |
| ការបង្ហាញថ្លៃក្នុងប្រព័ន្ធទទួលបញ្ជា | នៅថ្លៃដែលបានកំណត់ | • នៅថ្លៃល្អបំផុតនៃបញ្ជាដែនកំណត់ ± ១ ឯកតាតម្លៃថ្លៃនៅពេលមានបញ្ជាដែនកំណត់<br>• ថ្លៃចុងក្រោយ ករណីគ្មានបញ្ជាដែនកំណត់ |
| ការកែប្រែបញ្ជា | អនុញ្ញាត | មិនអនុញ្ញាត |
| ការលុបបញ្ជា | អនុញ្ញាត | អនុញ្ញាត |
| ការបង្កកសាច់ប្រាក់ | សាច់ប្រាក់បង្កកស្មើនឹងថ្លៃគុណនឹងបរិមាណបញ្ជា បូកបន្ថែមថ្លៃសេវាឈ្មួញជើងសារមូលបត្រ | សាច់ប្រាក់បង្កកស្មើនឹងថ្លៃដែនកំណត់ខាងលើគុណនឹងបរិមាណបញ្ជា បូកបន្ថែមថ្លៃសេវាឈ្មួញជើងសារមូលបត្រ |
| បំរាម | គ្មាន | • ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ<br>• ការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង |

ប្រភព ៖ គេហទំព័រ ផ.ម.ក (២០១៨), (www.csx.com.kh)

- **បញ្ជាតាមការចរចា៖** ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា។ បញ្ជាប្រភេទនេះធានាដល់ការជួញដូររបស់វិនិយោគិននៅក្នុងតែមួយប្រតិបត្តិការធំ ប៉ុណ្ណោះ និងផ្តល់ភាពសម្ងាត់ដល់បញ្ជានិងការជួញដូររបស់វិនិយោគិនក្នុងអំឡុងម៉ោងជួញដូរ។

**ចំណាំ៖** ការកែតម្រូវឬការលុបបញ្ជាអាចធ្វើទៅបាន ដរាបណាបញ្ជានោះមិនទាន់ត្រូវបានអនុវត្តការជួញដូរ។ ពេលវេលាបញ្ជាក់ពីការទទួលបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ត្រូវបានកំណត់សាជាថ្មី នៅពេលដែលមានការកែប្រែថ្លៃ ឬការបង្កើនបរិមាណនៃបញ្ជា។

### ២.៤.៤. វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រដេញថ្លៃ (ATM) ឬវិធីសាស្ត្រជួញដូរតាមការចរចា (NTM)។

#### ២.៤.៤.១. វិធីសាស្ត្រដេញថ្លៃ

#### ក. គោលការណ៍ដេញថ្លៃ

រាល់ការជួញដូរត្រូវបានអនុវត្តតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ឬ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើនយោងទៅតាមអាទិភាពថ្លៃនិងអាទិភាពពេលវេលាដូចមានខាងក្រោម៖

**អាទិភាពថ្លៃ៖** បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង និង បញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

**អាទិភាពពេលវេលា៖**ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ឧទាហរណ៍៖

| បរិមាណលក់ | ថ្លៃ | បរិមាណទិញ |
|---|---|---|
| | : | |
| | ៦.៥០០ | ①៥០០(បញ្ជាទិញដែលមានថ្លៃខ្ពស់ជាង) |
| | ៦.៤៨០ | ②១០០③២០០ |
| | ៦.៤៦០ | |
| ③៣០០②២០០ | ៦.៤២០ | |
| (បញ្ជាលក់ដែលមានថ្លៃទាបជាង) ①៤៥០ | ៦.៤០០ | |
| | : | |

* ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ បញ្ជាទិញ ① និងបញ្ជាលក់ ① ត្រូវអនុវត្តការជួញដូរមុន យោងទៅតាមអាទិភាពថ្លៃ។

* ក្នុងចំណោមបញ្ជាដែលមានថ្លៃដូចគ្នា បញ្ជា ② ដែលទទួលបានមុន នឹងត្រូវអនុវត្តការជួញដូរមុន បញ្ជា ②។

**ខ. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ**

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវអនុវត្ត តាមថ្លៃកំណត់មួយ ដែលហៅថា ថ្លៃជួញដូរ។

**គ. វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន**

តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន បញ្ជាមួយអាចជួញដូរបាននៅថ្លៃច្រើនខុសពីគ្នា។ នៅពេលបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងគេផ្គូផ្គងជាមួយបញ្ជាលក់ដែលមានថ្លៃទាបជាងគេ ថ្លៃជួញដូរគឺជាថ្លៃនៃបញ្ជាដែលទទួលបានមុន។

**២.៤.៤.២. វិធីសាស្ត្រជួញដូរតាមការចរចា**

វិធីសាស្ត្រជួញដូរតាមការចរចា ជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីអ្នកទិញនិងអ្នកលក់បានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ ដើម្បីផ្គូផ្គងបញ្ជាទិញនិងលក់តាមការចរចាមួយគូបាន ចាំបាច់ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងចំនួន៤គឺ ឈ្មោះមូលបត្រ ថ្លៃ បរិមាណ និងលេខកូដជួញដូរតាមការចរចា។

លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចារះ

- បញ្ជាអប្បបរមាៈ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច ៥០.០០០ភាគហ៊ុន ឬ តម្លៃជួញដូរ ២០០.០០០.០០០រៀល (យកមួយណាដែលតូចជាង)។
- ឯកតាគម្លាតថ្លៃៈ ១រៀល។
- ដែនកំណតថ្លៃប្រចាំថ្ងៃៈ មិនអនុវត្តចំពោះការជួញដូរតាមវិធីសាស្ត្រជួញដូរតាមការចរចា។
- ការលុបចោលបញ្ជាៈ ដរាបណាបញ្ជាមិនទាន់អនុវត្តការជួញដូរ នោះបញ្ជាតាមការចរចាអាចលុបបាន តែពុំអាចកែប្រែបានឡើយ។

**២.៤.៥. ដែនកំណត់ថ្លៃ ឯកតាជួញដូរ និង ឯកតាគម្លាតថ្លៃ**

ដែនកំណត់ថ្លៃប្រចាំថ្ងៃត្រូវស្មើនឹង បូក រឺ ដក ១០% នៃថ្លៃមូលដ្ឋាន។ នៅក្នុងករណី ថ្លៃមូលដ្ឋានទាបជាង១០០រៀល នោះដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង១០រៀល។

ឯកតាបញ្ជានៃមូលបត្រកម្មសិទ្ធិនៅផ.ម.ក. គឺ ០១ (មួយ)ឯកតាមូលបត្រកម្មសិទ្ធិ។

ថ្លៃភាគហ៊ុននៅផ.ម.ក. អាស្រ័យលើឯកតាគម្លាតថ្លៃដែលបានកំណត់ដូចខាងក្រោម៖

| ថ្លៃ (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| P < ៥.០០០ | ១០ | ២.៥៥៥; ៣.០១២; ៣.៩៩៩ | ២.៥៥០; ២.៥៦០; ៣.០១០; ៣.០២០; ៣.៩៩០ |
| ៥.០០០ ≤ P < ២០.០០០ | ២០ | ៥.២១០; ១៩.៥២៥ | ៥.២០០; ៥.២២០; ១៩.៥២០; ១៩.៥៤០ |
| ២០.០០០ ≤ P < ៥០.០០០ | ៥០ | ២០.១១០; ៣៥.៥៣០ | ២០.១០០; ២០.១៥០; ៣៥.៥០០; ៣៥.៥៥០ |
| ៥០.០០០ ≤ P < ១០០.០០០ | ១០០ | ៥០.៧២០; ៩០.៤៥០ | ៥០.៧០០; ៥០.៨០០; ៩០.៤០០; ៩០.៥០០ |
| ១០០.០០០ ≤ P < ២០០.០០០ | ២០០ | ១៥០.៥០០; ១២៥.៣០០ | ១៥០.៤០០; ១៥០.៦០០; ១២៥.២០០; ១២៥.៤០០ |
| ២០០.០០០ ≤ P < ៥០០.០០០ | ៥០០ | ៣០០.១០០; ៣៥០.២០០ | ៣០០.០០០; ៣០០.៥០០; ៣៥០.០០០; ៣៥០.៥០០ |
| P ≥ ៥០០.០០០ | ១.០០០ | ៦២០.៥០០; ៨៥២.១០០ | ៦២០.០០០; ៦២១.០០០; ៨៥២.០០០; ៨៥៣.០០០ |

* ទឹកប្រាក់ទាំងអស់គិតជារៀល

## ២.៥. សមាជិក និង អ្នកចូលរួមនៅក្នុងផ្សារមូលបត្រកម្ពុជា[17]

យោងតាមប្រកាសចុះ ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១១ ស្តីពីការដាក់ឲ្យអនុវត្តនូវវិធានសមាជិកភាពរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានកំណត់និយមន័យ **សមាជិក** គឺសំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា ហើយជាសមាជិករបស់ប្រតិបត្តិករ ទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និង ប្រតិបត្តិកររក្សាទុកមូលបត្រ និង មានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្ររបស់ផ្សារមូលបត្រកម្ពុជា។ សមាជិករបស់ផ.ម.ករួមមាន៖

| | |
|---|---|
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ១. ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី |
| | ២. អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីយូរីធី ម.ក |
| | ៣. កាណា ស៊ីយូរីធី អិលធីឌី |
| | ៤. កម្ពុ ស៊ីយូរីធី ភីអិស៊ី |
| | ៥. យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |
| | ៦. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី |

[17] ផ្សារមូលបត្រកម្ពុជា (ផ.ម.ក),*សមាជិក និងអ្នកចូលរួម*

| | |
|---|---|
| **ក្រុមហ៊ុនពាណិជ្ជកម្មមូលបត្រ** | ១.ហ្គោលដេន ហ្វ័រឈូន(ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី |
| **ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ** | ១.ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី |
| | ២. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី |
| | ៣. ខេប ស៊ីឃ្យូរីធី លីមីតធីត |

**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជីការមូលបត្រ ភ្នាក់ងារចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធ ឬសេវាកម្មរបស់ផ្សារមូលបត្រ។ គិតត្រឹមពេលបច្ចុប្បន្ន អ្នកចូលរួមរបស់ផ.ម.ករួមមាន

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី

២. ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី

៣. ធនាគារកាណាឌីយ៉ា

ភ្នាក់ងារបញ្ជិកាមូលបត្រ និង ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី

២. ត្រាយខ័រ ស៊ីឃ្យូរីធី ស៊ីរីស ភីអិលស៊ី

៣. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

# ជំពូកទី ៣
# មូលដ្ឋាននៃការវិនិយោគ
# លើមូលបត្រកម្មសិទ្ធិ

# ជំពូកទី ៣

# មូលដ្ឋាននៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ

## ៣.១. ការវិភាគមូលដ្ឋាន ( Fundametal Analysis )

ការវិភាគមូលដ្ឋាន គឺជាមធ្យោបាយមួយក្នុងការវិភាគ និង វាយតម្លៃលើមូលបត្រ ដោយផ្អែកទៅលើកត្តាដែលជះឥទ្ធិពលទៅលើក្រុមហ៊ុនដែលបោះផ្សាយមូលបត្រនោះ និង ការប្រែប្រួលនៅពេលអនាគតរបស់ក្រុមហ៊ុន។

ការវិភាគមូលដ្ឋាន គឺជាមធ្យោបាយមួយដ៏ល្អ សំរាប់វាយតម្លៃលើមូលបត្រដោយការប្រើប្រាស់នូវការវិភាគអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ការវិភាគទៅលើវិស័យ និង ការវិភាគលើក្រុមហ៊ុនដោយផ្ទាល់។

អ្នកវិនិយោគប្រើប្រាស់ការវិភាគមូលដ្ឋាននេះ ដើម្បីវាយតម្លៃទៅលើភាគហ៊ុនដែលគេចង់វិនិយោគ។ គោលបំណងនៃការវិភាគនេះគឺដើម្បីកំណត់តម្លៃជាក់លាក់មួយ ទៅប្រៀបធៀបជាមួយតំលៃរបស់ភាគហ៊ុននោះនាពេលបច្ចុប្បន្ន ថាគួរវិនិយោគភាគហ៊ុននោះដែរឬទេ។

នៅចំនុចខាងក្រោមនេះនឹងលើកយកនូវការវិភាគទាំងបី នៅក្នុងការវិភាគមូលដ្ឋានមកបកស្រាយ ដើម្បីជាពត៌មានសំរាប់ដល់អ្នកវិនិយោគយកមកពិចារណាមុននឹងវិនិយោគភាគហ៊ុនណាមួយ ។

### ៣.១.១. ការវិភាគស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

#### ៣.១.១.១. គោលគំនិត

ម៉ាក្រូសេដ្ឋកិច្ច គឺជាកត្តាមួយដ៏សំខាន់សំរាប់វិភាគស្ថានភាពរបស់ក្រុមហ៊ុន។ នៅក្នុងម៉ាក្រូសេដ្ឋកិច្ច គេត្រូវត្រួតពិនិត្យនៅចំនុចជាច្រើនដូចជា ស្ថានភាពសេដ្ឋកិច្ចរបស់ពិភពលោក ស្ថានភាពសេដ្ឋកិច្ចនៅក្នុងស្រុក គោលនយោបាយ និងព្រឹត្តិការណ៍ដែលមិនបានរំពឹងទុកជាមុន ដូចជាគ្រោះធម្មជាតិ សង្គ្រាម -ល- ។ កត្តាទាំងអស់នេះនៅក្នុងម៉ាក្រូសេដ្ឋកិច្ច ជាកត្តាដែលអាចជះឥទ្ធិពលដល់យ៉ាងខ្លាំង តម្លៃនៃភាគហ៊ុនរបស់ក្រុមហ៊ុនដែលគេចង់វិនិយោគ។

#### ៣.១.១.២ នយោបាយ

នយោបាយគឺជា កត្តា ដែលជិះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ជាពិសេសចំពោះប្រទេសដែលអស្ថេរភាពនយោបាយ។

មុនពេលសំរេចចិត្តវិនិយោគលើភាគហ៊ុនណាមួយ អ្នកវិនិយោគគួរតែសិក្សាអំពីស្ថានភាពនយោបាយរបស់ប្រទេសនោះផងដែរ ព្រោះថា កាលណាដែលប្រទេសនោះមិនមានស្ថេរភាព

នយោបាយនោះទេ វាអាចធ្វើអោយមានការផ្លាស់ប្តូរភ្លាមៗនូវ ប្រពន្ធ័ហិរញ្ញវត្ថុ អត្រាការប្រាក់ និង អត្រាប្តូរប្រាក់ ជាហេតុធ្វើអោយអ្នកវិនិយោគជួបនឹងហានិភ័យជាមិនខាន។

### ៣.១.១.៣ អថេរម៉ាក្រូសេដ្ឋកិច្ច ( Macro Economy Variable )

ដើម្បីសម្រេចចិត្តទិញភាគហ៊ុនអោយបានត្រឹមត្រូវ អ្នកវិនិយោគក៏គួរតែសិក្សាអំពីធាតុមីក្រូសេដ្ឋកិច្ចដែលអាចប្រែប្រួលផងដែរ ដែលធាតុទាំងនោះមានដូចជា ផលិតផលក្នុងស្រុកសរុប (GDP) អត្រាប្តូរប្រាក់(Exchange rate) អត្រាការប្រាក់(Interest rate) អតិផរណា(Inflation) អត្រានិកម្មភាព (Unemployment)-ល-។

តារាងខាងក្រោមនេះនឹងបង្ហាញអំពីការប្រែប្រួលនៃធាតុមីក្រូសេដ្ឋកិច្ចដែលអាចប្រែប្រួល ហើយធ្វើអោយមានការឥទ្ធិពលប៉ះពាល់ដល់ទៅលើផ្សារហ៊ុន ៖

| ធាតុដែលអាចប្រែប្រួល | ផលប៉ះពាល់ទៅលើផ្សារភាគហ៊ុន |
|---|---|
| កាលណាអត្រាផលិតផលក្នុងស្រុកមានការកើនឡើង | វិជ្ជមាន |
| កាលណាអត្រាប្តូរប្រាក់មានការកើនឡើង | វិជ្ជមាន |
| កាលណាអត្រាអតិផរណាមានការកើនឡើង | អវិជ្ជមាន |
| កាលណាអត្រានិកម្មភាពមានការកើនឡើង | អវិជ្ជមាន |
| កាលណាអត្រាការប្រាក់មានការកើនឡើង | អវិជ្ជមាន |

### ៣.១.១.៤. ព្រឹត្តិការណ៍មិនបានព្រៀងទុក

គ្មានអ្នកណាដែលអាចគ្រប់គ្រងនូវព្រឹត្តការណ៍ដែលកើតឡើងមិនបានព្រៀងទុកបាន នោះទេ ដោយព្រឹត្តិការណ៍នោះមានដូចជា ៖ សង្គ្រាម ភេរវកម្ម គ្រោះធម្មជាតិ -ល- ។ ហើយព្រឹត្តការណ៍ទាំងនោះពិតជាមានផលប៉ះពាល់យ៉ាងអវិជ្ជមានចំពោះទីផ្សារ។ នៅពេលដែលមានព្រឹត្តិការណ៍ទាំងនោះកើតឡើងអ្នកវិនិយោគត្រូវសម្រេចចិត្តភ្លាមៗ ថាគួរតែលក់ភាគហ៊ុននោះចោល ឬក៏នៅបន្តរង់ចាំដោយសង្ឃឹមថាទីផ្សារភាគហ៊ុននោះនឹងក្រោកឡើងវិញ។ ប៉ុន្តែជម្រើសដែលរង់ចាំទីផ្សារភាគហ៊ុនក្រោកឡើងវិញ ពិតជាកត្តាដែលមានហានិភ័យខ្ពស់ព្រោះថាគេមិនអាចដឹងថា តើទីផ្សារភាគហ៊ុនអាចកើតឡើងនៅពេលណា ឬ ក្រោកឡើងវិញ រឺ អត់នោះទេ។ឧទាហរណ៍ថា៖ក្រុមហ៊ុនមួយកំពុងដំណើរការអាជីវកម្មប្រកបដោយភាពរលូន ហើយតម្លៃភាគហ៊ុនក្រុមហ៊ុននោះក្នុង

ទីផ្សារមានការកើនឡើងស្រាប់តែមានគ្រោះធម្មជាតិ(គ្រោះទឹកជំនន់)កើតឡើង ជាហេតុដែលធ្វើអោយមានការបង្អាក់នូវដំណើរការអាជីវកម្ម វាធ្វើអោយតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុននោះធ្លាក់ថ្លៃផងដែរ។

### ៣.១.២. ការវិភាគលើវិស័យនៃភាគហ៊ុនជួញដូរ

ការវិភាគលើវិស័យអាជីវកម្មជាការវិភាគមួយដ៏សំខាន់ ដែលអ្នកវិនិយោគគួរតែយកចិត្តទុកដាក់អង្កេតផងដែរ។ ការវិភាគលើវិស័យអាជីវកម្ម គឺជាប្រភេទមួយនៃការស្រាវជ្រាវដើម្បីវិនិយោគដែលផ្តោតទៅលើស្ថានភាពរបស់វិស័យនៃអាជីវកម្ម។ គោលបំនងនៃការស្រាវជ្រាវនេះគឺចង់ព្យាករ-ណ៍នៃប្រាក់ចំនេញ និង កំណើននៃអាជីវកម្មរបស់ក្រុមហ៊ុននាពេលអនាគត។ វាក៏ជា ឧបករណ៍មួយដែលធ្វើអោយក្រុមហ៊ុនយល់ដឹងអំពីស្ថានភាពរបស់ខ្លួនបើប្រៀបធៀបទៅនឹង ស្ថានភាពក្រុមហ៊ុនផ្សេងទៀតដែលផលិតនូវផលិតផល ឱកាស ដែលអាជីវកម្មរបស់ក្រុមហ៊ុនត្រូវប្រឈមនាពេល អនាគត។

#### ៣.១.២.១. កម្លាំងជំរុញអោយមានការប្រកួតប្រជែង (Porter's Five Force of Competitive Position)

Porter's Five Force គឺជាឧបករណ៍ដែលសាមញ្ញតែមានសារ:សំខាន់សំរាប់ការដឹងអំពីការប្រកួតប្រជែងរបស់អាជីវកម្មក្រុមហ៊ុនហើយនឹងស្វែងរកនូវវិធីសាស្រ្តល្អៗ ដើម្បីជំនះនូវការប្រកួតប្រជែងនេះដើម្បីស្វែងរកនូវប្រាក់ចំនេញ។

រូបភាពទី ៧ ៖ កត្តាទាំង៥ ដែលជំរុញអោយមានការប្រកួតប្រជែងក្នុងទីផ្សារ




ប្រភព៖ Investopedia.Com – Porter's Five Forces

តាមរូបភាពខាងលើ យើងអាចបកស្រាយបានថា៖

កាលណានៅក្នុងអាជីវកម្មមានគូប្រកួតប្រជែងតិចតួច នោះវាមានភាពងាយស្រួល អោយផលិតផល រឺ សេវាកម្មរបស់ក្រុមហ៊ុនយើងវាយលុកក្នុងទីផ្សារ ហើយស្វែងរកនូវប្រាក់ចំនេញបានច្រើន ។

**១. ឥទ្ធិពលនៃអ្នកផ្គត់ផ្គង (Supplier Power)** : កាលណាក្រុមហ៊ុនមានអ្នកផ្គត់ផ្គង់តិចតួច នោះអ្នកផ្គត់ផ្គង់ប្រាកដជាមានឥទ្ធិពលយ៉ាងខ្លាំងមកលើក្រុមហ៊ុននោះជាមិនខាន។ ព្រោះតែក្រុមហ៊ុនគ្មាន ជំរើសច្រើនសម្រាប់អោយធ្វើការជ្រើសរើសឡើយ ទោះបីជាទំនិញដែលអ្នកផ្គត់កំណត់តម្លៃថ្លៃជាងថ្លៃទីផ្សារក៏ដោយ។ មានន័យថា មុននឹងចង់វិនិយោគលើក្រុមហ៊ុនណាមួយ អ្នកវិនិយោគគួរតែពិនិត្យទៅលើឥទ្ធិពលនៃអ្នកផ្គត់ផ្គងរបស់ក្រុមហ៊ុននោះដែរ បើក្រុមហ៊ុននោះត្រូវបានទទួលរងឥទ្ធិពលពីអ្នកផ្គត់ផ្គង់ខ្លាំងពេក វាអាចប្រឈមមុខនឹងហានិភ័យច្រើនដូចជា ការតម្លើងថ្លៃពីអ្នកផ្គត់ផ្គង់ និងការកង្វះខាតនៃទំនិញ សេវាកម្មនៅពេលដែលអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុននោះមិនអាចផ្គត់ផ្គង់អោយបានតទៅទៀត។

**២. ឥទ្ធិពលនៃអតិថិជន (Buyer Power)** : ក្រុមហ៊ុនត្រូវពិនិត្យថា តើអ្នកទិញអាចមានឥទ្ធិ-ពលធ្វើ អោយថ្លៃនៃផលិតផលរបស់ក្រុមហ៊ុនធ្លាក់ថ្លៃដែររឺទេ? កាលណាពេលក្រុមហ៊ុនមានអតិថិជនតិចពេកនោះ អតិថិជនប្រាកដជាមានឥទ្ធិពលយ៉ាងខ្លាំងចំពោះក្រុមហ៊ុន មានន័យថាអតិថិជនអាចធ្វើ អោយថ្លៃទំនិញធ្លាក់ថ្លៃទៅតាមចិត្តរបស់អតិថិជន។ តែបើក្រុមហ៊ុនមានអតិថិជនច្រើនវិញ អតិថិជនមួយចំនួនតូចនោះមិនសូវមានឥទ្ធិពលចំពោះថ្លៃនៃទំនិញរបស់ក្រុមហ៊ុនឡើយ។ ចំពោះអ្នកវិនិយោគវិញគួរតែវិនិយោគទៅលើក្រុមហ៊ុនណាដែលមានអតិថិជនច្រើនទើបប្រសើរ។

**៣. ការគំរាមកំហែងនៃទំនិញជំនួស (Threat of Substitution)** : នៅចំនុចនេះគេចង់បង្ហាញថា តើអតិថិជនរបស់ក្រុមហ៊ុនយើងមានភាពងាយស្រួលក្នុងការរកនូវទំនិញអ្វីផ្សេង ដើម្បីមកជំនួសនូវទំនិញរបស់ក្រុមហ៊ុនយើងដែររឺទេ? កាលណាអតិថិជនកាន់តែមានភាពងាយស្រួលក្នុងការរកទំនិញផ្សេងទៀតមកជំនួសនោះ វាកាន់តែធ្វើអោយទំនិញរបស់ក្រុមហ៊ុនយើងមានតម្លៃទាប និង រកប្រាក់ ចំនេញបានតិច។ ដូចនេះអ្នកវិនិយោគគួរតែវិនិយោគលើក្រុមហ៊ុនណាដែលមានផលិតផលដែលពិបាករកផលិតផលផ្សេងមកជំនួស។

**៤. ការគំរាមកំហែងនៃលំហូរចូលនូវផលិតផលថ្មី (Threat of New Entry)** : កាលណាដែលដៃគូរប្រកួតប្រជែងឃើញផលិតផលរបស់ក្រុមហ៊ុនយើងលក់ដាច់នឹងរកប្រាក់ចំនេញបានច្រើន នោះពួកគេប្រាកដជាចង់លក់ផលិតផលនោះដែរ។ កាលណាមានភាពងាយស្រួលក្នុងការចូលក្នុងទីផ្សាររបស់អ្នកប្រកួតប្រជែងថ្មីនោះប្រាក់ចំនេញក៏ត្រូវកាត់បន្ថយផងដែរ។

**៥. Competitive Rivalry** : បង្ហាញពីចំនួននិងឥទ្ធិពលនៃដៃគូរប្រកួតប្រជែង ថាក្រុមហ៊ុនយើងមានដៃគូរប្រកួតប្រជែងប៉ុន្មាននៅក្នុងអាជីវកម្ម។ តើគុណភាពផលិតផលរបស់ពួកគេយ៉ាងណាដែរបើប្រៀបធៀបជាមួយផលិតផលរបស់ក្រុមហ៊ុនយើង។ នៅពេលដែលមានដៃគូរប្រកួតប្រជែងកាន់តែច្រើនការរកនូវប្រាក់ចំនេញក៏កាន់តែពិបាក។

**៣.១.២.២. ខ្សែកោងនៃកំណើនអាជីវកម្ម** ( Industry Growth Curve )

មុនពេលសម្រេចចិត្តទិញភាគហ៊ុនរបស់ក្រុមហ៊ុនណាមួយ អ្នកវិនិយោគគួរតែអង្កេតមើលខ្សែកោងនៃកំណើននៃអាជីវកម្មរបស់ក្រុមហ៊ុននោះផងដែរ ថាតើក្រុមហ៊ុននោះកំពុងស្ថិតនៅចំនុចណានៃខ្សែកោង។

រូបភាពទី ៨ ៖ ខ្សែកោងកំណើន




ប្រភព ៖ Investopedia.Com - Industry Growth Curve

ដូចនៅរូបខាងលើ ៖ ខ្សែកោងនៃកំណើនអាជីវកម្មមាន៤ចំនុច គឺ Introduction Growth Maturnity and Decline។

នៅក្នុងដំណាក់កាលចាប់ផ្តើម (Introduction Stage) ក្រុមហ៊ុនត្រូវចំនាយដើមទុនជាច្រើនដើម្បីធ្វើការស្រាវជ្រាវ និងផ្សព្វផ្សាយផលិតផលថ្មី។ នៅក្នុងដំណាក់កាលនេះគេមិនអាចដឹងមុនថាតើផលិតផលនោះនឹងទទួលបានជោគជ័យ រឺបរាជ័យឡើយ ដូចនេះនៅក្នុងដំណាក់កាលនេះ អ្នកវិនិយោគអាចនឹងប្រឈមមុខនឹងអត្រាហានិភ័យខ្ពស់។

នៅក្នុងដំណាក់កាលកំណើន (Growth Stage) ក្រុមហ៊ុនមានផលិតផលវាយលុកក្នុងទីផ្សារហើយប្រាក់ចំនេញក៏ច្រើន ដូចនេះអ្នកវិនិយោគគួរតែវិនិយោគលើក្រុមហ៊ុនណាដែលស្ថិតនៅដំណាក់កាលនេះ។

នៅក្នុង ដំណាក់កាលនឹងនរ (Maturity Stage) ក្រុមហ៊ុនស្ថិតនៅក្នុងលក្ខណៈថេរ មានន័យថាមិនសូវមានកំណើនការលក់ឡើយ។ នៅក្នុងដំណាក់កាលនេះ ក្រុមហ៊ុនក៏ត្រូវចំនាយលុយលើការផ្សព្វផ្សាយពាណិជ្ជកម្មច្រើនផងដែរដើម្បីប្រកួតប្រជែងនឹង ទំនិញរបស់គូរប្រកួតប្រជែង។

នៅក្នុង ដំណាក់កាលធ្លាក់ចុះ (Decline Stage) ប្រសិនបើទំនិញរបស់ក្រុមហ៊ុនមិនអាចប្រកួតប្រជែងនិង ទំនិញថ្មីៗបាននោះទេ អត្រាការលក់នឹងថយចុះជាលំដាប់ ដូចនេះអ្នកវិនិយោគមិនគួរ វិនិយោគទៅលើក្រុមហ៊ុនដែលស្ថិតនៅក្នុងដំណាក់កាលនេះឡើយ។

### ៣.១.៣. ការវិភាគលើក្រុមហ៊ុន

អ្នកវិនិយោគគួរតែយកចិត្តទុកដាក់ទៅលើការវិភាគពីរនៃការវិនិយោគ ក្រុមហ៊ុនគឺ ការវិភាគគុណភាព(Qualitative Analysis) និង ការវិភាគបរិមាណ(Quanitative Analysis)។ នៅចំនុចខាងក្រោមនេះ នឹងធ្វើការបកស្រាយអំពីការវិភាគទាំងពីរនេះ។

#### ៣.១.៣.១. ការវិភាគគុណភាព( Qualitative Analysis )

មុនពេលសម្រេចចិត្តទិញភាគហ៊ុនអ្នកវិនិយោគ ក៏គួរតែធ្វើការវិភាគទៅលើការវិភាគទៅលើការវិភាគគុណភាព( Quanlitative Analysis) របស់ក្រុមហ៊ុនផងដែរ។

ការវិភាគទៅលើគុណភាពភាគច្រើនគេមិនយកជាតួរលេខមកប្រើប្រាស់នោះទេ ដោយភាគច្រើនជាវិភាគលើគុណភាពនៃការគ្រប់គ្រង កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ការទំនាក់ទំនងរបស់ក្រុមហ៊ុននោះជាមួយអ្នកខាងក្រៅល្អដែររឺទេ។

#### ៣.១.៣.២. ការវិភាគបរិមាណ

ដោយឡែកការវិភាគបរិមាណ( Quantative Analysis) គឺដូចគ្នានឹងការវិភាគរបាយការណ៍ហិរញ្ញវត្ថុដែរ។ ដោយការវិភាគនោះផ្តោតលើចំនុចសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ ៣ គឺៈ របាយការណ៍ប្រាក់ចំនេញ(Income statement) តារាងតុល្យការណ៍(Balance Sheet) និងរបាយការណ៍លំហូរសាច់ប្រាក់(Cash Flow statement)។

**ក. របាយការណ៍ប្រាក់ចំនេញ (Income Statement)**

អ្នកវិនិយោគក៏គួរតែស្វែងយល់ពីរបាយការណ៍ប្រាក់ចំនេញរបស់ក្រុមហ៊ុនផងដែរ ដើម្បីអោយការវិនិយោគកាន់តែទទួលបានភាពជោគជ័យ។ របាយការណ៍ប្រាក់ចំនេញបានបង្ហាញពីព័ត៌មានសំខាន់ៗដូចជា ចំណូលពីការលក់ និងចំណាយប្រតិបត្តិការណ៍ផ្សេងនៅក្នុងអំឡុងពេល

ណាមួយជាក់លាក់ ហើយសំខាន់បំផុតវាបង្ហាញពីប្រាក់ចំណេញ ថាតើនៅឆ្នាំនីមួយៗក្រុមហ៊ុននោះទទួលបានប្រាក់ចំណេញ រឺ ក៏ខាត។

រូបភាពទី ៩ ៖ របាយការណ៍ប្រាក់ចំនេញរបស់រដ្ឋាករទឹកក្រុងភ្នំពេញនៅត្រីមាសទី ៤ ឆ្នាំ ២០១៧



ប្រភព៖ របាយការណ៍ក្រុមហ៊ុនរដ្ឋាករទឹកក្រុងភ្នំពេញ

## ខ. តារាងតុល្យការណ៍ (Balance Sheet)

តារាងតុល្យការណ៍បានបង្ហាញនូវស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅក្នុងអំឡុង ពេលមួយជាក់លាក់។អ្នកវិនិយោគក៏គួរតែសិក្សាអោយបានច្បាស់ពីតារាងតុល្យការណ៍របស់ក្រុមហ៊ុននីមួយ ៗផងដែរ មុននឹងសំរេចចិត្តវិនិយោគ។

ធាតុទាំង៣របស់តារាងតុល្យការណ៍បានបង្ហាញអ្នកវិនិយោគនូវ ទ្រព្យសកម្ម (Asset) បំណុល (Liability) និង មូលធនម្ចាស់ (Equity) របស់ក្រុមហ៊ុន។ តារាងតុល្យការណ៍គឺជារបាយ-ការណ៍យ៉ាងសាមញ្ញ ប៉ុន្តែវាបានផ្តល់ពត៍មានជាច្រើនទៅដល់អ្នកវិនិយោគ។ វាបានបង្ហាញអោយអ្នកវិនិយោគដឹងថាក្នុងទ្រព្យសកម្ម (Asset) របស់ក្រុមហ៊ុនទាំងអស់ មានប៉ុន្មានភាគរយបានមកពីការជំពាក់គេ និង ប៉ុន្មានភាគរយជាមូលធន ដែលបានមកពីការវិនិយោគរបស់ម្ចាស់ភាគហ៊ុន។

ដើម្បីធ្វើឲ្យការសម្រេចចិត្តអោយកាន់តែមានប្រសិទ្ធិភាព អ្នកវិនិយោគគួរតែយកតារាងតុល្យការណ៍របស់ក្រុមហ៊ុនមួយទៅប្រៀបធៀបទៅនឹងក្រុមហ៊ុនផ្សេងទៀត ដែលនៅក្នុងវិស័យតែមួយ រឺ ក៏អាចយកតារាងតុល្យការណ៍ពីឆ្នាំមួយទៅប្រៀបធៀបនឹងឆ្នាំមួយទៀត។

## រូបភាពទី ១០ ៖ តារាងតុល្យការណ៍របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនៅត្រីមាសទី៤ ឆ្នាំ២០១៧

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | ១.១២៤.១៧២.១៨៣ | ១.០៣៦.៥០៥.៥៣៩ |
| ទ្រព្យសកម្មអរូបី | | ៥.២១១.៤០៦ | ១.៥៧៩.១៥៤ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១១២.៨៥៦ | ២៥៤.៧៤៥ |
| | | ១.១២៩.៤៩៦.៤៥៥ | ១.០៣៨.៣៣៨.៤៦៨ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | | ៦៤.៥២៦.១២៤ | ៤៨.៣៥៩.៤០៣ |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | ៥៥.៨០៤.១៣២ | ៣៥.៥៥៥.៥៥៥ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១៩១.៨៥៥ | ១២៣.១១២ |
| ឥណទានផ្តល់ឲ្យបុគ្គលិក | | ៥.០៣៤.៨៦៤ | ៨.៦០៨.៧៨៧ |
| វិនិយោគរយៈពេលខ្លី | ៧ | ៥៦.៧០៣.៧០៤ | ១៥៨.២៧១.៣៥៩ |
| គណនីផ្សេងៗត្រូវទទួល | | ៥.៣១២.០៥២ | ៥.៣១២.០៥២ |
| សាច់ប្រាក់ក្នុងដៃ និងធនាគារ | | ១៨.៩៩២.៥២៧ | ១៦.៣៥៦.៨៩៩ |
| | | ២៣២.៥១៨.២៥៦ | ២៥៥.០៥១.១៣២ |
| **ទ្រព្យសកម្មសរុប** | | ១.៣៦២.០១១.៧៣៧ | ១.២៩៣.៣៨៩.៦០០ |
| **មូលធន និងបំណុល** | | | |
| **មូលធនភាគហ៊ុនិក** | | | |
| ដើមទុន | | ៥៤១.២២៧.២៥២ | ៥៤១.២២៧.២៥២ |
| ទុនបម្រុង | ៦ | ២៦៤.៨២៩.៦៣៨ | ២២៩.៨៧១.៥១០ |
| ចំណេញរក្សាទុក | | ៣៣.៣១២.២៨៦ | ៤៩.២៧៣.១០៤ |
| **មូលធនរបស់ភាគហ៊ុនិកសរុប** | | ៨៣៩.៣៦៩.២៤៦ | ៨១៩.៥៧១.៧៨៦ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| ប្រាក់កម្ចី | ៧ | ២៥៨.២៨៦.៥០៣ | ២៥១.៦១៦.២១៩ |
| កាតព្វកិច្ចសោធននិវត្តន៍ | ៨ | ៣៧.២៦៧.៤៦១ | ៣៣.៩៥៣.៤៧៧ |
| ជំនួយពន្យារពីរដ្ឋាភិបាល និងដៃគូផ្សេងៗ | ៩ | ២៥.៤៥១.០០១ | ២៧.៨៥០.៩៧៥ |
| បំណុលពន្ធពន្យារ | | ៣៨.២០៧.៣៥៩ | ៣១.១៣០.៨៦៩ |
| គណនីត្រូវបង់ផ្សេងៗ | ១០ | ៩៩.៦៩៩.៨៥៨ | ៥៤.៩២២.៣១៦ |
| | | ៤០៥.៩៩២.៦២២ | ៣៩៩.៤០៣.៨៥៥ |

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៤៣៩ Et/២០១២

៤

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេប (ត)**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | |
| គណនីពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១០ | ៥១.១៤៥.១៣៤ | ៣៣.៣៥៤.២៧០ |
| ប្រាក់កម្ចី | ៧ | ៤៩.៣៥០.៦៨៤ | ៣៤.៦៥៥.៧៥៨ |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | | ១៦.១៩៤.០៩១ | ១០.១៧៣.៩២១ |
| | | ១១៦.៦៨៩.៩០៩ | ៧៨.២៥៣.៩៤៩ |
| **បំណុលសរុប** | | ៥២២.៦៤២.៥៣១ | ៤៧៧.៧៥៧.៨០៤ |
| **មូលធនរបស់ភាគហ៊ុនិក និងបំណុលសរុប** | | ១.៣៦២.០១១.៧៧៧ | ១.២៩៧.៧២៩.៦០០ |

ប្រភព៖ របាយការណ៍ក្រុមហ៊ុនរដ្ឋាករទឹកក្រុងភ្នំពេញ

### គ. របាយការណ៍លំហូរសាច់ប្រាក់ (Cash Flow Statement)

របាយការណ៍លំហូរសាច់ប្រាក់ក៏ជារបាយការណ៍មួយដែលអ្នកវិនិយោគគួរតែយកចិត្តទុកដាក់ផងដែរ។ របាយការណ៍លំហូរសាច់ប្រាក់ គឺជារបាយការណ៍ហិរញ្ញវត្ថុមួយដែលបង្ហាញពីប្រភពនៃសាច់ប្រាក់របស់ក្រុមហ៊ុនហើយនឹងរបៀបនៃការប្រើប្រាស់សាច់ប្រាក់របស់ក្រុមហ៊ុន នៅក្នុងអំឡុងពេលជាក់លាក់មួយ។ ដោយរបាយការណ៍ទាំងនោះមិនបានរាប់បញ្ចូលនូវ Non-Cash ដូចជា ការរំលស់ (Depreciation) នោះទេ។

របាយការណ៍លំហូរសាច់ប្រាក់បានបង្ហាញនូវការគ្រប់គ្រងលំហូរចូល និង ចេញនៃសាច់ប្រាក់របស់ក្រុមហ៊ុន។ វាបានបង្ហាញពីសមត្ថភាពក្នុងការសងបំណុលទៅម្ចាស់បំណុលវិញ និងការរីកចម្រើននៃផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

របាយការណ៍លំហូរសាច់ប្រាក់ត្រូវបានបែងចែកជា៣គឺ៖

- លំហូរសាច់ប្រាក់ពីប្រតិបត្តិការណ៍ ៖ ជាលំហូរសាច់ប្រាក់ប្រចាំថ្ងៃក្នុងពេលប្រតិបត្តិការណ៍អាជីវកម្ម។

- លំហូរសាច់ប្រាក់ពីការវិនិយោគ : ជាលំហូរសាច់ប្រាក់ដែលបានពីការវិនិយោគរយៈពេលវែងទៅលើទ្រព្យសម្បត្តិ ដូចជា ដីធ្លី ផ្ទះសម្បែង និង ការវិនិយោគទៅលើឧបករណ៍ហិរញ្ញវត្ថុ ដូចជា ភាគហ៊ុន ប័ណ្ណបំណុល -ល- ។
- លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ : គឺជាការនូវវាស់វែងនូវសកម្មភាពទ្រព្យសកម្ម និង បំណុល របស់ក្រុមហ៊ុន ដូចជាសកម្មភាពបោះផ្សាយមូលបត្រ រឺ ក៏ការទិញមូលបត្រត្រឡប់មកវិញ។

រូបភាពទី ១១ ៖ របាយការណ៍លំហូរសាច់ប្រាក់ក្រុមហ៊ុនរដ្ឋាករទឹកក្រុងភ្នំពេញ

លេខចុះបញ្ជីពាណិជ្ជកម្ម
Co. ០៨៣៥ E/២០១២

៧

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់សរុប**
**សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| | កំណត់សម្គាល់ | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧ គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៦ គិតជាពាន់រៀល |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ចំណេញមុនបង់ពន្ធ | | ៥២.៨២៦.៧៨៦ | ៦០.៥៩១.២៨៩ |
| និយ័តកម្ម៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | | ៥៥៣.៤០២ | ៧២៩.៣៦២ |
| រំលស់ជំនួយពេញព្រាងពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | | (២.៣៥៥.៥៧៣) | (២.៣៥៥.៥៧២) |
| រំលស់ទ្រព្យសកម្មរូបី | | ៣៦.០២៤.៥៣០ | ៣៥.២៦៦.០១០ |
| ចំណូលការប្រាក់ | | (៦.១៤៤.៥២៦) | (២០.១៥៣.៥៥៥) |
| ចំណាយការប្រាក់ | | ៣២.៨០៤.៧៣៥ | ១៧.០៧១.៧៨៣ |
| សំវិធានធនលើគណនីមានផ្តល់ឲ្យបុគ្គលិក | | ៥៧៣.៥២៣ | - |
| ការជម្រះពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៨ | ៤៥០.៨៧៥ | - |
| ខាតពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | - | ៥២០.៤០៣ |
| ចំណាយកាតព្វកិច្ចសោធននិវត្តន៍ | ៧ | ៤.៨៧១.៨២២ | ៤.០៣៦.០៥៤ |
| ចំណេញប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ១១៥.៦០១.១៧៨ | ៥៥.៦៦១.៧៣៤ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | (១៦.១៣១.៧២១) | ៥.៣២៣.៨៣៤ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (៥.៨២០.១៦៨) | (២.៣១០.៦០៦) |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | | (៣.៧៣១.៥១០) | ៦.០៧៦.២៧០ |
| ប្រាក់កក់របស់អតិថិជន | | ៤.០៧១.៧០៣ | ៥.៦៦៧.០៦៥ |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | | ៩៣.៩៩៩.០៨២ | ១១៣.៨១៨.២៥៧ |
| ចំណាយពន្ធបានបង់ | | (៥.៤១៧.៧១៥) | (១១.៧៥០.២៧៥) |
| កាតព្វកិច្ចសោធននិវត្តន៍បានបង់ | | (១.១៤៧.៥៥៥) | (១.០១៣.៩៤៧) |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ | | ៨៣.៣៨៣.៤០៤ | ១០០.៥៦៤.០៣៥ |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៤ | (១១៦.៤៥៧.៤២០) | (១៣៥.១០១.០៧១) |
| បុរេប្រទានការប្រាក់លើទ្រព្យសម្បត្តិដែលមានលក្ខណៈគ្រប់គ្រាន់ | | (៧៥៥.០១៩) | (៣៨៣.៣៤៤) |
| ការទិញទ្រព្យសកម្មអរូបី | | (២៧.៨៨១) | (៤៤០.០៥៣) |
| ទឹកប្រាក់សំណងពីឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ១២៣.១១២ | ១១១,៦៦២ |
| ការវិនិយោគរយៈពេលខ្លី | | ៥១.៥៦៧.៦៤០ | ៤៦.១៨៦.១៨០ |
| ការប្រាក់បានទទួល | | ៤.៥១៥.៣៤៧ | ១៤.៥២៩.០៣៤ |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៦០.១២៣.៨៨១) | (៧៤.៦៥៧.៨៥២) |

លេខបញ្ជីពាណិជ្ជកម្ម៖
Co ០៨៣៥ E/២០១២

ក

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់សង្ខេប (ត)**
**សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧**

| | | សម្រាប់រយៈពេល ១២ខែ គិតត្រឹមថ្ងៃទី | |
|---|---|---|---|
| | កំណត់សម្គាល់ | មិនបានធ្វើសវនកម្ម ៣១ ធ្នូ ២០១៧[1] គិតជាពាន់រៀល | បានធ្វើសវនកម្ម ៣១ ធ្នូ ២០១៦[2] គិតជាពាន់រៀល |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភដែលបានបង់ | | (១៣.៥១៤.៨៣៦) | (១៣.២៦៩.៤៥០) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ២៤.៦៦៤.៥៦៧ | ៣៣.៧៧៤.៥៥៥ |
|ការប្រាក់បានបង់ | | (៥.៧៤១.៤៩៩) | (១៧.៣១៩.៦៤៧) |
| ការបង់សងប្រាក់កម្ចី | | (២៥.៦៦៣.០៤១) | (២៥.២២០.៤១០) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | | (២៣.៦៥៣.៨៤៩) | (២២.០៣៥.០២៥) |
| **កំហាយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (៣៦៤.៣២២) | ៣.៨៣១.៨១៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ១៦.៣៨៦.៨៩៥ | ១២.៥៥៥.៤៣៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | ១៦.០៥២.៥២៧ | ១៦.៣៨៦.៨៩៥ |

***កំណត់សម្គាល់៖***
*(១) របាយការណ៍លំហូរសាច់ប្រាក់សង្ខេប ត្រូវតែអានជាមួយនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៦ ដែលបានធ្វើសវនកម្មរួច ព្រមទាំងកំណត់សម្គាល់ដែលបានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុរយៈពេលខ្លីនេះ។*
*(២) តួលេខដែលយកមកប្រៀបធៀបសម្រាប់ការិយបរិច្ឆេទ បានកំណត់ឡើងវិញ ពុំទាន់បានធ្វើសវនកម្ម។*

ប្រភព៖ របាយការណ៍ក្រុមហ៊ុនរដ្ឋាករទឹកក្រុងភ្នំពេញ

អ្នកវិនិយោគគួរតែវិនិយោគលើក្រុមហ៊ុនណាដែលក្នុង របាយការណ៍លំហូរសាច់ប្រាក់បង្ហាញថាវិជ្ជមាន រឺ ប្រៀបធៀបនឹងក្រុមហ៊ុនដទៃទៀត ហើយគួរវិនិយោគទៅលើក្រុមហ៊ុនដែលមានលំហូរសាច់ប្រាក់សុទ្ធធំជាងគេ។

### ៣.១.៤. **ការវិភាគលើអនុបាតភាគហ៊ុន** ( Stock Ratio Analysis )

ការវិភាគលើអនុបាតជាឧបករណ៍មួយដែលពេញនិយមជាងគេក្នុង ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ។ ការវិភាគលើអនុបាតគឺបានបង្ហាញអំពីទំនាក់ទំនងយ៉ាងសំខាន់ និង ជាមូលដ្ឋានក្នុងការប្រៀបធៀបលក្ខខណ្ឌមួយដែលពិបាកក្នុងការពិនិត្យលើធាតុនីមួយៗ ដែលមានសមាមាត្រកើត ឡើង។

ដើម្បីបណ្តាក់ទុនលើភាគហ៊ុនអោយកាន់តែជោគជ័យ និងទទួលបានប្រាក់ចំណេញច្រើន អ្នកវិនិយោគគួរតែសិក្សាលើអនុបាតភាគហ៊ុនរបស់ក្រុមហ៊ុននីមួយៗអោយកាន់តែច្បាស់។

ដូចនេះហើយ ទើបយើងបានលើកយកនូវអនុបាតមួយចំនួនដើម្បីមកបកស្រាយដូចខាងក្រោមនេះ ៖

#### ៣.១.៤.១. **អនុបាតនៃថ្លៃភាគហ៊ុន/ចំណូល** ( Price/Earning Ratio )

អនុបាតនៃថ្លៃភាគហ៊ុន/ចំណូល(P/E Ratio) គឺជាអនុបាតដែលវាស់វែងដោយធៀបនូវតម្លៃភាគហ៊ុនបច្ចុប្បន្នក្នុងមួយឯកតា និង ប្រាក់ចំណូលក្នុងមួយឯកតា។

ដើម្បីធ្វើការជ្រើសរើសភាគហ៊ុនដែលល្អសំរាប់ធ្វើការវិនិយោគ អ្នកវិនិយោគត្រូវធ្វើការប្រៀបធៀបក្រុមហ៊ុនមួយទៅនឹងក្រុមហ៊ុនមួយទៀតដែលស្ថិតនៅក្នុងវិស័យតែមួយ។

ចំពោះអនុបាត P/E Ratio នោះដែរវាមានរូបមន្តដូចខាងក្រោម៖

**P/E ratio = Price per Share/ Earning Per share**

ដើម្បីអោយកាន់តែច្បាស់ក្នុងការក្នុងការជ្រើសរើសភាគហ៊ុនមួយណាដើម្បីយកមកវិនិយោគដោយផ្អែកទៅលើ P/E ratio យើងបានយកឧទាហរណ៍មួយមកបង្ហាញដូចខាងក្រោម ៖

ភាគហ៊ុន "ក" មានតម្លៃបច្ចុប្បន្នស្មើនឹង៤០ដុល្លារ/ឯកតា ហើយវាមានEPS ស្មើរនឹង២ដុល្លារដូចនេះ P/E ratio = 40ដុល្លារ/2 = 20, ហើយភាគហ៊ុន "ខ" មានតំលៃបច្ចុប្បន្នស្មើនឹង២០ដុល្លារក្នុងមួយឯកតា វាមាន EPS = ១ដុល្លារ ដូចនេះ P/E Ratio= 20ដុល្លារ/1= 20

ភាគហ៊ុនទាំង២នេះមាន P/E Ratio ដូចគ្នាគឺអ្នកវិនិយោគត្រូវចំនាយ២០ដុល្លារ ដើម្បីទទួលបានប្រាក់ចំនូល 1ដុល្លារ។ នេះមានន័យថាភាគហ៊ុន "ក" អ្នកវិនិយោគទទួលបានតែ 1ដុល្លារ នៅពេលដែលភាគហ៊ុន១ឯកតា មានតម្លៃ 40ដុល្លារ ដូចគ្នានឹងភាគហ៊ុន "ខ" ដែលទទួលបាន1ដុល្លារ

ដូចគ្នាតែភាគហ៊ុន១ ឯកតា មានតម្លៃតែ 20ដុល្លារតែប៉ុណ្ណោះ។ ទោះបីជាតម្លៃភាគហ៊ុន "ខ" ថោកជាងភាគហ៊ុន "ក" ក៏ប៉ុន្តែគេមិនអាចថាភាគហ៊ុន "ខ" គួរអោយវិនិយោគជាងនោះទេ ព្រោះគេត្រូវពិចារណាលើចំនុចមួយចំនួនដូចខាងក្រោម ៖

- ភាគហ៊ុន "ក" ត្រូវបានគេរំពឹងថានឹងបង្កើននូវចំនូលនឹងប្រាក់ចំនេញលឿនជាង ភាគហ៊ុន "ខ" នៅពេលអនាគត ហើយភាគហ៊ុន "ក"ត្រូវបានគេប្រាកដចិត្តថានឹងទទួលបាន 1ដុល្លារ ដូចគេរំពឹងទុកច្រើនជាងភាគហ៊ុន "ខ"។

- ជាធម្មតាបើគេយកក្រុមហ៊ុន២ ដែលរកស៊ីក្នុងវិស័យតែមួយយកមកប្រៀបធៀបគ្នា ក្រុមហ៊ុនដែលមានស្ថេរភាព ជាក្រុមហ៊ុនដែលបង្កើតឡើងយូរមកហើយ នឹងមានកំណើនកើនជាលក្ខណៈមធ្យមច្រើនតែមាន P/E ratio ទាបជាងក្រុមហ៊ុនដែលទើបបង្កើតឡើង ហើយមានសន្ទុះនៃការកើនឡើងខ្ពស់។ ប៉ុន្តែបើអ្នកវិនិយោគយកភាគហ៊ុនរបស់ក្រុមហ៊ុនទាំងពីរមកពិចារណា ក្រុមហ៊ុនដែលទើបបង្កើតឡើងងាយប្រឈមហានិភ័យជាង។

អ្នកវិនិយោគអាចប្រៀបធៀប P/E ratio របស់ក្រុមហ៊ុនដែលប្រហាក់ប្រហែលគ្នាហើយស្ថិតនៅក្នុងវិស័យតែមួយ ដើម្បីអោយដឹងថា តើភាគហ៊ុនដែលអ្នកវិនិយោគចង់ទិញក្នុងតម្លៃទាបជ្រុល ឬ ខ្ពស់ជ្រុល។

**៣.១.៤.២. អនុបាតនៃថ្លៃ/ ចំណូល/ កំណើន** ( Price/Earning/ Growth Ratio-PEG )

អនុបាតនេះគឺជាអនុបាតមួយដែលប្រើដើម្បីយកមកធ្វើការប៉ាន់ស្មាន ពីការរីកចម្រើន នៃក្រុមហ៊ុនក្នុងអំឡុងពេលមួយ ទៅប្រាំឆ្នាំខាងមុខ។ អ្នកវិនិយោគយកអនុបាតនេះមកប្រើប្រាស់ដើម្បីអោយដឹងថា តើពួកគេគួរតែវិនិយោគលើក្រុមហ៊ុននេះដែររឺទេ។

**រូបមន្ត PEG= P/E Ratio÷ Annual EPS Growth**

អ្នកវិនិយោគភាគច្រើនគិតថា P/E Ratio គឺជាវិធីសាស្ត្រដ៏ល្អសំរាប់វិភាគថ្លៃភាគហ៊ុន ក៏ប៉ុន្តែនៅពេលខ្លះ P/E Ratio មិនបានប្រាប់នូវរឿងរ៉ាវទាំងអស់របស់ក្រុមហ៊ុនអោយអ្នកវិនិយោគបានដឹងទេ។ ចំនែកឯ PEG Ratio គឺជាការប្រើ P/E Ratio ធៀបនឹងអត្រាកំណើននៃចំនូលរបស់ក្រុមហ៊ុន។ ដូចនេះវាបានបង្ហាញនូវព័ត៌មានបានច្បាស់លាស់ជាង P/E Ratio។

ឧទាហរណ៍ ៖ ភាគហ៊ុនក្រុមហ៊ុន XYZ មាន ថ្លៃក្នុងមួយឯកតា 10ដុល្លារ , EPS=2ដុល្លារ, Annual EPS Growth= 5%, ភាគហ៊ុនក្រុមហ៊ុន ABC មាន ថ្លៃក្នុងមួយឯកតា 20ដុល្លារ , EPS=2 ដុល្លារ, Annual EPS Growth= 20%។

ដូចនេះ ភាគហ៊ុនក្រុមហ៊ុន XYZ មានP/E Ratio = 10ដុល្លារ/ 2ដុល្លារ = 5

⇨ PEG Ratio = 5/5 = 1

ភាគហ៊ុនក្រុមហ៊ុន ABC មាន P/E Ratio= 20ដុល្លារ/2 = 10

⇨ PEG Rato = 10/20 = 0.5

បើតាមឧទាហរណ៍ខាងលើ ហើយ អ្នកវិនិយោគយកតែ P/E Ratio មកប្រើប្រាស់ អ្នកវិនិយោគប្រាកដជាគិតថា ភាគហ៊ុនក្រុមហ៊ុន XYZ គឺជាភាគហ៊ុនដ៏ល្អសំរាប់វិនិយោគព្រោះវាមាន P/E Ratio ទាបជាង ភាគហ៊ុន ABC ដល់ទៅ 50% ។

ក៏ប៉ុន្តែនៅពេលដែលអ្នកវិនិយោគគិតថាក្រុមហ៊ុន ABC នឹងមានចំណូលរំពឹងទុកកើនឡើងលឿនជាង ៤ដងនៃក្រុមហ៊ុនXYZ នោះអ្នកវិនិយោគប្រាកដជាប្តូរចិត្តមកវិនិយោគភាគហ៊ុនរបស់ក្រុមហ៊ុនABC វិញជាមិនខាន។

គន្លឹះណែនាំមួយចំនួនសម្រាប់អ្នកវិនិយោគ

- កាលណា PEG Ratio តូចជាង០.៥ នោះមានន័យថាភាគហ៊ុននោះត្រូវបានគេអោយថ្លៃទាបជ្រុល ។
- កាលណា PEG Ratio ធំជាង ១ នោះមានន័យថាភាគហ៊ុននោះត្រូវបានគេអោយថ្លៃខ្ពស់ជ្រុល ។
- កាលណា PEG Ratio ចាប់ពី ០.៥ ដល់ ១ នោះវាជាតម្លៃសមស្របសម្រាប់វិនិយោគ។

### ៣.១.៤.៣ អនុបាតនៃថ្លៃភាគហ៊ុន និង ការលក់ ( Price to Sale Ratio-P/S )

អ្នកវិនិយោគតែងតែរុករកនូវមធ្យោបាយក្នុងការប្រៀបធៀបនូវតម្លៃភាគហ៊ុន ដើម្បីរកឃើញនូវភាគហ៊ុនដែលល្អបំផុតសម្រាប់វិនិយោគ។ អនុបាតនៃថ្លៃភាគហ៊ុន នឹង ការលក់( Price to Sale Ratio-P/S) គឺជាអនុបាតមួយដែលសាមញ្ញដោយយកតម្លៃភាគហ៊ុនក្នុងមួយឯកតាក្នុងពេលបច្ចុប្បន្ន ចែកនឹងចំណូលពីការលក់ក្នុងមួយឯកតា រឺ ត្រូវយកតម្លៃនៃ Market Capitalisation ចែកនឹងចំណូលពីការលក់សរុប។

អនុបាតនៃថ្លៃភាគហ៊ុន និង ការលក់មានរូបមន្តដូចខាងក្រោមៈ

$$\text{P/S Ratio} = \frac{\textit{Price Per Share}}{\textit{Sale per Share}} = \frac{\textit{Market Capitalization}}{\textit{Total sale over past 12 months}}$$

អ្នកវិនិយោគគួរតែយក P/S Ratio របស់ក្រុមហ៊ុនពីរដែលមានស្ថានភាពប្រហាក់ប្រហែលគ្នាយកមកប្រៀបធៀប។ កាលណាក្រុមហ៊ុនណាដែលបង្ហាញថាមាន P/S Ratio ទាប គឺ

ជាក្រុមហ៊ុនដែលល្អសម្រាប់ធ្វើការវិនិយោគ។ ហើយក្រុមហ៊ុនដែលមាន P/S Ratioខ្ពស់ អាចដាស់តឿនថាមិនគួរវិនិយោគឡើយ។

**៣.១.៤.៤. ទិន្នផលភាគលាភ** (Dividend Yield)

ទិន្នផលភាគលាភគឺជា អនុបាតហិរញ្ញវត្ថុមួយដែលវាស់វែងនូវតម្លៃនៃភាគលាភដែលបែងចែកទៅអោយម្ចាស់ភាគហ៊ុន (Common Stock Holder) ដោយធៀបនឹងតម្លៃភាគហ៊ុនក្នុងមួយឯកតា។

ទិន្នផលភាគលាភ គឺត្រូវបានយកទៅប្រើដោយអ្នកវិនិយោគដើម្បីបង្ហាញអោយដឹងថាប្រាក់ដែលពួកគេវិនិយោគទៅលើភាគហ៊ុនត្រូវបានបំលែងជាទម្រង់ចរន្តសាច់ប្រាក់ (Cash Flow) ទៅជាភាគលាភ រឺ ក៏ទុកដើម្បីបង្កើនតម្លៃនៃទ្រព្យសកម្ម។

អ្នកវិនិយោគធ្វើការវិនិយោគលុយរបស់ពួកគេទៅលើភាគហ៊ុនគឺរំពឹងចង់ទទួលបានភាគលាភ និង ថ្លៃកើនរបស់ភាគហ៊ុន (Stock Appreciation)។ អ្នកវិនិយោគអាចប្រើទិន្នផលភាគលាភ (Dividend Yield) ដើម្បីជួយវិភាគពីប្រាក់ចំនេញដែលទទួលបានពីរការវិនិយោគលើស្តុករបស់ពួកគេ។

ទិន្នផលភាគលាភមានរូបមន្តដូចខាងក្រោម៖

$$\text{Divident Yield} = \frac{\textit{Cash divident per share}}{\textit{Market Value per share}}$$

ទិន្នផលភាគលាភអាចធ្វើអោយអ្នកវិនិយោគដឹងថាតើក្នុង១ដុល្លារដែលពួកគេវិនិយោគលើភាគហ៊ុនទទួលបានភាគលាភប៉ុន្មាន។ អ្នកវិនិយោគគួរតែវិនិយោគលើក្រុមហ៊ុនដែលផ្តល់ទិន្នផលភាគលាភខ្ពស់មានន័យថាអ្នកវិនិយោគនឹង ទទួលបាន នូវប្រាក់ចំនេញខ្ពស់ដែលបានមកពីការវិនិយោគរបស់ពួកគេ។

**៣.១.៤.៥. តម្លៃគណនេយ្យក្នុងមួយឯកតា** ( Book Value)

អនុបាតតម្លៃគណនេយ្យរបស់ក្រុមហ៊ុន គឺជាអនុបាតមួយដែលបង្ហាញថា តើពេលបច្ចុប្បន្នតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនដែលគេចង់វិនិយោគមានតម្លៃប៉ុន្មាន បើប្រៀបធៀបជាមួយនឹងតម្លៃភាគហ៊ុននាពេលបច្ចុប្បន្ន តើវាសមស្របសម្រាប់ធ្វើការវិនិយោគដែររឺទេ។

តម្លៃគណនេយ្យ គឺបានបង្ហាញអោយឃើញនូវទ្រព្យសម្បត្តិសរុបរបស់ក្រុមហ៊ុន ដោយយកទ្រព្យសកម្មទាំងអស់របស់ក្រុមហ៊ុន(Total Assets) ដកចេញនូវទ្រព្យអរូបី (Intangible Asset) និង បំណុល (Liabilities) របស់ក្រុមហ៊ុនចេញ។

អ្នកវិនិយោគអាចយកតម្លៃគណនេយ្យ មកប្រើប្រាស់ដើម្បីអោយដឹងថា តើក្រុមហ៊ុននោះមានទ្រព្យសម្បត្តិប៉ុន្មានក្រោយពីសងបំណុលអោយគេរួចរាល់ហើយ។ ដើម្បីអោយកាន់តែច្បាស់ថា អ្នកវិនិយោគនឹងទទួលបានត្រឡប់មកវិញប៉ុន្មាន ប្រសិនបើក្រុមហ៊ុនដែលពួកគេវិនិយោគនោះក្ស័យធន គេអាចប្រើប្រាស់នូវ អនុបាត Price-to-book ratio (P/B ratio) ដោយអនុបាតនោះបានធ្វើការប្រៀបធៀបរវាងតម្លៃនៅក្នុងទីផ្សារ និង តម្លៃគណនេយ្យរបស់ភាគហ៊ុន។

**ដោយអនុបាត** P/B Ratio = $\frac{Market\ Price\ per\ share}{Book\ value\ per\ share}$

**តែ** Book Value per share = $\frac{(Total\ Asset - Total\ Liabilites)}{Number\ of\ share\ outstanding}$

ដោយសារតែ Book Value តំណាងអោយតម្លៃពិត (Net Worth) របស់ក្រុមហ៊ុន ដូចនេះហើយវាគឺជាឧបករណ៍មួយដែលមានប្រយោជន៍សម្រាប់អ្នកវិនិយោគក្នុងការកំណត់អោយ ដឹងថាតើក្រុម-ហ៊ុននោះកំពុងតែ លក់ទាបជ្រុល រឺ ខ្ពស់ជ្រុល ហើយវាបង្ហាញអោយអ្នកវិនិយោគដឹងថា តើគួរលក់ រឺ ទិញភាគហ៊ុននោះ។ ឧទាហរណ៍ អ្នកវិនិយោគភាគច្រើនចង់វិនិយោគលើភាគហ៊ុនដែលនៅស្មើ រឺ តិចជាង Book Value (មានន័យថា P/B ratio តូចជាង រឺស្មើ ១) ដែលមានន័យថាក្រុមហ៊ុននោះកំពុងលក់ភាគហ៊ុនក្នុងតម្លៃទាបជាងតម្លៃពិតរបស់ក្រុមហ៊ុន។

### ៣.១.៤.៦. ផលនៃមូលធន ( Return on Equity – ROE )

ផលនៃមូលធន គឺជាអនុបាតមួយដែលប្រើប្រាស់ដើម្បីបង្ហាញថា តើក្រុមហ៊ុនអាចរកប្រាក់ចំនេញបានប៉ុន្មានដោយប្រើប្រាស់មូលធនក្នុងមួយដុល្លារ។

ផលនៃមូលធន អាចបង្ហាញអោយយើងដឹងថា តើម្ចាស់ភាគហ៊ុន(Common Stock holder) នឹងទទួលបានប្រាក់ចំនេញប៉ុន្មានបើប្រៀបធៀបនឹងភាគហ៊ុនដែលពួកគេកំពុងកាន់កាប់។

ផលនៃមូលធន ត្រូវបានគណនាដោយប្រើរូបមន្តដូចខាងក្រោម៖

**ផលនៃមូលធន** = $\frac{\textbf{Net Income}}{\textbf{Shareholder's Equity}}$

ឧទាហរណ៍ថា ៖ ក្រុមហ៊ុនABC នៅឆ្នាំមុនមានប្រាក់ចំនេញសុទ្ធ (Net Income) ១០លានដុល្លារ ហើយមាន Share holder Equity ស្មើរនឹង ២០លានដុល្លារ ដូចនេះយើងអាចគណនាផលនៃមូលធនបានដូចខាងក្រោម៖

ផលនៃមូលធន= $\frac{\text{១០លានដុល្លារ}}{\text{២០លានដុល្លារ}}$ = ០.៥ រឺ ៥០%

នេះមានន័យថាក្រុមហ៊ុន ABC ទទួលបានប្រាក់ចំនេញ០.៥ ដុល្លារដោយប្រើប្រាស់រាល់១ដុល្លារនៃមូលធន។

អ្នកវិនិយោគគួរជ្រើសរើសវិនិយោគលើក្រុមហ៊ុនណាដែលមានផលនៃមូលធន ខ្ពស់ជាងក្រុមហ៊ុនដែលមានផលនៃមូលធនទាប បើក្រុមហ៊ុនទាំងពីរនោះមានស្ថានភាពប្រហាក់ប្រហែលគ្នា។

## ៣.២. ការវិភាគតាមលក្ខណៈបច្ចេកទេស ( Technical Analysis )

### ៣.២.១. គំនូសក្រាហ្វិក ( Charts )

#### ៣.២.១.១. ក្រាហ្វិកបន្ទាត់ ( Line Chart )

ក្រាហ្វិកបន្ទាត់ផ្តល់លក្ខណៈងាយស្រួលក្នុងការកត់សម្គាល់ចំពោះចលនានៃថ្លៃ បើធៀបនឹងប្រភេទក្រាហ្វិកផ្សេងទៀត។ ក្រាហ្វិកនេះ ត្រូវបានបង្កើតឡើងតាមរយៈការភ្ជាប់នូវរាល់ ចំនុចថ្លៃបិទ ទីផ្សារ (Closing Price) ជាអនុគមន៍នឹងពេលវេលា។ ដើម្បីយល់កាន់តែច្បាស់ សូមសិក្សាឧទាហរណ៍ជាក់ស្តែងនៃក្រាហ្វិក បន្ទាត់របស់ភាគហ៊ុនក្រុមហ៊ុន Apple ខាងក្រោម។

ផ្អែកតាមរូបភាព ១១ គេអាចដកស្រង់នូវព័ត៌មានដូចជា នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៨ ភាគហ៊ុនរបស់ក្រុមហ៊ុន Apple មានកម្រិតថ្លៃបើក (Open) $ 162.13 កម្រិតថ្លៃបិទ (Close) $161.84 តម្លៃជួញដូរ $165.26 កម្រិតថ្លៃខ្ពស់បំផុតក្នុងថ្ងៃ (High) $167.26 កម្រិតថ្លៃទាបបំផុតក្នុងថ្ងៃ (Low) $161.84 និង ទំហំជួញដូរ (Volume) 42,427,424 ឯកតា។

រូបភាពទី ១២ ៖ ក្រាហ្វិកបន្ទាត់នៃភាគហ៊ុនរបស់ក្រុមហ៊ុន Apple,Inc.




ប្រភព៖ StockCharts.Com - Line Chart, Apple,Inc. (APPL)

### ៣.២.១.២. ក្រាហ្វិកបារ (Bar Chart)

ក្រាហ្វិកបារ បានបញ្ជាក់ឲ្យឃើញច្បាស់ពី កម្រិតថ្លៃខ្ពស់បំផុត និងថ្លៃទាបបំផុត ក៏ដូចជាកម្រិតថ្លៃបើក និងថ្លៃបិទទីផ្សារ នៃភាគហ៊ុនមួយនៅលើបារតែមួយ។

រូបភាពទី ១៣ ៖ គម្រូក្រាហ្វិកបារ




ប្រភព៖ Investopedia.Com - Bar Chart

ខាងក្រោមជាក្រាហ្វិកបាររបស់ភាគហ៊ុនក្រុមហ៊ុន Google ដោយនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨ ថ្លៃបើកទីផ្សាររបស់ភាគហ៊ុនគឺ $1,034.42 ថ្លៃបិទទីផ្សារគឺ $1,018.58 ថ្លៃខ្ពស់បំផុតគឺ $1,038.37 ថ្លៃទាបបំផុតគឺ $1,018.30 ជាមួយបរិមាណភាគហ៊ុនជួញដូរក្នុងថ្ងៃគឺ 1,724,632 ឯកតា។

រូបភាពទី ១៤ ៖ ក្រាហ្វិកបារនៃភាគហ៊ុនរបស់ក្រុមហ៊ុន Google




ប្រភព៖ StockCharts.Com - Bar Chart, Alphabet,Inc. (GOOGL)

### ៣.២.១.៣. ក្រាហ្វិកទៀន (Candlestick Chart)

ក្រាហ្វិកទៀនជាការបញ្ចូលគ្នារវាងក្រាហ្វិកបន្ទាត់ និង របារ ដោយរបារនីមួយៗតំណាងឱ្យបំណែកព័ត៌មានសំខាន់ៗចំនួន បួន រួមមាន កម្រិតថ្លៃខ្ពស់ កម្រិតថ្លៃទាប កម្រិតថ្លៃបើក និងកម្រិតថ្លៃបិទ។ ជាទូទៅក្រាហ្វិកទៀនមានទម្រង់ ២ យ៉ាង៖

- Bullish Candle : នៅពេលកម្រិតថ្លៃបិទខ្ពស់ជាងកម្រិតថ្លៃបើក(ជាធម្មតាពណ៌បៃតង ឬ ស)
- Bearish Candle : នៅពេលកម្រិតថ្លៃបិទ ទាបជាង កម្រិតថ្លៃបើក(ជាធម្មតា ពណ៌ ក្រហម ឬខ្មៅ)

រូបភាពទី ១៥ ៖ ក្រាហ្វិកទៀន




ប្រភព៖ Investopedia.Com - Candlestick Chart

សូមពិនិត្យមើលរូបភាព ដើម្បីយល់កាន់តែច្បាស់ពីទម្រង់ក្រាហ្វិកទៀន។

រូបភាពទី ១៦ ៖ ក្រាហ្វិកទៀនរបស់ភាគហ៊ុនក្រុមហ៊ុន IBM




ប្រភព៖ StockCharts.Com - Candlestick Chart, IBM

### ៣.២.២. ការវិភាគលើគម្រូនៃក្រាហ្វិកភាគហ៊ុន ( Pattern Analysis )

#### ៣.២.២.១. លក្ខណៈក្បាល និង ស្មា ( Head and Shoulders )

គម្រូក្បាលនិងស្មារពិពណ៌នា អំពីការបង្កើតគំនូសតាងជាក់លាក់ ដែលព្យាករណ៍ពីការប្រែប្រួលនៃនិន្នាការកើនឡើង និងធ្លាក់ចុះនៃថ្លៃ។ លំនាំក្បាលនិងស្មាត្រូវបានគេជឿថា ជាគំរូនៃការផ្លាស់ប្តូរទិសដៅគួរឱ្យជឿជាក់បំផុត។ វាគឺជាផ្នែកមួយនៃគម្រូកំពូលជាច្រើនដែលបង្ហាញសញ្ញាដែលមានភាពខុសគ្នានៃកម្រិតភាពត្រឹមត្រូវដែលថានិន្នាការកើនឡើងកំពុងជិតចប់។

រូបភាពទី ១៧ ៖ គម្រូក្បាល និង ស្មា នៃភាគហ៊ុនរបស់ក្រុមហ៊ុន CNET Networks, Inc.




ប្រភព៖ StockCharts.Com - Chart School, Head and Shoulders Top (Reversal)

គំរូនេះមានសមាសភាគបី៖

- ស្មាឆ្វេង (Left shoulder) ៖ បន្ទាប់ពីមាននិន្នាការកើនឡើងយូរមកតម្លៃកើនឡើងដល់កម្រិតកំពូលហើយក្រោយមកមានការធ្លាក់ចុះ
- ក្បាល (Head) ៖ តម្លៃកើនឡើងជាថ្មីម្តងទៀតដើម្បីបង្កើតកំពូលថ្មីខ្ពស់ជាងមុនលើសពីកំពូលដំបូងនិងថយចុះ ម្តងទៀត
- ស្មាស្តាំ (Right shoulder) ៖ តម្លៃកើនឡើងជាលើកទីបីប៉ុន្តែមានតែកម្រិតស្មើ ឬ ប្រហាក់ប្រហែលនឹងកំពូលទី១ ប៉ុណ្ណោះមុនពេលធ្លាក់ចុះម្តងទៀត។

កំពូលទី ១ និងទី ៣គឺជាស្មាហើយកំពូលទីពីរបង្កើតក្បាល។ បន្ទាត់ដែលតភ្ជាប់កំពូលទីមួយនិងទីពីរត្រូវបានហៅថាបន្ទាត់ក។

បន្ទាត់ Neckline ក៏ដើរតួជាបន្ទាត់ Support ផងដែរ។ វិនិយោគិនមិនគួរធ្វើការសន្មតថាលក្ខណៈក្បាលនិងស្មាត្រូវបានបញ្ចប់ពេញលេញនទេ លុះត្រាតែក្រាហ្វិកថ្លៃឆ្លងកាត់ស្មាខាងស្តាំនិង កាត់បន្ទាត់ Neckline ក្នុងទិសដៅធ្លាក់ចុះ។

**៣.២.២.២. លក្ខណៈកំពូលពីរ** ( Double Top )

លក្ខណៈនៃកំពូលពីរត្រូវបានបង្កើតឡើងពីចំណុចកំពូលពីរ ដែលស្ថិតនៅទីតាំងថ្លៃស្មើគ្នាឬប្រហាក់ប្រហែលគ្នា។ លក្ខណៈកើនឡើង ទាំងពីរនេះកើតមាន ក៏ដោយសារដែរ វាមិនអាចឆ្លងផុតពីបន្ទាត់ Resistance បានឡើយ។

រូបភាពទី ១៨ ៖ លក្ខណៈកំពូលពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន Gillette Co.




ប្រភព៖ StockCharts.Com - Chart School, Double Top Reversal

ខណៈពេលដែលលក្ខណៈកំពូលពីរដង ហាក់បីដូចជាងាយសាមញ្ញ វិនិយោគិនគួរតែមានការប្រុងប្រយ័ត្នផងដែរ។ តួយ៉ាង កំពូលទាំងពីរ គួរតែឃ្លាតឆ្ងាយពីគ្នាយ៉ាងហោចណាស់មួយខែ។ ប្រសិនបើកំពូលទាំងពីរ នៅជិតគ្នាពេក វាពុំបានបង្ហាញនូវរូបភាពពេញលេញនៃកម្លាំង ផ្គត់ផ្គង់

និង តម្រូវការនោះឡើយ។ បន្ថែមពីនេះ វិនិយោគិនគួរសង្កេតផងដែរថា កម្រិតធ្លាក់ចុះនៃថ្លៃរវាងកំពូលទាំងពីរ យ៉ាងហោចណាស់ក៏ 10% ដែរ ។ ការធ្លាក់ចុះតិចជាង 10% ប្រហែលជាមិនបានបង្ហាញពីការកើនឡើងនៃសម្ពាធលក់នោះទេ។ បន្ទាប់ពីនេះ គេក៏គួរពិនិត្យពីទំហំជួញដូរ ដើម្បីស្វាបស្ទង់ពីតម្រូវការនៃភាគហ៊ុនដែរ។

រូបភាពទី ១៩ ៖ លក្ខណៈកំពូលពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន Ford




ប្រភព៖ StockCharts.Com - Chart School, Double Top Reversal

### ៣.២.២.៣. លក្ខណៈបាតពីរ (Double Bottom)

លក្ខណៈនៃកំពូលពីរត្រូវបានបង្កើតឡើងពីចំណុចទាបពីរ ដែលស្ថិតនៅទីតាំងថ្លៃស្មើគ្នាឬប្រហាក់ប្រហែលគ្នា។ លក្ខណៈធ្លាក់ចុះទាំងពីរនេះកើតមាន ក៏ដោយសារដែល វាមិនអាចឆ្លងផុតពីបន្ទាត់ Support បានឡើយ។

រូបភាពទី ២០ ៖ លក្ខណៈបាតពីរនៃភាគហ៊ុនរបស់ក្រុមហ៊ុន United Technologies Corp.




ប្រភព៖ StockCharts.Com - Chart School, Double Bottom Reversal

**៣.២.២.៤. លក្ខណៈកំពូលបី និងបាតបី** ( Triple Top and Trip Bottom )

លក្ខណៈកំពូលបីកើតឡើង នៅពេលតម្លៃភាគហ៊ុនកើនឡើងដល់ចំនុចខ្ពស់បំផុតចំនួន ៣ លើក ដែលមានកម្ពស់ប្រហាក់ប្រហែល ឬ ស្មើគ្នា។បន្ទាប់ពីថ្លៃបានកើនដល់កំពូលនីមួយៗ ថ្លៃត្រូវបានសន្និដ្ឋានថានឹងធ្លាក់ចុះរហូតដល់ប៉ះ ឬ កៀកបន្ទាត់ Support។

មានយុទ្ធសាស្ត្រជួញដូរខុសៗគ្នាជាច្រើនដែលអ្នកវិនិយោគអាចពិចារណាប្រើប្រាស់ ដើម្បីទាញយកអត្ថប្រយោជន៍នៃតម្រង់បែបនេះ។ ចំនុចដែលគួរអោយកត់សម្គាល់ ជាការពិតណាស់ កំពូលទីមួយនិងទីពីរគឺជាចំណុចល្អឥតខ្ចោះដើម្បីដាក់ការបញ្ជាលក់។ បន្ទាប់ពីការកើនឡើងទ្វេដងត្រូវបានបញ្ចាក់ហើយប្រសិនបើតម្លៃឡើងថ្លៃម្តងទៀតជាមួយបរិមាណទាប វាគឺជាឱកាសសមស្របក្នុងការ លក់។

រូបភាពទី ២១ ៖ លក្ខណៈកំពូលបីនៃភាគហ៊ុនរបស់ក្រុមហ៊ុន Champion Enterprise Inc.




ប្រភព៖ StockCharts.Com - Chart School, Triple Top Reversal

លក្ខណៈបាតបីកើតឡើងនៅពេលតម្លៃភាគហ៊ុនធ្លាក់ចុះដល់ចំនុចទាបបំផុតចំនួន ៣ លើក ដែលមានកម្ពស់ប្រហាក់ប្រហែល ឬ ស្មើគ្នា។បន្ទាប់ពីថ្លៃបានធ្លាក់ដល់បាតនីមួយៗ ថ្លៃត្រូវបានសន្និដ្ឋានថានឹងកើនរហូតដល់ប៉ះ ឬ កៀកបន្ទាត់ Resistance។

រូបភាពទី ២២ ៖ លក្ខណៈបាតបីនៃភាគហ៊ុនរបស់ក្រុមហ៊ុន Anadarko Petroleum Corp.




ប្រភព៖ StockCharts.com-Chart School, Triple Bottom Reversal

### ៣.២.២.៥. លក្ខណៈរូមតូច ( Wedge Pattern )

លំនាំរូមតូចក្នុងទិសដៅកើនឡើង (Rising Wedge Pattern) ត្រូវបានកំណត់ដោយលំនាំគំនូសតាងដែលត្រូវបានបង្កើតនៅពេលដែលទាំងតម្លៃភាគហ៊ុនខ្ពស់(High Price) និងតម្លៃទាប (Low Price) មានកំណើនជាបន្តបន្ទាប់។ នៅពេលដែលលំនាំនេះត្រូវបានរកឃើញថាស្ថិតក្នុងទិសដៅកើនឡើង(Uptrend) វាត្រូវបានគេសង្កេតថានឹងមានលំនាំបញ្ច្រាស (Reverse Pattern) កើតឡើង ព្រោះការខិតជិតគ្នារវាង ថ្លៃខ្ពស់ និង ថ្លៃទាប បង្ហាញថាទិសដៅកើនឡើងកំពុងថយចុះ។

បន្ទាត់ Lower Highs និង Higher Lows មានចលនាពីឆ្វេងទៅស្តាំ។ ថ្វីបើបន្ទាត់ទាំងពីរចង្អុលក្នុងទិសដៅដូចគ្នាក៏ដោយក៏ខ្សែបន្ទាត់ Higher Lows ខិតឡើងទៅកៀកនឹង បន្ទាត់ Lower Highs ។ តម្លៃជាធម្មតាមានការប្រែប្រួលធ្លាក់ចុះ នៅពេលបន្ទាត់ទាំងពីរកាន់តែកៀកគ្នាដល់ចំនុច Breakout។

រូបភាពទី ២៣ ៖ លំនាំរូមតូចក្នុងទិសដៅកើនឡើងនៃភាគហ៊ុនរបស់ក្រុមហ៊ុន Dell




ប្រភព៖ StockCharts.Com - Chart School, Rising Wedge (reversal)

លំនាំរូមតូចក្នុងទិសដៅធ្លាក់ចុះ (Falling Wedge Pattern) គឺត្រូវបានកំណត់ដោយលំនាំគំនូសតាងដែលបង្កើតនៅពេលនៅពេលដែលទាំងតម្លៃភាគហ៊ុនខ្ពស់ (High Price) និងតម្លៃទាប (Low Price) មានការធ្លាក់ចុះជាបន្តបន្ទាប់។ នៅពេលដែលលំនាំនេះត្រូវបានរកឃើញនៅក្នុងនិន្នាការធ្លាក់ចុះនោះវាត្រូវបានគេចាត់ទុកថាជាគំរូវិជ្ជមានព្រោះការធ្លាក់ចុះជិតនឹងដល់ចំនុចបញ្ចប់។

បន្ទាត់ Lower Highs និង Higher Lows ទាំងពីរធ្លាក់ចុះពីឆ្វេងទៅស្តាំ។ ផ្នែកខាងលើចុះទៅមុំស្រាលជាងបន្ទាត់ទាបជាង។ តម្លៃជាធម្មតាមានការប្រែប្រួលកើនឡើង នៅពេលបន្ទាត់ទាំងពីរកាន់តែកៀកគ្នាដល់ចំនុច Breakout ។

រូបភាពទី ២៩ ៖ លំនាំរូមតូច (ទិសដៅធ្លាក់ចុះ) នៃភាគហ៊ុនរបស់ Rowan Companies, Inc.




ប្រភព៖ StockCharts.Com - Chart School, Falling Wedge (reversal)

### ៣.២.២.៦. លក្ខណៈទង់ជាតិ ឬ ស្លាបព្រា ( Flag and Pennant )

ទំរង់ទង់ជាតិឬស្លាបព្រាបង្កើតបាននៅពេលការកើនឡើងតម្លៃយ៉ាងខ្លាំង បន្ទាប់មកផ្លាស់ទីធ្លាក់ចុះបន្តិច។ ចលនាធ្លាក់ចុះបន្តិចនេះជាធម្មតាបង្កើតបានជាទំរង់ចតុកោណ (ទង់ជាតិ) ឬត្រីកោណតូចមួយ (Pennant)។ការកើនឡើងថ្លៃដើមមុនពេលចេញ ជាទម្រង់ទង់ត្រូវបានគេហៅថាបង្គោលទង់។

រយៈពេលថ្លៃធ្លាក់ចុះនេះជាធម្មតា តែងតែជាសញ្ញាថានឹងមានការកើនឡើងនៃថ្លៃនាពេលបន្ទាប់។ នេះគឺជាកន្លែងដែលឱកាសទិញជូរមក។ នៅពេលដែលបង្គោលទង់និងទង់ជាតិលេចជារូបរាង អ្នកជួញដូរសម្លឹងមើលតម្លៃដើម្បីស្វែងរកបរបត់នៃថ្លៃនៅខាងលើទង់ ហើយនេះជាសញ្ញាទិញ។ លំនាំខាងលើគឺមានលក្ខណៈសុទិដ្ឋិនិយម(Bulish) ដោយសារតែលំនាំបានចាប់ផ្តើមជាមួយនឹងការប្រមូលផ្តុំយ៉ាងខ្លាំង ។

រូបភាពទី ២៥ ៖ លក្ខណៈទង់ជាតិ Flag នៃភាគហ៊ុនរបស់ក្រុមហ៊ុន Hewlett-Packard




ប្រភព៖ StockCharts.Com - Chart School, Flag, Pennant (Continuation)

នៅទីនេះក៏មានសន្ទុះធ្លាក់ចុះ (Bearish) ផងដែរដែលតម្លៃធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់មកបង្កើតទង់ជាតិ។ ជាមួយនឹងគំរូនេះសូមមើលតម្លៃដើម្បីបំបែកនៅខាងក្រោមទង់ជាតិ ។

អ្នកជួញដូរសម្លឹងមើលនិន្នាការតម្លៃដើម្បីស្វែងរកបរបត់នៃថ្លៃនៅខាងក្រោមទង់ ដែលជាសញ្ញានៃការលក់។

រូបភាពទី ២៦ ៖ លក្ខណៈ Pennant នៃភាគហ៊ុនរបស់ក្រុមហ៊ុន Dell




ប្រភព៖ StockCharts.com-Chart School, *Flag, Pennant (Continuation)*

### ៣.២.៣. សូចនករទីផ្សារ ( Market Indicator )

#### ៣.២.៣.១. មធ្យមរំកិល ( Moving Average )

មធ្យមរំកិល Moving Average ជាតម្លៃមធ្យមនៃភាគហ៊ុនមួយ ក្នុងរយៈពេលកំណត់ណាមួយ។ MA ធ្វើការសិក្សាទិសដៅបច្ចុប្បន្ន ដោយផ្អែកតាមទិន្នន័យពីអតីតកាល។ តម្លៃមធ្យមទាំងនេះត្រូវបានគូសនៅលើក្រាហ្វិក ហើយក្លាយជាបន្ទាត់ដែលរំកិលទៅមុខជារៀងរាល់ថ្ងៃដែលជួញដូរ ។

Moving Average ពីរប្រភេទ ដែលត្រូវបានគេនិយមប្រើប្រាស់គឺ Simple Moving Average (SMA) និង Exponential Moving Average (EMA) ។ សូមពិនិត្យរូបភាព ដើម្បីស្វែងយល់ពី SMA និង EMA។

រូបភាពទី ២៧ ៖ ក្រាហ្វិក SMA និង EMA នៃភាគហ៊ុនរបស់ក្រុមហ៊ុន Intel Corp.




ប្រភព៖ StockCharts.Com - Chart School, Moving Averages - Simple and Exponential

SMA ត្រូវបានគណនា ដោយរកតម្លៃមធ្យមនៃភាគហ៊ុនមួយ នៅក្នុងរយៈពេលជាក់លាក់មួយ ដែលតម្លៃនៃភាគហ៊ុន ដែលយកមកគណនាគឺជា តម្លៃបិទទីផ្សារ (Closing price) ។ ឧទាហរណ៍ SMA សម្រាប់រយៈពេល 5 ថ្ងៃគឺជាតំលៃមធ្យមនៃថ្លៃបិទទីផ្សារចំនួន 5 ថ្ងៃ។ SMA គឺជាមធ្យមដែលអាចផ្លាស់ទី មានន័យថា ទិន្នន័យចាស់ត្រូវបានទម្លាក់ចោលដោយជំនួសមកវិញដោយទិន្នន័យថ្មី។ ខាងក្រោមនេះគឺជាឧទាហរណ៍មួយនៃការគណនា SMA ក្នុងរយៈពេល 5 ថ្ងៃ ៖

កម្រិតថ្លៃបិទប្រចាំថ្ងៃ៖ 11, 12, 13, 14, 15, 16, 17

$$First\ day\ of\ 5-day\ SMA = \frac{11+12+13+14+15}{5} = 13$$

$$Second\ day\ of\ 5-day\ SMA = \frac{12+13+14+15+16}{5} = 14$$

$$Third\ day\ of\ 5-day\ SMA = \frac{13+14+15+16+17}{5} = 15$$

First day of 5-day SMA គណនារយៈពេលប្រាំថ្ងៃដំបូង (11 ដល់ 15) ។ Second day of 5-day SMA ទម្លាក់ចំណុចទិន្នន័យដំបូង (11) និងបន្ថែមចំណុចទិន្នន័យថ្មី (16) ។

Third day of 5-day SMA បន្តទម្លាក់ចំណុចទិន្នន័យដំបូង (12) និងការបន្ថែមចំណុចទិន្នន័យថ្មី (17) ។

EMA មានលក្ខណៈស្រដៀងគ្នាទៅនឹង SMA លើកលែងតែមានទម្ងន់ (Weights) បន្ថែមទៀតត្រូវបានផ្តល់ឱ្យទៅទិន្នន័យចុងក្រោយបំផុត (ទិន្នន័យថ្មីៗ) ។ ចំពោះ EMA គេសង្កេតឃើញថា មានប្រតិកម្មឆ្លើយតបលឿនទៅនឹងបច្ចុប្បន្នភាពនៃតម្លៃភាគហ៊ុននៅលើទីផ្សារ។ គួរកត់សម្គាល់ផងដែរថា វិនិយោគិនគួរប្រើប្រាស់ទិន្នន័យតម្លៃភាគហ៊ុនឲ្យច្រើនជាង 10 ថ្ងៃ ដើម្បីទទួលលទ្ធផលកាន់តែច្បាស់លាស់ពី EMA។

ដើម្បីគណនា EMA ជាដំបូងគេត្រូវគណនា SMA សម្រាប់ជាមូលដ្ឋានតម្លៃសម្រាប់ EMA ។ EMA ចាំបាច់ត្រូវចាប់ផ្តើមពីចំណុចណាមួយ ដូច្នេះ SMA ត្រូវបានប្រើជា តម្លៃ EMA នៃអំឡុងពេលពីមុន (Previous Period's EMA ) ។ ជំហានទីពីរ គេត្រូវគណនារកតម្លៃទម្ងន់មេគុណ (Weighting multiplier)។ ជំហានទីបី គេគណនារក EMA សម្រាប់ថ្ងៃនីមួយៗរវាងតម្លៃ EMA ដំបូង (Initial EMA Value) និងថ្ងៃនេះ ដោយប្រើតម្លៃមេគុណ (Multiplier) និងតម្លៃ EMA នៃអំឡុងពេលពីមុន (Previous Period's EMA ) ។ រូបមន្តខាងក្រោមគឺសម្រាប់គណនារក EMA រយៈពេល 10 ថ្ងៃ។

$$Initial\ \ SMA = Previous\ EMA = 10\ periods\ sum/10$$

$$Multiplier = \frac{2}{Time\ periods + 1} = \frac{2}{10+1} = 0.1818\ (18.18\%)$$

$$EMA = (Cloase - Previous\ EMA) \times Multiplier + Previous\ EMA$$

រូបភាពទី ២៨ ៖ ក្រាហ្វិក 50-day SMA និង 50-day EMA នៃភាគហ៊ុនរបស់ក្រុមហ៊ុន IBM




ប្រភព៖ StockCharts.Com - Chart School, Moving Averages - Simple and Exponential

អ្នកវិនិយោគិនក៏អាចប្រើប្រាស់ MA កំណត់ និង បញ្ជាក់ពីនិន្នាការ ដូចជា ក្នុងករណី Double Crossovers ដែល ប្រភេទ MA ទាំងពីរ (SMA និង EMA) ត្រូវបានប្រើរួមគ្នាដើម្បី បង្កើតជាសញ្ញាកាត់គ្នា (Crossover Signal)។ Bullish Crossover កើតឡើង នៅពេលដែល MA រយៈពេលខ្លី កាត់ជាមួយ MA រយៈពេលវែង ក្នុងទិសដៅវិជ្ជមាន។ ចំណុចកាត់គ្នានេះ ហៅថា Golden Cross ដែលឲ្យសញ្ញាថា តម្លៃភាគហ៊ុននឹងបន្តកើនឡើង។ Bearish Crossover កើតឡើងនៅពេលដែល MA រយៈពេលខ្លី កាត់ជាមួយ MA រយៈពេលវែង ក្នុងទិសដៅអវិជ្ជមាន។ ចំណុចកាត់គ្នានេះត្រូវបានគេស្គាល់ថាជា Death Cross ដែលមានន័យថាតម្លៃភាគហ៊ុននឹងធ្លាក់ចុះ ។ លក្ខណៈ Golden Cross និង Death Cross ត្រូវបានបង្ហាញដូចខាងក្រោម៖

រូបភាពទី ២៩ ៖ Golden Cross និង Death Cross នៃភាគហ៊ុនរបស់ក្រុមហ៊ុន Home Depot, Inc.




ប្រភព៖ StockCharts.Com - Chart School, Moving Averages - Simple and Exponential

MA ក៏អាចដើរតួជាបន្ទាត់ Support និងបន្ទាត់ Resistance ផងដែរ។ MA ត្រូវបានប្រើប្រាស់ជាបន្ទាត់ Support នៅពេលដែលវាការពារថ្លៃមិនអោយថ្លៃធ្លាក់ចុះទាបជាងនេះ ផ្ទុយមកវិញវាក្លាយជាបន្ទាត់ Resistance នៅពេលទប់ថ្លៃមិនឲ្យកើនឡើងហួសពីបន្ទាត់។

ក្រាហ្វិកខាងក្រោមបង្ហាញពី SMA សម្រាប់ ពីពាក់កណ្តាលឆ្នាំ 2004 រហូតដល់ចុងឆ្នាំ 2008 ។ រយៈពេល 200 ថ្ងៃបានបង្កើតជាបន្ទាត់ Support ជាច្រើនដង។ នៅពេលដែលនិន្នាការ

មានការផ្លាស់ ប្តូរនៅត្រង់កំពូល 2 (Double top) 200-day SMAបានក្លាយជាបន្ទាត់ Resistance នៅត្រង់តម្លៃ9,500 ។

រូបភាពទី ៣០ ៖ លក្ខណ: Support និង Resistance របស់ 200-day SMA (ក្រុមហ៊ុន NYSE)




ប្រភព៖ StockCharts.com-Chart School, *Moving Averages - Simple and Exponential*

### ៣.២.៣.២. **សូចនករ** Moving Average Convergence-Divergence

សូចនករ MACD គឺជាឧបករណ៍វិភាគមួយដែលសិក្សាអំពីកម្លាំងនៃការប្រែប្រួល ទិសដៅ សន្ទុះ និង រយៈពេលនៃនិន្នាការរបស់តម្លៃភាគហ៊ុនមួយ។ MACD ត្រូវបានគេគណនាតាមរយៈ ផលដករវាង12-day Exponential Moving Average និង 6-day Exponential Moving Average ។ រីឯ 9-day Exponential Moving Average ត្រូវបានកំណត់ជា "បន្ទាត់សញ្ញា" (Signal Line) ហើយត្រូវបានគូសរួមគ្នាជាមួយបន្ទាត់ MACD ពីរផ្សេងទៀតខាងលើ ដើម្បីផ្តល់សញ្ញាសម្រាប់ការ ទិញនិងលក់ភាគហ៊ុន។

រូបភាពទី ៣១ ៖ ខ្សែ MACD និង Signal Line របស់ក្រុមហ៊ុន PowerShares QQQ Trust




ប្រភព៖ StockCharts.com-Chart School, *Moving Average Convergence-Divergence (MACD)*

រូបមន្តគណនាគឺ

- $MACD\ Line = 12\ days\ EMA - 26\ days\ EMA$
- $Signal\ Line = 9\ days\ EMA\ of\ MACD\ Line$
- $MACD\ Histogram = MACD - Signal\ Line$

អ៊ីស្តូក្រាមគឺ វិជ្ជមាននៅពេលបន្ទាត់ MACD ស្ថិតនៅពីលើ Signal Line និង អវិជ្ជមាននៅពេលបន្ទាត់ MACD ស្ថិតនៅខាងក្រោម Signal Line។

ខ្សែបន្ទាត់ MACD អាចមានចលនានៅខាងលើ ឬ ខាងក្រោម បន្ទាត់សូន្យ ដែលត្រូវបានគេស្គាល់ផងដែរថាជាបន្ទាត់កណ្តាល (Centerline)។ សញ្ញាឆ្លងកាត់ (Crossover Signal) ទាំងនេះបង្ហាញថា 12-day EMA បានឆ្លងកាត់ 26-day EMA ។ ចំពោះលក្ខណៈ MACD វិជ្ជមានមានន័យថា 12-day EMA គឺស្ថិតនៅខាងលើ 26-day EMA។ តម្លៃវិជ្ជមានមានការកើនឡើងខណៈដែល 12-

day EMA កាន់តែឃ្លាតចេញ (Diverge) ពីខាងលើ 26-day EMA ដែលនេះមានន័យថាសន្ទុះវិជ្ជមាន (Upside Momentum) គឺ កំពុងតែកើនឡើង។ តម្លៃ MACD អវិជ្ជមានបង្ហាញថា 12-day EMA ស្ថិតនៅក្រោម 26-day EMA។ ផ្ទុយមកវិញ តម្លៃអវិជ្ជមានកើនឡើងនៅពេលដែល 12-day EMA កាន់តែឃ្លាតចេញ (Diverge) ពីខាងក្រោម 26-day EMA។ នេះមានន័យថាសន្ទុះធ្លាក់ចុះ (Downside Momentum) គឺកំពុងតែកើនឡើង។

រូបភាពទី ៣២ ៖ លក្ខណៈវិជ្ជមាន និង អវិជ្ជមាននៃ MACD របស់ក្រុមហ៊ុន Home Depot




ប្រភព៖ StockCharts.Com - Chart School, Moving Average Convergence-Divergence

ក្នុងឧទាហរណ៍រូបភាព ៣១ តំបន់ពណ៌លឿងបង្ហាញថាបន្ទាត់ MACD នៅក្នុងដែនអវិជ្ជមាននៅពេលដែល 12-day EMA នៅខាងក្រោម 26-day EMA ។ ការឆ្លងដំបូងបានកើតឡើងនៅចុងខែកញ្ញា (ព្រួញពណ៌ខ្មៅ) ហើយខ្សែ MACD បន្តចលនាក្នុងដែនអវិជ្ជមាន ស្របពេលដែល 12-day EMA កាន់តែឃ្លាតឆ្ងាយ (Diverge)ពី 26-day EMA។ ចំណែកឯ តំបន់ពណ៌ទឹកក្រូចបង្ហាញអំពីតម្លៃវិជ្ជមាននៃ MACD នៅពេលដែល 12-days EMA ស្ថិតនៅខាងលើ 26-day EMA។ ចូរកត់សម្គាល់ថាខ្សែបន្ទាត់ MACD បន្តស្ថិតនៅក្រោម តម្លៃ 1 ក្នុងកំឡុងពេលនេះ (បន្ទាត់ពណ៌ក្រហម)

។ នេះមានន័យថាចម្ងាយរវាង 12-day EMA និង 26-day EMA គឺតិចជាង 1 ឯកតា ដែលមិនមែនជាភាពខុសគ្នាធំដុំនោះឡើយ។

**ការឆ្លងកាត់បន្ទាត់សញ្ញា (Signal Line Crossovers)**

Signal Line Crossovers គឺ ជាសញ្ញាទូទៅបំផុតនៃ MACD។ 9-day EMA ត្រូវបានដើរតួជាបន្ទាត់សញ្ញា (Signal Line) ដែល វាផ្តល់ភាពងាយស្រួលក្នុងការសិក្សាពីចលនារបស់ MACD ។ ចំណុច Bullish Crossover កើតមានឡើងនៅពេល MACD ងើបឡើង ហើយឆ្លងកាត់បន្ទាត់សញ្ញា ដែលនេះជាសញ្ញាសម្រាប់វិនិយោគិន គួរតែទិញ ព្រោះតម្លៃភាគហ៊ុនកំពុងបន្តកើនឡើង។ រីឯចំណុច Bearish Crossover កើតមាននៅពេលដែល MACD ធ្លាក់ចុះ និង ឆ្លងកាត់នៅខាងក្រោមបន្ទាត់សញ្ញា ដែលជាសញ្ញាវិនិយោគិន គួរលក់ភាគហ៊ុនរបស់ខ្លួន ខណៈពេលតម្លៃភាគហ៊ុននឹងបន្តធ្លាក់ចុះ។

គំនូសតាងខាងក្រោមបង្ហាញពី តម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន IBM ដែលមានបង្ហាញដោយខ្សែ 12-day EMA (ពណ៌បៃតង) និង 26-day EMA (ពណ៌ក្រហម)។ ក្នុងនោះផងដែរ ករណី Signal Line Crossovers មានចំនួន ៨ ដង នៅក្នុងរយៈពេល ៦ខែ រួមមាន ៤ ដង ឡើង និង ៤ ដងចុះ។ តំបន់ពណ៌លឿង ជារយៈពេលដែលខ្សែបន្ទាត់ MACD បានកើនឡើងនៅខាងលើចំណុចលេខ 2 ។ ក្នុងនោះក៏មានករណី Bearish Signal Crossovers ចំនួន ២ លើក នៅខែមេសា និងឧសភា ប៉ុន្តែ តម្លៃភាគហ៊ុន IBM នៅតែបន្តមាននិន្នាការកើនឡើងខ្ពស់។

រូបភាពទី ៣៣ ៖ ករណី Signal Line Crossovers របស់ក្រុមហ៊ុន IBM




ប្រភព៖ StockCharts.Com – Chart School, Moving Average Convergence-Divergence

**Centerline Crossovers**

ករណីផ្សេងមួយទៀត ដែលគេសង្កេតឃើញកើតឡើងញឹកញាប់ផងដែរ គឺសញ្ញា Centerline Crossovers។ ចំណុច Bullish Centerline Crossover កើតឡើងនៅពេល MACD ផ្លាស់ទីខាងលើបន្ទាត់សូន្យ (Zero Line) ដើម្បីលេចចេញសន្ទុះវិជ្ជមាន។ ព្រឹត្តិការណ៍នេះលេចចេញ នៅពេលដែល 12-day EMA ផ្លាស់ទី ខាងលើ 26-day EMA។ ចំណុច Bearish Centerline Crossover កើតមានឡើងនៅពេល MACD ផ្លាស់ទីនៅខាងក្រោមបន្ទាត់សូន្យដើម្បីលេចចេញសន្ទុះអវិជ្ជមាន។ ហេតុការណ៍នេះកើតឡើងនៅពេលដែល 12-day EMA បានផ្លាស់ប្តូរនៅខាងក្រោម 26-day EMA។

ខាងក្រោមនេះគឺជាតារាងរបស់ ក្រុមហ៊ុន Cummins Inc. (CMI) ដែលមានករណី Centerline Crossovers ចំនួន ៧ ដង សម្រាប់រយៈពេល ៥ ខែ។

រូបភាពទី ៣៩ ៖ ករណី Centerline Crossovers របស់ក្រុមហ៊ុន Cummins




ប្រភព៖ StockCharts.Com –Chart School, Moving Average Convergence-Divergence

**ករណី Divergence**

ករណី Divergence ត្រូវបានបែងចែកជាពីរគឺ Bullish Divergence និង Bearish Divergence។ Bullish Divergence កើតឡើង នៅពេលដែលតម្លៃភាគហ៊ុន ធ្លាក់ចុះកាន់តែទាបជាងមុន (Lower Low) ហើយ MACD មានកម្រិតធ្លាក់ចុះកាន់តែទាបជាងមុន (Higher Low) មានន័យថា ទោះបីភាគហ៊ុនមានទិសដៅធ្លាក់ចុះ តែមានសន្ទុះធ្លាក់ចុះខ្សោយជាងមុន។

រូបភាពទី ៣៥ ៖ Bullish Divergence នៃភាគហ៊ុនរបស់ក្រុមហ៊ុន Google, Inc.




ប្រភព៖ StockCharts.Com – Chart School, Moving Average Convergence-Divergence

Bearish Divergence កើតមាននៅពេលតម្លៃភាគហ៊ុនកាន់តែកើនឡើងខ្ពស់ (Higher high) ហើយ MACD មានកំណើនកាន់តែទាបជាងមុន (Lower high) ដែលមានន័យថា ទោះបីភាគហ៊ុនមានទិសដៅកើនឡើង តែមានសន្ទុះកើនឡើងខ្សោយជាងមុន។

រូបភាពទី ៣៦ ៖ Bearish Divergence នៃភាគហ៊ុនរបស់ក្រុមហ៊ុន Gamestop Corp.




ប្រភព៖ StockCharts.Com – Chart School, Moving Average Convergence-Divergence

### ៣.២.៣.៣.សូចនករ On Balance Volume (OBV)

OBV ជាវិធានវាស់វែងរវាងសម្ពាធនៃការទិញ (Buying Pressure) និងសម្ពាធនៃការលក់ (Selling Pressure) របស់ភាគហ៊ុនមួយដែលវាបានបូកបន្ថែមនូវបរិមាណនៃថ្ងៃដែលការជួញដូរកើនឡើង (Up day) និងកាត់បន្ថយបរិមាណនៃថ្ងៃដែលការជួញដូរធ្លាក់ចុះ (Down day)។

របៀបគណនា OBV ត្រូវបានបង្ហាញដូចខាងក្រោម៖

- ប្រសិនបើ កម្រិតថ្លៃបិទផ្សារបច្ចុប្បន្នខ្ពស់ជាងកម្រិតថ្លៃបិទផ្សារម្សិលមិញ

$$Current\ OBV = Previous\ OBV + Current\ Volume$$

- ប្រសិនបើ កម្រិតថ្លៃបិទផ្សារបច្ចុប្បន្នទាបជាងកម្រិតថ្លៃបិទផ្សារម្សិលមិញ

$$Current\ OBV = Previous\ OBV - Current\ Volume$$

- ប្រសិនបើ កម្រិតថ្លៃបិទផ្សារបច្ចុប្បន្នស្មើនឹងកម្រិតថ្លៃបិទផ្សារម្សិលមិញ

$$Current\ OBV = Previous\ OBV\ (no\ change)$$

រូបភាពទី ៣៧ ៖ On Balance Volume នៃភាគហ៊ុនរបស់ក្រុមហ៊ុន Wal-Mart Stores




ប្រភព៖ StockCharts.Com - Chart School, On Balance Volume (OBV)

លោក Joe Granville ស្ថាបនិកនៃ OBV បានអះអាងថា បរិមាណជួញដូរជាកត្តាសំខាន់នាំមុខ ទៅលើបម្រែបម្រួលតម្លៃនៃភាគហ៊ុនមួយ។ លោកបានបញ្ជាក់ថា OBV កើនឡើង នៅពេលបរិមាណនៃថ្ងៃជួញដូរកើន (Up day) មានកម្រិតខ្ពស់ជាងបរិមាណនៃថ្ងៃជួញដូរធ្លាក់ចុះ (Down day)។ ប្រសិនបើ OBV កើនឡើង វាឆ្លុះបញ្ចាំងពីសម្ពាធវិជ្ជមានទៅលើបរិមាណជួញដូរ ដែលតម្រូវការស្ទុះឡើង នឹង នាំឱ្យមានថ្លៃបន្តកើន។ ផ្ទុយទៅវិញប្រសិនបើ OBV ធ្លាក់ចុះ វាបានបង្ហាញពីសម្ពាធអវិជ្ជមានទៅលើបរិមាណជួញដូរ ដែលការផ្គត់ផ្គង់កើនខ្ពស់ជាងតម្រូវការ នឹង នាំឲ្យតម្លៃនៃភាគហ៊ុនបន្តធ្លាក់ចុះទាប។

លោក Granville ក៏បានកត់សម្គាល់នៅក្នុងការស្រាវជ្រាវរបស់គាត់ថា OBV នឹងផ្លាស់ប្តូរជាញឹកញាប់មុនពេលនៃបម្រែបម្រួលតម្លៃ។ គេរំពឹងថាតម្លៃនឹងឡើងខ្ពស់ប្រសិនបើ OBV កំពុងកើនឡើង ទោះតម្លៃភាគហ៊ុនធ្លាក់ថ្លៃ ដោយសារការធ្លាក់ចុះនេះគ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះហើយ គេក៏រំពឹងថាតម្លៃនឹងធ្លាក់ចុះទាប បើសិនជា OBV កំពុងធ្លាក់ចុះ ទោះបីតម្លៃភាគហ៊ុនកំពុងកើន។

### ៣.២.៣.៤. សូចនករ Relative Strength Index (RSI)

Relative Strength Indicator (RSI) គឺជាសូចនករដំពេញនិយមមួយដែលមានតួនាទីវាស់នូវ ល្បឿន (Speed) និងការផ្លាស់ប្តូរ (Change) នៃចលនាតម្លៃ។ ខ្សែ RSI ត្រូវបានវាស់ពីចន្លោះ 0 ទៅ 100 ។ ជាទូទៅខ្សែ RSI ត្រូវបានគេសន្មតថាករណីតម្លៃភាគហ៊ុនត្រូវបានឲ្យតម្លៃខ្ពស់ពេក (Overbought) ស្ថិតនៅខាងលើ 70 និងករណីតម្លៃភាគហ៊ុនត្រូវបានឲ្យតម្លៃទាបពេក (Oversold) ស្ថិតនៅក្រោម 30។ សញ្ញាអាចត្រូវបានបង្កើតដោយស្វែងរកភាពខុសគ្នានិងតំលៃធ្លាក់ចុះ។ ខ្សែ RSI ក៏អាចត្រូវបានប្រើដើម្បីកំណត់និន្នាការទូទៅផងដែរ។

RSI ត្រូវបានគណនាតាមរយៈរូបមន្តដូចខាងក្រោម៖

$$RSI = 100 - \frac{100}{1 + RSI}$$

ដែល $RS = \frac{Average\ Gain}{Average\ Loss}$

**ករណី Overbought-Oversold**

លោក J. Welles Wilder ស្ថាបនិកនៃRSI បានសន្មតថា តម្លៃភាគហ៊ុនត្រូវបានឲ្យតម្លៃខ្ពស់ពេក (Overbought) នៅពេលដែលខ្សែ RSI ស្ថិតនៅខាងលើ 70 និងករណីតម្លៃភាគហ៊ុនត្រូវបានឲ្យតម្លៃទាបពេក (Oversold) នៅពេលដែលខ្សែ RSI ស្ថិតនៅក្រោម 30 ។ រូបភាព ៣៧ បង្ហាញពីភាគហ៊ុនរបស់ក្រុមហ៊ុន McDonalds ជាមួយ ខ្សែ RSI រយៈពេល 14 ថ្ងៃ។

រូបភាពទី ៣៨ ៖ ករណី Overbought និង Oversold នៃភាគហ៊ុនក្រុមហ៊ុន McDonalds




ប្រភព៖ StockCharts.Com - Chart School, Relative Strength Index (RSI)

### ៣.២.៣.៥. **សូចនករ** Bollinger Bands

សូចនករ Bollinger Bands គឺជាឧបករណ៍វិភាគភាគហ៊ុនមួយតាមលក្ខណៈបច្ចេកទេសដែលមានតួនាទីសំខាន់ក្នុងការសិក្សាថាតើភាគហ៊ុនមួយត្រូវបានគេឲ្យតម្លៃទាបពេក (Overbought) ឬ តម្លៃខ្ពស់ពេក (Oversold) នៅលើទីផ្សារជួញដូរ។ Bollinger Bands មានទម្រង់ស្រដៀងទៅនឹងមធ្យមរំកិល (Moving Average) ក្នុងន័យថា វាបានកំណត់យកខ្សែបន្ទាត់មធ្យមរំកិលជាខ្សែបន្ទាត់គោល (Baseline)ក្នុងការប្រៀបធៀបបម្រែបម្រួលថ្លៃ។

Bollinger Bands ផ្សំដោយរបារចំនួនបីរួមមាន Upper Band Middle Band Lower Band។ វិធីគណនារបស់វា ត្រូវបានបង្ហាញដូចខាងក្រោម៖

$$Middle\ Band = 20 - day\ simple\ moving\ average\ (SMA)$$

$$Upper\ Band = 20 - day\ SMA + (20 - day\ standard\ deviation\ of\ price \times 2)$$

$$Lower\ Band = 20 - day\ SMA - (20 - day\ standard\ deviation\ of\ price \times 2)$$

ដែល SMA ជាផលបូកនៃថ្លៃបិទទីផ្សារចែកនឹងចំនួនថ្ងៃជួញដូរនោះ។

ផ្នែកកណ្តាលគឺជាបន្ទាត់ Simple Moving Average (SMA) ដែលជាធម្មតាត្រូវបានកំណត់ក្នុង ចន្លោះរយៈពេល 20 ថ្ងៃនៃអំឡុងពេលជួញដូរ ផ្នែកខាងលើហៅថា Upper Bands និង ផ្នែកខាងក្រោមហៅថា Lower Bands។ គួរបញ្ជាក់ផងដែរ ការគណនា Bollinger Bands អាចស្វែងរកតាមរយៈប្រព័ន្ធ Software គួបផ្សំនឹងលក្ខណៈស្មុគស្មាញនៃរូបមន្ត នោះការសិក្សានេះសូមមិនបកស្រាយឲ្យលម្អិតនោះទេ។

នៅក្នុងឧទាហរណ៍នៃ ការអនុវត្តសូចនាករ Bollinger Bands តម្លៃភាគហ៊ុនត្រូវបានរំកិលនៅក្នុងចន្លោះ Upper Bands និង Lower Bands ។ ដើម្បីងាយស្រួលក្នុងការសិក្សា សូម ពិនិត្យមើល Bollinger Bands ត្រូវបានបង្ហាញនៅក្នុងរូបភាព ៣៩។

រូបភាពទី ៣៩ ៖ Upper Bands និង Lower Bands របស់ភាគហ៊ុនក្រុមហ៊ុន Apple




ប្រភព៖ StockCharts.com - Apple (AAPL) with Bollinger Bands (20,2)

ដោយសារតែគម្លាតស្តង់ដារ (Standard Deviation) គឺជារង្វាស់នៃការប្រែប្រួលតម្លៃភាគហ៊ុន នោះនៅពេលដែលទីផ្សារប្រែប្រួលកាន់តែខ្លាំងឡើង (more volatile) គម្លាតរវាង Upper Bands និង Lower Bands កាន់តែរីកធំ និងនៅពេលដែលទីផ្សារពុំសូវប្រែប្រួលខ្លាំង (less volatile) គម្លាតរវាង Upper Bands និង Lower Bands ក៏រួមតូច។

គួរកត់សម្គាល់ផងដែរថា នៅពេលតម្លៃភាគហ៊ុនផ្លាស់ទីនៅក្បែរ ឬ ប៉ះ Upper Band នោះវាជាសញ្ញាបញ្ជាក់ថាភាគហ៊ុនត្រូវបានគេកំណត់តម្លៃខ្ពស់ពេក (Overbought) ដែលនេះជាឱកាសសម្រាប់លក់ភាគហ៊ុន។ ផ្ទុយមកវិញ នៅពេលដែលតម្លៃភាគហ៊ុនផ្លាស់ទីនៅក្បែរ ឬ ប៉ះ Lower Band ផ្តល់សញ្ញាថាភាគហ៊ុនត្រូវបានគេកំណត់តម្លៃទាបពេក (Oversold) ដែលនេះជាឱកាសទិញ។ បន្ថែមជាងនេះទៅទៀត វិនិយោគិនក៏គួរកត់សម្គាល់ដែរថា ប្រសិនបើតម្លៃភាគហ៊ុនរក្សាការប្រែប្រួលនៅចន្លោះ Upper Band និង 20-day SMA នោះមានន័យថាកម្លាំងនៃតម្រូវការនឹងនូវបន្តភាពវិជ្ជមានដែរ។ ក៏ប៉ុន្តែ ប្រសិនបើ តម្លៃភាគហ៊ុនបានឆ្លងកាត់ 20-day SMA នោះ និន្នាការអវិជ្ជមាននៃថ្លៃនឹងកើតឡើង។

ចំណែករបៀបកំណត់មេគុណគម្លាតស្តង់ដារ(Standard Deviation Multiplier) អាចប្រែប្រួលទៅតាម លក្ខណៈពិសេសនៃមូលបត្រនីមួយៗ។ លោក Bollinger ជាស្ថាបនិកនៃសូចនាករនេះបាន ណែនាំឱ្យធ្វើការកែសម្រួលបន្តិចបន្តួចទៅលើតម្លៃលេខនៃមេគុណគម្លាតស្តង់ដារ។ ការផ្លាស់ប្តូរចំនួន រយៈពេលសម្រាប់គណនា Moving Average ក៏មានផលប៉ះពាល់ដល់ទិន្នន័យដែលត្រូវបានប្រើដើម្បីគណនាគម្លាតស្តង់ដា (Standard Deviation)ផងដែរ។ ដូច្នេះការកែសម្រួលបន្តិចបន្តួចជាជម្រើសដ៏ងាយសម្រាប់កំណត់មេគុណគម្លាតស្តង់ដារ (Standard Deviation Multiplier)។ លោក Bollinger បានគូសបញ្ជាក់ថា ជាមួយការសិក្សារក 20-day SMAនិងគម្លាតស្តង់ដា 20 ថ្ងៃ មេគុណគម្លាតស្តង់ដារគួរកំណត់ឲ្យតម្លៃ 2 ។ លោកក៏បានបន្ថែមថា មេគុណគម្លាតស្តង់ដារគួរកើនដល់ 2.1 សម្រាប់ដំណាក់កាលសិក្សា 50-day SMA ហើយបន្ថយមេគុណគម្លាតស្តង់ដារមកត្រឹម1.9 សម្រាប់រយៈពេល សិក្សា 10-day SMA។

## ៣.៣. ស្វែងយល់ហានិភ័យនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ

### ៣.៣.១. ហានិភ័យជាប្រព័ន្ធ ( Systematic Risk )

ហានិភ័យជាប្រព័ន្ធ (Systematic Risk) គឺជាហានិភ័យបណ្តាលមកពីកត្តាដែលប៉ះពាល់ដល់មូលបត្រទាំងអស់។ ហានិភ័យជាប្រព័ន្ធមានដូចជា ការប្រែប្រួលអត្រាអតិផរណា ភេរវកម្ម ដំណឹងអំពីសង្គ្រាម ការបាត់បង់ជីវិតនៃមេដឹកនាំដែលមានអំណាចនៃប្រទេសជាតិ អត្រានិកម្មភាពគ្រោះ ធម្មជាតិជាដើម។

### ៣.៣. ២. ហានិភ័យមិនជាប្រព័ន្ធ ( Unsystematic Risk )

ហានិភ័យមិនជាប្រព័ន្ធគឺជាហានិភ័យកើតមានជាក់លាក់ចំពោះតែក្រុមហ៊ុន ឬ ឧស្សាហកម្មមួយប៉ុណ្ណោះ។ ហានិភ័យទាំងនោះរួមមាន ៖

- ហានិភ័យអាជីវកម្ម គឺ ជាភាពមិនច្បាស់លាស់ដែលទាក់ទងនឹងការលក់ និងការរកប្រាក់ចំណេញរបស់ក្រុមហ៊ុនក្នុងរយៈពេលមួយ។
- ហានិភ័យហិរញ្ញវត្ថុ គឺ សំដៅថា ក្រុមហ៊ុនពុំមានសមត្ថភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួនចំពោះម្ចាស់បំណុលរបស់ខ្លួន។
- ហានិភ័យប្រតិបត្តិការ គឺ ជាហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីការបរាជ័យក្នុងដំណើរការផ្ទៃក្នុង ការគ្រប់គ្រងធនធានមនុស្ស និង ប្រព័ន្ធប្រតិបត្តិការផងដែរ។




ដើម្បីកាត់បន្ថយនៅហានិភ័យខាងលើ គេអាចអនុវត្តវិធីសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ការធ្វើពិពិធកម្ម ជាមធ្យោបាយមួយដែលអ្នកវិនិយោគទិញភាគហ៊ុន ច្រើនប្រភេទផ្សេងៗគ្នាដើម្បីកាត់បន្ថយនូវការខាតបង់ បើសិនជាគេវិនិយោគតែលើភាគហ៊ុនមួយប្រភេទ។
- ការវិនិយោគសាច់ប្រាក់ថេរ (Dollar-Cost Average) ជាវិធីមួយដែលវិនិយោគិនបែងចែកនូវបរិមាណសាច់ប្រាក់មួយជាក់លាក់ ហើយវិនិយោគទៅលើភាគហ៊ុនមួយក្នុងរយៈពេលមួយទៀងទាត់ (ប្រចាំខែ ប្រចាំត្រីមាស ឬ ប្រចាំឆ្នាំ)។ ដូច្នេះវិនិយោគិនទទួលបានភាគហ៊ុនកាន់តែច្រើននៅពេលដែលថ្លៃភាគហ៊ុនមានកម្រិតទាប និទទួលបានភាគហ៊ុនតិចជាងមុននៅពេលដែលថ្លៃភាគហ៊ុនកើនឡើង។ ដោយសន្មតថា តម្លៃភាគហ៊ុនមានការប្រែប្រួលក្នុងអំឡុងពេលវិនិយោគ លទ្ធផលចុងក្រោយគឺជាការចំណាយសរុបក្នុងមួយហ៊ុនជាមធ្យមសម្រាប់រយៈ

ពេលផ្សេងគ្នាមានតម្លៃទាបជាង បើប្រៀបធៀបទៅនឹងចំណាយសរុបជាជាមធ្យម បើគេទិញតែម្តង។

- ការវិនិយោគបន្ត មានន័យថាចំណូលដែលបានពីភាគហ៊ុន នឹងត្រូវបានប្រើប្រាស់ឡើងវិញតាម រយៈការវិនិយោគលើភាគហ៊ុនដដែល ឬ ផ្សេងទៀត ដើម្បីកាត់បន្ថយហានិភ័យ។

សរុបសេចក្តីមក ហានិភ័យគឺជាផ្នែកមួយនៃការវិនិយោគ។ ចំពោះហានិភ័យជាប្រព័ន្ធ ពិតជាលំបាកក្នុងការកាត់បន្ថយ ចំណែកឯហានិភ័យមិនជាប្រព័ន្ធ គេអាចអនុវត្តវិធីសាស្ត្រ ដូចជាការធ្វើពហុវិនិយោគ ការវិនិយោគសាច់ប្រាក់ថេរ និង ការវិនិយោគបន្ត។ ក្រៅវិធីសាស្ត្រខាងលើ វិនិយោគិន ក៏អាចអនុវត្តវិធីសាស្ត្រដទៃទៀត ដូចជា ការរៀបចំផែនការវិនិយោគជាដើម។ ការវិនិយោគដែលមានហានិភ័យខ្ពស់ ជាទូទៅតម្រូវឱ្យវិនិយោគិន មានលទ្ធភាពកាន់កាប់សម្រាប់រយៈពេលវែង(5-10 ឆ្នាំ) ។ សំខាន់ជាងនេះទៅទៀតវិនិយោគិនគួរតែមានការយល់ដឹងថាការទទួលយកកម្រិតខ្ពស់នៃហានិភ័យមិនតែងតែមានផលត្រលប់ខ្ពស់នោះទេ។

# សេចក្តីសន្និដ្ឋាន
# និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវពីប្រធានបទ មូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិរួចមក យើងមានជំនឿថា វាបានពាំនាំមកនូវចំណេះដឹង និង គន្លឹះដ៏មានសារៈសំខាន់ នៅក្នុងការវិនិយោគលើវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជាផ្ទាល់។ ប្រធានបទនេះបានរួមចំណែកសម្រាលនូវភាពលំបាកក្នុងការវិនិយោគ របស់វិនិយោគិន។ ជាក់ស្តែង ជាការចាប់ផ្តើម នៅក្នុងជំពូកទី ១ បានបកស្រាយនៅ និយមន័យនៃការវិនិយោគ មូលបត្រ និង ទីផ្សារមូលបត្រ ព្រមទាំង ប្រភេទនៃការវិនិយោគ ប្រភេទនៃមូលបត្រ ប្រភេទនៃទីផ្សារមូលបត្រ អត្ថប្រយោជន៍នៃការវិនិយោគក្នុងវិស័យនេះជាដើម។

ជាបន្តមកទៀត នៅក្នុងជំពូកទី ២ គឺបានរៀបរាប់ពីទិដ្ឋភាពទូទៅនៃ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ព្រមទាំង ចក្ខុវិស័យ បេសកកម្ម និង សមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់នៃស្ថាប័ន។ ព្រមជាមួយគ្នានេះ យើងក៏បានលើកឡើងនូវ លក្ខខណ្ឌផ្សេងៗដែលវិនិយោគិនត្រូវស្វែងយល់មុននឹងធ្វើការជួញដូរ។ ការសិក្សាទាំងនេះ គឺអនុញ្ញាតឲ្យវិនិយោគអាចអនុវត្តការជួញដូរប្រកបដោយភាពងាយស្រួល និងប្រសិទ្ធិភាពបន្ថែមមួយកម្រិតទៀត។

នៅក្នុងជំពូកទី ៣ បានចូលមកបកស្រាយពីមូលដ្ឋានគ្រឹះនៃការវិនិយោគលើមូលបត្រកម្មសិទ្ធិដោយបែងចែក ជាពីរផ្នែកធំៗគឺ ការវិភាគតាមលក្ខណៈមូលដ្ឋាន និង ការវិភាគតាម លក្ខណៈបច្ចេកទេស។ ក្នុងផ្នែកការវិភាគតាមលក្ខណៈមូលដ្ឋាន មានការណែនាំពីការវិភាគស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ការវិភាគលើវិស័យអាជីវកម្ម ការវិភាគលើក្រុមហ៊ុន និង ការវិភាគលើអនុបាទភាគហ៊ុន។ ចំនុចទាំងនេះ ជាជំនួយដល់ការសម្រេចចិត្តរបស់វិនិយោគិនក្នុងការជ្រើសរើសក្រុមហ៊ុនដែលមានសក្តានុពល។ ងាកមក ការវិភាគតាមលក្ខណៈបច្ចេកទេសបានផ្តោតលើបម្រែបម្រួលនៃតម្លៃភាគហ៊ុន និង ឱកាសវិនិយោគ តាមរយៈការសិក្សាកាន់តែស៊ីជម្រៅលើគំនូសតាងក្រាហ្វិក គម្រូក្រាហ្វិក និង វិភាគសូចនាករទីផ្សារ។ ផ្នែកទាំងនេះ បានផ្តល់នូវមូលដ្ឋានយ៉ាងសំខាន់សម្រាប់វិនិយោគិនពង្រឹងនូវការសំរេចចិត្តរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព និង ភាពស័ក្តិសិទ្ធិ។ ក្នុងផ្នែកបញ្ចប់ ក៏មានការបង្ហាញនូវហានិភ័យនៃការវិនិយោគមួយចំនួនដែលអាចកើតឡើងក្នុងវិស័យមូលបត្រ ដោយភ្ជាប់មកជាមួយផងដែរ នៅវិធីសាស្ត្រខ្លះៗវិនិយោគិនអាចប្រើប្រាស់ ក្នុងគោលដៅកាត់បន្ថយហានិភ័យទាំងនោះ។ ការយល់ដឹងទាំងនេះ នឹងឲ្យវិនិយោគិនមានការត្រៀមខ្លួនប្រកបដោយទំនុកចិត្តខ្ពស់។

## ២. ការផ្តល់អនុសាសន៍

ដោយការវិនិយោគលើទីផ្សារមូលបត្រ តែងតែមានធាតុផ្សំរវាង ផលត្រឡប់ និង ហានិភ័យ ដែលអាចផ្តល់វិបាកសម្រាប់វិនិយោគិនធ្វើការសម្រេចចិត្ត ក្រុមយើងខ្ញុំ សូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- ស្វែងយល់ស៊ីជម្រៅអំពីក្រុមហ៊ុនបោះផ្សាយដោយផ្អែកលើព័ត៌មានសំខាន់ៗ ដូចជា របាយការណ៍ហិរញ្ញវត្ថុ ព័ត៌មានដំណើរការក្រុមហ៊ុន និង ព័ត៌មានបច្ចុប្បន្នភាពនានា ដែលជះអាចឥទ្ធិពលលើការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន។
- អនុវត្តការវិភាគទាំងតាមលក្ខណៈមូលដ្ឋាន និងតាមលក្ខណៈបច្ចេកទេស។ ការវិភាគលក្ខណៈមូលដ្ឋានអនុញ្ញាតឲ្យវិនិយោគិន ទទួលនូវចំណេះដឹងក្នុងការជ្រើសរើសក្រុមហ៊ុនមានសក្តានុពល និង ផ្តល់ផលត្រឡប់នាពេលអនាគត។ ចំណែកឯ ការវិភាគលក្ខណៈបច្ចេកទេស ផ្តល់នូវការស្វែងយល់បន្ថែមអំពីការប្រែប្រួលនៃតម្លៃភាគហ៊ុន ក៏ដូចជា ឱកាសវិនិយោគ តាមរយៈការប្រមូលព័ត៌មាននៃការជួញដូរ ដូចជា បម្រែបម្រួលថ្លៃ និង បរិមាណជួញដូរជាដើម។
- វិនិយោគិនគួរបែងចែកមូលធនរបស់ខ្លួនវិនិយោគលើភាគហ៊ុននៃក្រុមហ៊ុនក្នុងវិស័យផ្សេងៗគ្នា នឹងគួរជៀសវាងវិនិយោគក្នុងពេលតែមួយ ដើម្បីបន្ថយនូវកម្រិតហានិភ័យ។
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីអំពីចំណេះដឹងទីផ្សារមូលបត្រកម្ពុជា និងការវិនិយោគលើវិស័យនេះដែលរៀបចំដោយគណៈកម្មការមូលបត្រកម្ពុជា និង ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ឲ្យបានញឹកញាប់ ដើម្បីឲ្យក្តាប់បាននូវការវិវឌ្ឍថ្មីៗនៃទីផ្សារ។
- រៀបចំ នឹងដាក់ឲ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រស្របតាមគោលបំណង បទពិសោធន៍ និងមូលធនដែលខ្លួនមាន។ ផែនការវិនិយោគអាចមានរយៈពេលខ្លី ឬ រយៈពេលវែង។
- ស្វែងយល់ឲ្យច្បាស់លាស់អំពីលក្ខខណ្ឌ និង ទិដ្ឋភាពនៃការជួញដូរ ដូចជាលក្ខខណ្ឌតម្រូវមុនការវិនិយោគ ពេលវេលាជួញដូរ ក្រុមហ៊ុនដែលបោះផ្សាយជាដើម។
- វិនិយោគិនគួរមានភាពបត់បែនទៅតាមកាលៈទេសៈនៃទីផ្សារ និងរៀនសូត្រពីកំហុសឆ្គងរបស់ខ្លួនដែលមានពីកន្លងមក។ ការកែលម្អកំហុសពីមុន នឹងធ្វើឲ្យការវិនិយោគនៅពេលក្រោយកាន់តែមានអត្រាជោគជ័យប្រសើរឡើង។

# ឯកសារយោង

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ

### ច្បាប់និងបទប្បញ្ញត្តិផ្សេងៗក្នុងវិស័យមូលបត្រកម្ពុជា


១. ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

២. អនុក្រឹត្យថ្មីស្តីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ លេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៨ មករា ២០១៥

៣. ប្រកាសស្តីពី ការដាក់អោយអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ លេខ០១៧/១៧ គ.ម.ក ប្រ.ក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧។

៤. ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តវិធានសមាជិកភាព លេខ ០០៣/១១ គ.ម.ក ប្រ.ក ចុះថ្ងៃទី ០៣ ឧសភា ២០១១

៥. ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រា លេខ ២៧៣ សហវប្រ.ក ចុះថ្ងៃទី ១៧ មីនា ២០១៦


### សៀវភៅ និងអត្ថបទផ្សេងៗ


៦. សាស្ត្រាចារ្យ ឈាងហ៊ុយ (២០១៤), *មូលដ្ឋានគ្រឹះវិនិយោគ*, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


### របាយការណ៍កម្មសិក្សា និងសារណាបញ្ចប់កម្មសិក្សា


៧. ហេង ហុងស៊ីម (២០១៣), *មូលដ្ឋាននៃការវិនិយោគលើមូលបត្រកម្មសិទ្ធិ* , សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## ឯកសារជាភាសាបរទេស


៨. Michael Sincere (2004), *Understanding Stocks*, USA McGraw-Hill

៩. Michael Sincere (2011), *All About Market Indicators*, USA: McGraw-Hill

១០.Esme Faerber (2008), *All About Stocks*, Third Edition, USA: McGraw-Hill

## ឯកសារដកស្រង់ពីគេហទំព័រ


១១. ផ្សារមូលបត្រកម្ពុជា (២០១៨), *ប្រវត្តិ ផ.ម.ក.*។ ដកស្រង់ខែ មេសា ០៣, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/kh/about/profile.jsp?MNCD=10301;

១២. ផ្សារមូលបត្រកម្ពុជា (២០១៨), *ចក្ខុវិស័យ & បេសកកម្ម*។ ដកស្រង់ខែ មេសា ០៣, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/kh/about/mission.jsp?MNCD=1020;

១៣. ផ្សារមូលបត្រកម្ពុជា (២០១៨), *រចនាសម្ព័ន្ធគ្រប់គ្រង* ។ ដកស្រង់ខែ មេសា ០៣, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/kh/about/org.jsp?MNCD=10302;

១៤. ផ្សារមូលបត្រកម្ពុជា (២០១៨), *វគ្គជួញដូរនៅ ផ.ម.ក.* ។ ដកស្រង់ខែ មេសា ០៤, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/kh/about/trading.jsp?MNCD=1050;

១៥. ផ្សារមូលបត្រកម្ពុជា (២០១៨), *សមាជិក* ។ ដកស្រង់ខែ មេសា ០៤, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/kh/member/members.jsp?MNCD=10511;

១៦. ផ្សារមូលបត្រកម្ពុជា (២០១៨), *ទិដ្ឋភាពទូទៅនៃការជួញដូរ* ។ ដកស្រង់ខែ មេសា ០៥, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/operation/market/listPosts.do?MNCD=30201;

១៧. ផ្សារមូលបត្រកម្ពុជា (២០១៨), *ការជួញដូរភាគហ៊ុន* ។ ដកស្រង់ខែ មេសា ០៥, ២០១៨ ពីគេហទំព័រ: http://www.csx.com.kh/operation/stock/listPosts.do?MNCD=30202;

១៨. Stockcharts (2018), *Fundamental Analysis*. Retrieved April 07, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:overview:fundamental_analysis;

១៩. Investopedia (2018), *Fundamental Analysis*. Retrieved April 07, 2018 from website: https://www.investopedia.com/terms/f/fundamentalanalysis.asp;

២០. Investopedia (2018), *Porter's 5 Forces*. Retrieved April 07, 2018 from website: https://www.investopedia.com/terms/p/porter.asp;

២១. Inc. (2018), *Industrial Analysis*. Retrieved April 07, 2018 from website: https://www.inc.com/encyclopedia/industry-analysis.html;

២២. Inc. (2018), *Industry Life Cycle*. Retrieved April 11, 2018 from website: https://www.inc.com/encyclopedia/industry-life-cycle.html;

២៣. Investopedia (2018), *Understanding the Income Statement*. Retrieved April 13, 2018 from website: https://www.investopedia.com/articles/04/022504.asp;

២៤. Investopedia (2018), *Understanding the Income Statement*. Retrieved April 13, 2018 from website: https://www.investopedia.com/articles/04/022504.asp;

២៥. Investopedia (2018), *Reading the Balance Sheet*. Retrieved April 13, 2018 from website: https://www.investopedia.com/articles/04/031004.asp;

២៦. Investopedia (2018), *5 Tips For Reading A Balance Sheet*. Retrieved April 13, 2018 from website: https://www.investopedia.com/slide-show/reading-the-balance-sheet/;

២៧. Investopedia (2018), *Cash flow statement: Analyzing cash flow from financing activities*. RetrievedApril13, 2018 from website: https://www.investopedia.com/articles/investing/120613/cash-flow-statement-analyzing-cash-flow-financing-activities.asp;

២៨. Investopedia (2018), *Analyze Investments Quickly With Ratios*. Retrieved April 15, 2018 from website: https://www.investopedia.com/articles/stocks/06/ratios.asp;

២៩. Investorguide (2018), *List of Important Financial Ratios for Stock Analysis*. Retrieved April 15, 2018 from website: http://www.investorguide.com/article/13690/list-of-important-financial-ratios-for-stock-analysis/;

៣០. Investopedia (2018), *Price-Earnings Ratio - P/E Ratio*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/p/price-earningsratio.asp;

៣១. Investopedia (2018), *Price/Earnings To Growth - PEG Ratio*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/p/pegratio.asp;

៣២. Investopedia (2018), *Price-To-Sales Ratio - PSR*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/p/price-to-salesratio.asp;

៣៣. Forbes (2018), *How To Use Price-To-Sales Ratios To Value Stocks*. Retrieved April 15, 2018 from website: https://www.forbes.com/sites/investopedia/2010/11/24/how-to-use-price-to- sales-ratios-to-value-stocks/#350988116e2e;

៣៤. Thebalance (2018), *Understanding Dividend Yield*. Retrieved April 15, 2018 from website: https://www.thebalance.com/understanding-dividend-yield-3140782;

៣៥. Investopedia (2018), *Dividend Yield*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/d/dividendyield.asp;

៣៦. Investopedia (2018), *Book Value*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/b/bookvalue.asp;

៣៧. Myaccountingcourse (2018), *Return on Equity (ROE) Ratio*. Retrieved April 15, 2018 from website: https://www.myaccountingcourse.com/financial-ratios/return-on-equity;

៣៨. Investopedia (2018), *Return on Equity (ROE)*. Retrieved April 15, 2018 from website: https://www.investopedia.com/terms/r/returnonequity.asp;

៣៩. Stockcharts (2018), *Technical Analysis*. Retrieved April 19, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:overview:technical_analysis;

៤០. Stockcharts (2018), *Trend Lines*. Retrieved April 19, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:trend_lines;

៤១. Investopedia (2018), *Line Chart*. Retrieved April 19 2018 from website: https://www.investopedia.com/terms/l/linechart.asp;

៤២. Investopedia (2018), *Bar Chart*. Retrieved April 19 2018 from website: https://www.investopedia.com/terms/b/barchart.asp;

៤៣. Stockcharts (2018), *Introduction to Candlesticks*. Retrieved April 21, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:introduction_to_candlesticks;

៤៤. Investopedia (2018), *Candlestick Charting: What Is It?*. Retrieved April 21 2018 from website: https://www.investopedia.com/trading/candlestick-charting-what-is-it/;

៤៥. Stockcharts (2018), *Chart Patterns*. Retrieved April 23, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns;

៤៦. Stockcharts (2018), *Head and Shoulders Top (Reversal)*. Retrieved April 23, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns:head_and_shoulders_top_reversal;

៤៧. Investopedia (2018), *Head And Shoulders Pattern.* Retrieved April 23 2018 from website: https://www.investopedia.com/terms/h/head-shoulders.asp;

៤៨. Stockcharts (2018), *Double Top Reversal.* Retrieved April 26, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns :double_top_reversal;

៤៩. Stockcharts (2018), *Double Bottom Reversal.* Retrieved April 26, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_ patterns:double_bottom_reversal;

៥០. Stockcharts (2018), *Triple Top Reversal.* Retrieved April 27, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns triple_top_reversal;

៥១. Stockcharts (2018), *Triple Bottom Reversal.* Retrieved April 27, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns triple_bottom_reversal;

៥២. Stockcharts (2018), *Falling Wedge (Reversal).* Retrieved April 30, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns: falling_wedge_reversal;

៥៣. Stockcharts (2018), *Rising Wedge (Reversal).* Retrieved April 30, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns: rising_wedge_reversal;

៥៤. Stockcharts (2018), *Flag, Pennant (Continuation).* Retrieved April 30, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:chart_analysis:chart_patterns:

flag_pennant_continuation;

៥៥. Stockcharts (2018), *Moving Averages - Simple and Exponential.* Retrieved May 04, 2018

from website: http://stockcharts.com/school/doku.php?id=chart_school:technical_indicators:

moving_ averages;

៥៦. Stockcharts (2018), *MACD (Moving Average Convergence/Divergence Oscillator).*

Retrieved May 07, 2018 from http://stockcharts.com/school/doku.php website:?id=chart_school:

technical _indicators:moving_average_convergence_divergence_macd;

៥៧. Stockcharts (2018), *On Balance Volume (OBV).* Retrieved May 09, 2018 from website: http://stockcharts.com/school/doku.php?id=chart_school:technical_indicators:on_

balance_volume_obv;

៥៨. Investopedia (2018), *On-Balance Volume (OBV).* Retrieved May 09, 2018 from website: https://www.investopedia.com/terms/o/onbalancevolume.asp;

៥៩. Stockcharts (2018), *Relative Strength Index (RSI).* Retrieved May 12, 2018 from website:

http://stockcharts.com/school/doku.php?id=chart_school:technical_indicators:relative_

strength_index_rsi;

៦០. Investopedia (2018), *Relative Strength Index – RSI.* Retrieved May 12, 2018 from website:

https://www.investopedia.com/terms/r/rsi.asp;

໒໑. Stockcharts (2018), *Bollinger Bands.* Retrieved May 15, 2018 from website:

http://stockcharts.com/school/doku.php?id=chart_school:technical_indicators:bollinger_bands;

໒໒. Investopedia (2018), *Stock Risks.* Retrieved May 17, 2018 from website:

https://www.investopedia.com/exam-guide/series-65/portfolio-risks-returns/stock-risks.asp;

໒໓. Thebalance (2018), The Major Types of Risk for Stock Investors. May 18, 2018 from website:

https://www.thebalance.com/major-types-of-risk-for-stock-investors-3141315;

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១

## ច្បាប់

## ស្ដីពី

## ការបោះផ្សាយ និង ការជួញដូរមូលបត្រមហាជន

# ព្រះរាជក្រម

នស/រកម/១០០៧/០២៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភានីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្ដីពី

# ការបោះផ្សាយ

# និង

# ការជួញដូរមូលបត្រមហាជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
3/43

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

ច្បាប់នេះមានគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬ ផ្តល់សេវាកម្មហិរញ្ញវត្ថុ ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ ។ ច្បាប់នេះរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬ អ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុ សម្រាប់ការវិនិយោគ ។

**មាត្រា ២.- គោលបំណង**

ច្បាប់នេះមានគោលបំណង :

១-បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ ។

២-លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។

៣-ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ។

៤-ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



4/43

**មាត្រា ៣.- វិសាលភាព**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងច្បាប់នេះ ត្រូវបានកំណត់ដោយសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២

## គណៈកម្មការមូលបត្រកម្ពុជា

**មាត្រា ៥.- អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា**

គណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដែលមានប្រធាន ១(មួយ)រូប និងសមាជិកចំនួន ៨(ប្រាំបី)រូប ដែលតែងតាំងដោយអនុក្រឹត្យ ។ សមាជិករបស់**គ.ម.ក.** មានអាណត្តិ ៥(ប្រាំ)ឆ្នាំ ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬ ផ្លាស់ប្តូរភារកិច្ច ។ សមាជិក**គ.ម.ក.** អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន តាមសំណើរបស់ប្រធាន**គ.ម.ក.** នៅពេលផុតអាណត្តិ ។

**មាត្រា ៦.- សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា**

ប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សមាសភាពរបស់**គ.ម.ក.** មាន :

១- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ (មួយ)រូប

២- តំណាងធនាគារជាតិនៃកម្ពុជា ០១ (មួយ)រូប

៣- តំណាងក្រសួងពាណិជ្ជកម្ម ០១ (មួយ)រូប

៤- តំណាងក្រសួងយុត្តិធម៌ ០១ (មួយ)រូប

៥- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ (មួយ)រូប

៦- អគ្គនាយក **គ.ម.ក.** ០១ (មួយ)រូប

៧- អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ០២ (ពីរ)រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បេក្ខភាពរបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ត្រូវជ្រើសរើស និងស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជូនប្រមុខរាជរដ្ឋាភិបាល ។ សមាជិកនៃ **គ.ម.ក.** ដែលជាអ្នកជំនាញ ត្រូវមានសញ្ញាបត្រថ្នាក់ក្រោយឧត្តមសិក្សា មានសមត្ថភាព និងលក្ខណៈ-សម្បត្តិគ្រប់គ្រាន់ និងសមស្របក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនព្រមទាំងមានបទពិសោធន៍មួយ ឬ ច្រើនផ្នែក ដូចជាពាណិជ្ជកម្ម គ្រប់គ្រងក្រុមហ៊ុនទីផ្សារមូលបត្រ ច្បាប់ សេដ្ឋកិច្ច គណ-នេយ្យ និងផ្នែកផ្សេងទៀតតាមតម្រូវការជាក់ស្តែង ។

## មាត្រា ៧._ មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ ។

២-ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ។

៣-កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ។

៤-កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ ។

៥-លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ ។

៦-ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង



6/43

នីតិបុគ្គលមានអាជ្ញាប័ណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ ។

៧-ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៨-បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ ។

**មាត្រា ៨.- មុខងាររបស់អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា**

អគ្គនាយកនៃ **គ.ម.ក.** មានមុខងារដូចខាងក្រោម :

១-គ្រប់គ្រងបុគ្គលិក និងមន្ត្រីជំនាញដែលទទួលបន្ទុកសម្របសម្រួលកិច្ចការរដ្ឋបាលរបស់**គ.ម.ក.** ក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-រាយការណ៍ និងផ្តល់អនុសាសន៍ជូនប្រធាន និងសមាជិកទាំងអស់នៃ **គ.ម.ក.** នូវរាល់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអភិវឌ្ឍ និង ការត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងការលើកសំណើសុំធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។

៣-ពិនិត្យសំណុំឯកសារ ដែលស្នើសុំធ្វើសំណើលក់មូលបត្រជាសាធារណៈនិងផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ។

៤-ពិនិត្យឯកសារផ្តល់ព័ត៌មាន ដែលទាក់ទងនឹងសំណើដាក់លក់មូលបត្រមហាជនដែលដាក់មក **គ.ម.ក.** ដើម្បីធានានូវការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ និងបញ្ញត្តិនានានៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដោយផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារដែលបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ ។

៥-ត្រួតពិនិត្យឯកសារផ្តល់ព័ត៌មានជាប្រចាំ ដែលផ្តល់ជូនទីផ្សារមូលបត្រនូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ឧបសម្ព័ន្ធទី ២

## អនុក្រឹត្យថ្មី

## ស្ដីពី

## ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០១.អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះ-ផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលដៅ**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ។

**មាត្រា ២.- គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.- វិសាលភាព**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ ÷

១. ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។

២. អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន ។

## ជំពូកទី ២
## សកម្មភាព និងលក្ខខណ្ឌ នៃការលើកទឹកចិត្តពន្ធដារ

### មាត្រា ៤.- ការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារ តាមរយៈ គ.ម.ក. ដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ សម្រាប់រយៈពេល ៣ (បី) ឆ្នាំ ។

រយៈពេលនៃការលើកទឹកចិត្ត ៣ (បី) ឆ្នាំខាងលើនេះ ត្រូវគិតចាប់ផ្តើមពី ÷

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ ។

### មាត្រា ៥.- ការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញចំពោះក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធលើប្រាក់ចំណេញទាំងស្រុងក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានចំពោះ÷

១- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញដោយស្នងការសវនកម្មឯករាជ្យ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មពេញលេញ (បានបិទបញ្ជី និងចេញលិខិតបញ្ជាក់សារពើពន្ធសម្រាប់កាលបរិច្ឆេទ N-1, N-2 និង N-3) ។

២- បំណុលពន្ធលើប្រាក់ចំណេញដែលរកឃើញពីកម្មវត្ថុនៃការធ្វើសវនកម្មឡើងវិញ ដោយអគ្គនាយកដ្ឋានពន្ធដារ ក្រោយពេលដែលអគ្គនាយកដ្ឋានពន្ធដារនេះបានធ្វើសវនកម្មពេញលេញ ពោលគឺនៅមុនពេលដែលក្រុមហ៊ុន/សហគ្រាស ធ្វើការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ក្នុងរយៈពេល ៧ (ប្រាំពីរ) ឆ្នាំថយក្រោយ រាប់បន្ទាប់ពីឆ្នាំ N-3 ដែលបានធ្វើសវនកម្មដោយស្នងការសវនកម្មឯករាជ្យ ។ ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/សហគ្រាសធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

ការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះបំណុលពន្ធប្រយោលដែលជាបន្ទុករបស់អ្នកប្រើប្រាស់មានជាអាទិ៍ដូចជា អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធកាត់ទុកជាដើម ។

**មាត្រា ៦.- ការលើកទឹកចិត្តពន្ធកាត់ទុកដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយ លើការប្រាក់ និង/ឬភាគលាភ ដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬភាគលាភ ត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុក ជូនរដ្ឋបាលសារពើពន្ធ ទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ (ដប់ប្រាំ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក ។

**មាត្រា ៧.- ក្រុមហ៊ុន/សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ**

ក្រុមហ៊ុន/សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងមាត្រា ៤ និងមាត្រា ៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨.- ការបញ្ឈប់ការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ គ.ម.ក. ដើម្បីបញ្ឈប់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ ។ លិខិតប្រកាសពន្ធសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមាន តារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣ (បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ ។
- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ ។
- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ គ.ម.ក. អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្ត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/ សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជីជួញដូរមូលបត្រ ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៩.- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/សហគ្រាសបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលជាសាធារណៈរួច**

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី គ.ម.ក. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និង/ ឬមូលបត្របំណុលជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារ ដូចមានចែងក្នុងមាត្រា ៤ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ដោយគិតចាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុន/ សហគ្រាសបានបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ។

**មាត្រា ១០.- ការជំនួស**

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យមូលបត្រ ។

**មាត្រា ១១.- ការអនុវត្ត**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៥.

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ១១ "ដើម្បីអនុវត្ត"
- គ្រប់ក្រសួង-ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៣

## ប្រកាស

## ស្តីពី

## ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខៈ ០១៧/១៧.......គ.ម.ក. /ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ, ប្រកាសលេខ ០០១/១៣ គ.ម.ក.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រកាសលេខ ០០៥/១៤ គ.ម.ក.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងប្រការ១ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ............ខែ.......ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦... ខែ....... ឆ្នាំ២០១៧..

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ០០៣៣/១៣
ចុះថ្ងៃទី២៦... ខែ.វិច្ឆិកា... ឆ្នាំ២០១៣

## ស្តីពី
## វិធានប្រតិបត្តិការទីផ្សារមូលបត្រ
## របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

វិធាននេះមានគោលបំណងកំណត់ពីវិធីសាស្ត្រ យន្តការ នីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) ស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

- **សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ របស់ **ផ.ម.ក.** និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ **ផ.ម.ក.**។

- **បញ្ជា** សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃជួញដូរ** សំដៅដល់ថ្ងៃដែលទទួលបានពីការផ្គូផ្គងបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃចុងក្រោយ** សំដៅដល់ថ្ងៃជួញដូរចុងក្រោយ ឬថ្ងៃមូលដ្ឋាន ករណីគ្មានថ្ងៃជួញដូរនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃមូលដ្ឋាន** សំដៅដល់ថ្លៃគោលសម្រាប់គណនាដែនកំណត់ថ្លៃក្នុងការជួញដូរមូលបត្រប្រចាំថ្ងៃ។

- **ថ្លៃដុល** (Dirty Price) សំដៅដល់ថ្លៃនៃមូលបត្របំណុល ដែលគិតបញ្ចូលនូវការប្រាក់បង្គរ (Accrued Interest)។

- **ថ្លៃបើក** សំដៅដល់ថ្លៃជួញដូរដំបូងនៃមូលបត្រនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃបិទ** សំដៅដល់ថ្លៃដែលត្រូវបានកំណត់នៅពេលបិទទីផ្សារនៅថ្ងៃជួញដូរនីមួយៗ ដូចខាងក្រោម÷

១-ថ្លៃជួញដូរចុងក្រោយ ឬ

២-ថ្លៃពិសេស ឬ

៣-ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ក្នុងករណីគ្មានការជួញដូររហូតដល់ពេលបិទទីផ្សារ និងគ្មានថ្លៃពិសេស នៅថ្ងៃជួញដូរលើកដំបូង ឬ

៤-ថ្លៃមូលដ្ឋាន ក្នុងករណីគ្មានការជួញដូររហូតដល់ម៉ោងបិទទីផ្សារ និងគ្មានថ្លៃពិសេស។

- **ថ្លៃពិសេស** សំដៅដល់ថ្លៃដូចខាងក្រោម ក្នុងករណីមូលបត្រកម្មសិទ្ធិមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទទីផ្សារ÷

១-ថ្លៃល្អបំផុតនៃសំណើលក់ (Best Ask) ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង ឬ

២-ថ្លៃល្អបំផុតនៃសំណើទិញ (Best Bid) ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង។

- **ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង** (IPO Price) សំដៅដល់ថ្លៃមូលបត្រកម្មសិទ្ធិដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរនៅ គ.ម.ក.។

- **មូលបត្រចុះបញ្ជីលក់លើកដំបូង** (Initially Listed Securities) សំដៅដល់មូលបត្រដែលត្រូវបានចុះបញ្ជីសម្រាប់ជួញដូរជាផ្លូវការនៅ ផ.ម.ក. បន្ទាប់ពីត្រូវបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង។

- **ថ្លៃរំពឹងទុក** (Expected Price) សំដៅដល់ថ្លៃជួញដូររំពឹងទុកដែលទទួលបានពីការផ្គូផ្គងបញ្ជាជាបន្តបន្ទាប់នៅក្នុងអំឡុងវគ្គបើក និងវគ្គបិទ ដោយប្រើវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ។

- **បរិមាណរំពឹងទុក** (Expected Volume) សំដៅដល់បរិមាណមូលបត្រដែលអាចផ្គូផ្គងបានដោយឈរលើមូលដ្ឋាននៃថ្លៃរំពឹងទុក។

- **ប្រតិបត្តិការគណនីអតិថិជន** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្របន្ទាប់ពីបានទទួលការបញ្ជាពីអតិថិជន។

41

- **ប្រតិបត្តិការគណនីសមាជិក** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្រសម្រាប់គណនីផ្ទាល់របស់សមាជិក។

- **ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.** សំដៅដល់ប្រព័ន្ធកុំព្យូទ័រ ដែលប្រតិបត្តិដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. ក្នុងគោលបំណងធ្វើជាអន្តរការីនៃការជួញដូរមូលបត្រ។

- **ប្រព័ន្ធកុំព្យូទ័រសមាជិក** សំដៅដល់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិក ដែលត្រូវបានអនុញ្ញាតឱ្យបញ្ជូនបញ្ជាទៅកាន់ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.។

- **ការជួញដូរមិនប្រក្រតី** សំដៅដល់ការជួញដូរទាំងឡាយដែលក្នុងនោះថ្លៃ ឬបរិមាណនៃការជួញដូរមូលបត្រមានការប្រែប្រួលខុសប្រក្រតីនៅក្នុងទីផ្សារ។

- **ការជួញដូរមិនស្មោះត្រង់** សំដៅដល់ការជួញដូរដែលធ្វើឱ្យថ្លៃទីផ្សារមានការប្រែប្រួលដោយមធ្យោបាយមិនស្មោះត្រង់ដូចជា÷ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ការប្រើឧបាយកលក្នុងទីផ្សារ ឬការប្រើប្រាស់ព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

- **ការឃ្លាំមើលទីផ្សារ** (Market Watch) សំដៅដល់ការតាមដានសភាពការណ៍ទីផ្សារ តាមរយៈការវិភាគអំពីប្រតិបត្តិការជួញដូរមូលបត្រនៅលើទីផ្សារ ស្ថានភាពនៃបញ្ជា និងព័ត៌មាននានាដែលពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ពាក្យចចាមអារ៉ាម និងព័ត៌មានដែលទទួលបានពីប្រភពផ្សេងទៀត ជាដើម។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលរាល់បញ្ជាទិញនិងបញ្ជាលក់ទាំងអស់ ត្រូវផ្គូផ្គងព្រមគ្នានិងជួញដូរនៅថ្លៃតែមួយ។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលបញ្ជាទិញឬបញ្ជាលក់មួយត្រូវបានផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗគ្នា។

## **ប្រការ ៣.- មូលបត្រដែលអាចជួញដូរបាន**

មូលបត្រដែលចុះបញ្ជីលក់នៅ **ផ.ម.ក.** ត្រូវជួញដូរនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដោយគោរពតាមវិធាននេះ។

ការជួញដូរមូលបត្រក្នុងចំណោមសមាជិក ត្រូវបានធ្វើអន្តរការីកម្មដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក.។

## **ប្រការ ៤.- ប្រភេទនៃបញ្ជា**

ផ.ម.ក. អនុញ្ញាតឱ្យមានប្រភេទបញ្ជាដូចខាងក្រោម÷

41

១- បញ្ជាដែនកំណត់ (Limit Order) ÷ ជាបញ្ជាដែលមានថ្លៃជាក់លាក់មួយ ដើម្បីទិញឬលក់មូលបត្រ នៅថ្លៃជាក់លាក់នោះ ឬនៅថ្លៃប្រសើរជាងថ្លៃជាក់លាក់នោះ។ ថ្លៃប្រសើរជាងថ្លៃជាក់លាក់ គឺជាថ្លៃទាបជាងថ្លៃជាក់លាក់នោះក្នុងករណីទិញ ឬជាថ្លៃខ្ពស់ជាងថ្លៃជាក់លាក់នោះក្នុងករណីលក់។

២- បញ្ជាទីផ្សារ (Market Order) ÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ ដោយគោរពតាមប្រការ ១០, ១១ និង១២។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។ នៅក្នុងវគ្គនិរន្តរ៍ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌណាមួយ ដូចខាងក្រោម÷

ក- លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល (Fill or Kill) ÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។

ខ- លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill) ÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងឬមួយផ្នែកភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចោលភ្លាម។

៣- បញ្ជាតាមការចរចា (Negotiated Order) ÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

## ប្រការ ៥.- សុពលភាពនៃបញ្ជា

រាល់បញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តការជួញដូរនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ សុពលភាពនៃបញ្ជានៃមូលបត្រណាមួយត្រូវបានព្យួរក្នុងករណីដែលការជួញដូរមូលបត្រនោះត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

## ប្រការ ៦.- ការកែប្រែ ឬលុបបញ្ជាដែលបានបញ្ចូល

ប្រសិនបើបញ្ជាមិនទាន់ត្រូវបានអនុវត្តការជួញដូរ សមាជិកអាច÷

១- កែប្រែឬលុប ថ្លៃឬបរិមាណនៃបញ្ជាដែនកំណត់។

២- លុបបញ្ជាទីផ្សារ និងបញ្ជាតាមការចរចា។

## ប្រការ ៧.- នីតិវិធីនៃការដាក់បញ្ជា

ក្នុងករណីដែលសមាជិកមួយដាក់បញ្ជាទៅប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. សមាជិកនោះត្រូវអនុវត្តនីតិវិធីដូចខាងក្រោម÷

១-ពិនិត្យមើលសាច់ប្រាក់ ឬមូលបត្រដែលអតិថិជនមាន ដើម្បីធានាការទូទាត់ ឬការជួញដូរដែលពាក់ព័ន្ធនឹងបញ្ជានោះ។

២-ពិនិត្យព័ត៌មានលម្អិតនៃបញ្ជាដូចមានចែងក្នុងប្រការ ៨ ។

៣-ដាក់បញ្ជាចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក.។

## ប្រការ ៨.- ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. ត្រូវមានព័ត៌មានលម្អិត ដូចខាងក្រោម÷

១-ឈ្មោះមូលបត្រ។

២-បរិមាណ។

៣-ថ្លៃ ករណីក្រៅពីបញ្ជាទីផ្សារ។

៤-លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា។

៥-ការបញ្ជាក់ពីបញ្ជា÷ បញ្ជាទិញ ឬបញ្ជាលក់។

៦-ប្រភេទនៃប្រតិបត្តិការ÷ ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក។

៧-លេខអត្តសញ្ញាណសមាជិក។

៨-លេខអត្តសញ្ញាណវិនិយោគិន។

៩-លេខបញ្ជា។

១០-លេខគណនីជួញដូរ។

១១-ក្នុងករណីលុបឬកែប្រែបញ្ជា ត្រូវបញ្ជាក់ថាជាការលុបឬជាការកែប្រែ ហើយត្រូវបញ្ជាក់លេខបញ្ជាដើមផងដែរ។

១២-លេខកូដវិនិយោគិន÷ ជារូបវន្តបុគ្គល ឬនីតិបុគ្គល។

១៣-លេខកូដប្រទេសរបស់វិនិយោគិន។

## ប្រការ ៩.- វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រ ដូចខាងក្រោម÷

១-វិធីសាស្ត្រដេញថ្លៃ (Auction Trading Method)។

២-វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

**ប្រការ ១០.- វិធីសាស្ត្រដេញថ្លៃ**

វិធីសាស្ត្រដេញថ្លៃ (Auction Trading Method) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាទិញនិងបញ្ជាលក់ ដោយស្វ័យប្រវត្តិ តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction) ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

អាទិភាពនៃបញ្ជាតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម÷

១-បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២-ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុន មានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ទោះបីជាមានចែងក្នុងកថាខណ្ឌទី២នៃប្រការនេះក៏ដោយ អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវបានកំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា÷

១-ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម÷

ក-រាល់បញ្ជាទិញដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងលើ (ថ្លៃមូលដ្ឋាន +១០%)។

ខ-រាល់បញ្ជាលក់ដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងក្រោម (ថ្លៃមូលដ្ឋាន -១០%)។

២-ចំពោះបញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី១ នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះ បញ្ជាដែលមានបរិមាណច្រើនជាងមានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណីបញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល ផ.ម.ក. ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

៣-ការបែងចែកបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី២ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចខាងក្រោម÷

ក-១០០ (មួយរយ) ដង នៃឯកតាជួញដូរ។

ខ-៥០០ (ប្រាំរយ) ដង នៃឯកតាជួញដូរ។

គ-១០០០ (មួយពាន់) ដង នៃឯកតាជួញដូរ។

# ឧបសម្ព័ន្ធទី ៤

## ប្រកាស

## ស្តីពី

## ការដាក់ឲ្យអនុវត្តវិធានសមាជិកភាព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:........០០៣/១១...គ.ម.ក ប្រ.ក.

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យអនុវត្តវិធានសមាជិកភាព

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/ ០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធាន ប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានសមាជិកភាព របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានសមាជិកភាព របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី **០៣** ខែ **តុលា** ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ .០០៣/១១ គ.ម.ក. ប្រ.ក.
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានសមាជិកភាព
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះគឺដើម្បីកំណត់អំពីគោលការណ៍នានា ដែលចាំបាច់សម្រាប់ការគ្រប់គ្រងសមាជិកភាព និងការចូលរួមទាំងអស់នៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ដែលរួមទាំងការកំណត់គុណវុឌ្ឍិនៃសមាជិកភាព និងការចូលរួម ការផ្តល់ និងការដកសមាជិកភាពនិងការចូលរួម និងការកំណត់សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួម ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

- **សមាជិកនិងអ្នកចូលរួម** សំដៅដល់សមាជិក ឬអ្នកចូលរួមទាំងឡាយណាដែលត្រូវអនុញ្ញាតឱ្យប្រើប្រាស់សេវារបស់ **ផ.ម.ក.** ទាំងស្រុង ឬមួយផ្នែក ស្របតាមប្រភេទសមាជិក ឬអ្នកចូលរួម។

- **សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**)ហើយជាសមាជិករបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្ររបស់ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធ ឬសេវារបស់ **ផ.ម.ក.**។

## ជំពូកទី ២

## ការចូលជាសមាជិក ឬអ្នកចូលរួម

### ប្រការ ៣.- នីតិវិធីដើម្បីចូលជាសមាជិក ឬអ្នកចូលរួម

បុគ្គលដែលទទួលបានអាជ្ញាបណ្ណ ឬបុគ្គលដែលទទួលបានការទទួលស្គាល់ចាំបាច់ ពី **គ.ម.ក.** ដែលមានបំណងចូលជាសមាជិក ឬជាអ្នកចូលរួមនៃ **ផ.ម.ក.** ត្រូវបំពេញបែបបទដើម្បីចូលជាសមាជិកឬអ្នកចូលរួមរបស់ **ផ.ម.ក.** ហើយត្រូវបញ្ជាក់ពីភាពមានគុណវុឌ្ឍិគ្រប់គ្រាន់ដូចមានកំណត់នៅក្នុងវិធាននេះ។

### ប្រការ ៤.- លក្ខខណ្ឌគុណវុឌ្ឍិ

លក្ខខណ្ឌគុណវុឌ្ឍិមានដូចខាងក្រោម :

១-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានឧបករណ៍និងប្រព័ន្ធព័ត៌មានវិទ្យាដែលអាចភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.**។

២-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាដែលតភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.** ស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ៥.- ថ្លៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួម

បុគ្គលដាក់ពាក្យស្នើសុំចូលជាសមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតដូចខាងក្រោម :

១-សមាជិកត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់សមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

២-អ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតជា ÷

ក-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល។

ខ-ភ្នាក់ងារបញ្ជិកាមូលបត្រចំនួន ២.០០០.០០០ (ពីរលាន)រៀល។

គ-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រចំនួន ២.០០០.០០០ (ពីរលាន) រៀល។

ឃ- ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសម្រាប់ការអនុញ្ញាតធ្វើជាអ្នកចូលរួម។

## ជំពូកទី ៣
## ការដកហូតសមាជិកភាព ឬការចូលរួម

### ប្រការ ៦.- ការដកសមាជិកភាព ឬការចូលរួម ដោយស្ម័គ្រចិត្ត

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយមានបំណងស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួន បុគ្គលនោះត្រូវដាក់សំណើសុំដកសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

ការដកសមាជិកភាព ឬការចូលរួម ព្រមទាំងកាលបរិច្ឆេទសុពលភាពនៃការដកសមាជិកភាពឬការចូលរួមត្រូវសម្រេចដោយ **ផ.ម.ក.**។

### ប្រការ ៧.- ការដកហូតសមាជិកភាព ឬការចូលរួម

**ផ.ម.ក.** នឹងចាត់នីតិវិធីដកសមាជិកភាព ឬបញ្ឈប់ការចូលរួមពីសមាជិក ឬអ្នកចូលរួម ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម÷

១- ការដកហូតអាជ្ញាប័ណ្ណ ឬការទទួលស្គាល់ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬការផ្ទេរអាជីវកម្ម ឬការបិទអាជីវកម្ម។

២- ការរំលាយក្រុមហ៊ុន។

៣- ការដកហូតសមាជិកភាព ឬការបញ្ឈប់ការចូលរួម។

### ប្រការ ៨.- ការផ្ទេរសមាជិកភាព ឬការចូលរួម

បុគ្គលដែលមានបំណងផ្ទេរសមាជិកភាព ឬការចូលរួមដែលជាលទ្ធផលនៃការផ្ទេរអាជីវកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាដើម ត្រូវដាក់ពាក្យស្នើសុំផ្ទេរសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

សមាជិកភាព ឬការចូលរួមដែលត្រូវបានផ្ទេរស្របតាមកថាខណ្ឌទី ១ អាចត្រូវបានប្រគល់ឱ្យក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី ដោយមានការយល់ព្រមពី **ផ.ម.ក.**។

ក្នុងករណីដែលមានការផ្ទេរសមាជិកភាពស្របតាមកថាខណ្ឌទី ១ រាល់ការជួញដូរមូលបត្រទាំងឡាយដែលមិនបានទូទាត់របស់សមាជិកនោះ ត្រូវចាត់ទុកថាជាការជួញដូរដោយក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី។

### ប្រការ ៩.- ការបញ្ចប់ និងការផ្តល់សមាជិកភាព ឬការចូលរួមជាថ្មី

សមាជិកភាព ឬការចូលរួមត្រូវមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលសមាជិក-

ភាពឬការចូលរួមត្រូវបានសម្រេចដោយ **ផ.ម.ក.**។ សមាជិកភាព ឬការចូលរួមដែលត្រូវបានបន្តថ្មីនឹងមានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលសុពលភាពចាស់ផុតកំណត់។

សមាជិក ឬអ្នកចូលរួមដែលមានបំណងបន្តសមាជិកភាពរបស់ខ្លួន ត្រូវបំពេញបែបបទដើម្បីបន្តសុពលភាពយ៉ាងហោចណាស់ ៤៥ (សែសិបប្រាំ) ថ្ងៃ មុនថ្ងៃដែលសុពលភាពផុតកំណត់។

លក្ខខណ្ឌតម្រូវនានានៃការស្នើសុំបន្តសមាជិកភាព ឬការចូលរួម ត្រូវដូចគ្នានឹងលក្ខខណ្ឌតម្រូវនៃការស្នើសុំសមាជិកភាព ឬការចូលរួមលើកដំបូង ដែលមានចែងក្នុងប្រការ ៣ ខាងលើ។

ការស្នើសុំបន្តសមាជិកភាព ឬការចូលរួមស្របតាមកថាខណ្ឌទី ២ និងទី ៣ ខាងលើ ត្រូវសម្រេចដោយ **ផ.ម.ក.** និងត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកឬអ្នកចូលរួម ស្របតាមប្រការ ៥ នៃវិធាននេះ។

សេចក្តីសម្រេចផ្តល់ការអនុញ្ញាតបន្តធ្វើជាសមាជិក ឬជាអ្នកចូលរួម ត្រូវផ្តល់ដោយ **ផ.ម.ក.** បន្ទាប់ពីសមាជិក ឬអ្នកចូលរួម បានបំពេញបែបបទបន្តត្រឹមត្រូវ និងបានបង់ថ្លៃសេវាផ្សេងៗដូចមានចែងក្នុងវិធាននេះ។

**ប្រការ ១០.- ការព្យួរការជួញដូរ និងការទូទាត់លើការជួញដូរដែលមិនទាន់ទូទាត់**

ចំពោះបុគ្គលដែលបានដាក់ពាក្យស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួនស្របតាមប្រការ ៦ ខាងលើ ឬក៏សមាជិកភាព ឬការចូលរួមរបស់ខ្លួនត្រូវបានដកហូតស្របតាមប្រការ ៧ ខាងលើ សមាជិក ឬអ្នកចូលរួមនោះ ត្រូវបានព្យួរការប្រើប្រាស់សេវារបស់ **ផ.ម.ក.** ចាប់ពីថ្ងៃដែលការដកហូតសមាជិកភាពឬការចូលរួមត្រូវបានសម្រេចជាផ្លូវការដោយ **ផ.ម.ក.**។

## ជំពូកទី ៤

## សិទ្ធិ និងភារកិច្ចរបស់សមាជិកនិងអ្នកចូលរួម

**ប្រការ ១១.- សិទ្ធិរបស់សមាជិក និងអ្នកចូលរួម**

សមាជិកនិងអ្នកចូលរួមមានសិទ្ធិប្រើប្រាស់សេវារបស់ **ផ.ម.ក.** សម្រាប់ការជួញដូរមូលបត្រ ការជាត់ទាត់និងទូទាត់មូលបត្រ និងការរក្សាទុកមូលបត្រ ស្របតាមការសម្រេចរបស់ **ផ.ម.ក.** ពាក់ព័ន្ធនឹងការបែងចែករវាងសមាជិកនិងអ្នកចូលរួម និងពាក់ព័ន្ធនឹងវិធានការវិន័យដូចមានចែងក្នុងវិធានរបស់ **ផ.ម.ក.** ដែលទទួលបានការអនុម័តដោយ **គ.ម.ក.**។

**ប្រការ ១២.- ការបង់ថ្លៃសេវា**

សមាជិក ឬអ្នកចូលរួម ដែលទទួលបានការអនុញ្ញាតពី **ផ.ម.ក.** ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំដូចខាងក្រោម :

១-សមាជិកត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ដល់ **ជ.ម.ក.** នៅមុនដំណាច់ឆ្នាំនីមួយៗ។

២-សម្រាប់អ្នកចូលរួមជា ៖

ក-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ខ-ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ២.០០០.០០០ (ពីរលាន) រៀល។

គ-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០(បួនលាន) រៀល។

ឃ-អ្នកចូលរួមជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសេវាប្រចាំឆ្នាំ។

សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាតដំបូង សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំ នៅពេលដែលទទួលបានការអនុញ្ញាតដោយគណនាផ្អែកលើចំនួនថ្ងៃដែលនៅសល់ រហូតដល់ចុងឆ្នាំសារ-ពើពន្ធ។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ សមាជិកឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំនេះ ឱ្យបានមុនថ្ងៃទី ១៥ ខែ ធ្នូ នៃឆ្នាំសារពើពន្ធចាស់។

**ប្រការ ១៣.- ការទូទាត់លើការជួញដូរមូលបត្រ**

សមាជិក ត្រូវមានកាតព្វកិច្ចទូទាត់លើរាល់ប្រតិបត្តិការមូលបត្រដែលខ្លួនបានអនុវត្ត នៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.**។

សមាជិក ត្រូវបានហាមឃាត់មិនឱ្យធ្វើការអនុញ្ញាតឱ្យភាគីទី ៣ ធ្វើការទូទាត់លើប្រតិបត្តិការមូល-បត្រក្នុងនាមរបស់ខ្លួនឡើយ។

**ប្រការ ១៤.- ការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានា**

សមាជិក និងអ្នកចូលរួមទាំងអស់ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីអាជីវកម្មមូលបត្រ ព្រមទាំងវិធានរបស់ **ផ.ម.ក.** ដែលរួមទាំងវិធានប្រតិបត្តិការទីផ្សារមូលបត្រ វិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ វិធានប្រតិបត្តិការរក្សាទុកមូលបត្រ ព្រមទាំងចំណាត់ការ ឬវិធានការផ្នែកវិន័យដែលត្រូវបានអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិនានា។

**ប្រការ ១៥.- កិច្ចព្រមព្រៀងផ្តល់សេវា**

នៅពេលបើកគណនី សមាជិកនិងអ្នកចូលរួម ត្រូវចុះកិច្ចព្រមព្រៀងផ្តល់សេវាជាមួយ **ផ.ម.ក.** តាមគំរូដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

សមាជិក និងអ្នកចូលរួមត្រូវផ្ដល់ជូន **ផ.ម.ក.** នូវគំរូនៃកិច្ចព្រមព្រៀងសេវារវាងសមាជិក ឬអ្នកចូល-រួម និងអតិថិជនរបស់ខ្លួន ដែលបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធរបស់ **គ.ម.ក.**។

## ជំពូកទី ៥
## ការត្រួតពិនិត្យសមាជិក និងអ្នកចូលរួម

### ប្រការ ១៦.- របាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ

សមាជិកត្រូវផ្ដល់ជូន **ផ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច ព្រមទាំងព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។ អ្នកចូលរួមត្រូវផ្ដល់ជូន **ផ.ម.ក.** នូវរបាយការណ៍ និងព័ត៌មានដែលកំណត់ដោយ **គ.ម.ក.**។

### ប្រការ ១៧.- សំណើសុំផ្ដល់ព័ត៌មាន

**ផ.ម.ក.** អាចស្នើឱ្យសមាជិក និងអ្នកចូលរួមផ្ដល់នូវព័ត៌មានពាក់ព័ន្ធក្នុងករណីដូចខាងក្រោម :

១-ករណីដែលមានភាពចាំបាច់ក្នុងការបញ្ជាក់ឱ្យដឹងច្បាស់ថា សមាជិក និងអ្នកចូលរួមពិតជាបានអនុវត្តត្រឹមត្រូវតាមការណែនាំនៃវិធាននេះ ឬតាមកាតព្វកិច្ចរបស់ខ្លួន។

២-ករណីដែលមានភាពចាំបាច់ សម្រាប់ការគ្រប់គ្រងដំណើរការទីផ្សារប្រកបដោយរបៀបរៀប-រយ។

### ប្រការ ១៨.- វិធានការវិន័យចំពោះសមាជិក និងអ្នកចូលរួម

ចំពោះសមាជិកនិងអ្នកចូលរួម ដែលមិនអនុវត្តតាមវិធានទាំងឡាយរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **ផ.ម.ក.** អាចចាត់វិធានការវិន័យក្នុងចំណោមវិធានការដូចខាងក្រោម :

១-ការព្រមាន។

២-ការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុង ឬផ្នែកណាមួយ ដែលអាចមានក្នុងរយៈពេលកំណត់ណាមួយ។

៣-ការបញ្ឈប់ពីសមាជិកភាព ឬពីការចូលរួមនៃ **ផ.ម.ក.**។

### ប្រការ ១៩.- ការជូនដំណឹងអំពីការចាត់វិធានការ

នៅពេលដែលវិធានការដូចជាការបញ្ឈប់ ឬការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុងឬមួយផ្នែក ឬការព្យួរសិទ្ធិជួញដូរទាំងស្រុង ឬមួយផ្នែក ត្រូវបានអនុវត្តចំពោះសមាជិក ឬអ្នកចូលរួមណាមួយ ឬនៅពេល

ដែលវិធានការដែលបានអនុវត្តត្រូវបានបញ្ចប់ **ផ.ម.ក.** ត្រូវផ្តល់ដំណឹងអំពីការណ៍នេះភ្លាមដល់សមាជិក និង អ្នកចូលរួមដទៃទៀត។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

### ប្រការ ២០.- សុពលភាពនៃសមាជិកភាព ឬការចូលរួមលើកទីមួយ

សម្រាប់ការចូលជាសមាជិក ឬជាអ្នកចូលរួមលើកទីមួយ សមាជិកភាព ឬការចូលរួមត្រូវមានសុពល-ភាពស្មើនឹងសុពលភាពនៅមាននៃអាជ្ញាបណ្ណ ឬការទទួលស្គាល់ ដែលចេញដោយ **គ.ម.ក.** ហើយថ្លៃនៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួមនេះត្រូវគិតជាប្រូរ៉ាតា (Pro Rata)។

*****

# ឧបសម្ព័ន្ធទី ៥

## ប្រកាស

## ស្តីពី

## ការប្រមូលពន្ធប្រថាប់ត្រា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៧៣........សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធប្រថាប់ត្រា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតពន្ធប្រថាប់ត្រា
- បានឃើញព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត
- សេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ
- លិខិតលេខ ១៣៤ សជណ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការដោះស្រាយក្នុងការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី
- លិខិតលេខ ១៩៧ សជណ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំគោលការណ៍បន្ថែមលើការអនុវត្តប្រមូលពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្សញាតិរវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់បែបបទ និងនីតិវិធីប្រមូលពន្ធប្រថាប់ត្រារបស់រដ្ឋបាលសារពើពន្ធ ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ សេចក្តីសម្រេចលេខ ០៤ សសរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៦ និងសេចក្តីសម្រេចលេខ ២២ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលពន្ធ និងបង់ចូលក្នុងគណនីទោលនៃរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

**ប្រការ ២.-**

ផ្អែកតាមជំពូកទី៣ ផ្នែកទី១ ដែលចែងពីបទប្បញ្ញត្តិមួយចំនួនស្តីពីពន្ធប្រថាប់ត្រា នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ ÷

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុន បញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

**ប្រការ ៣.-**

ពន្ធប្រថាប់ត្រាត្រូវប្រមូលពី ÷

- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬមធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុន
- អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត។

**ប្រការ ៤.-**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១. ពាក្យ "**ញាតិ**" សំដៅដល់ ÷
   - រវាងឪពុកម្តាយបង្កើត និងកូនបង្កើត
   - រវាងប្តី និងប្រពន្ធ
   - រវាងយាយតាបង្កើត និងចៅបង្កើត
   - រវាងបងប្អូនបង្កើត និងបងប្អូនបង្កើត
   - រវាងឪពុកម្តាយក្មេក និងកូនប្រសារ។

២. ពាក្យ "**តម្លៃចុះកិច្ចសន្យា**" សំដៅដល់តម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

៣. ពាក្យ "**តម្លៃភាគហ៊ុន**" សំដៅដល់តម្លៃនៃការផ្ទេរភាគហ៊ុន ផ្អែកតាមតម្លៃទីផ្សារ។

៤. ពាក្យ "**ថវិការដ្ឋ**" សំដៅដល់ថវិកាជាតិ ឬថវិកាថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងមាតិកាថវិកាប្រចាំឆ្នាំនីមួយៗ។

៥. ពាក្យ "**ទំនិញ ឬសេវា**" សំដៅដល់ទំនិញ សំណង់ ឬសេវា។

៦. ពាក្យ "**ប្រទានកម្ម**" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៧. ពាក្យ "**ប្រធានសក្តិ**" សំដៅដល់បាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គីភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៨. ពាក្យ "**ភាគហ៊ុន**" សំដៅដល់ចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមអាជីវកម្ម និងសហគ្រាសឯកបុគ្គល ដែលបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។

៩. ពាក្យ "**មធ្យោបាយដឹកជញ្ជូនឬយានយន្ត**" សំដៅដល់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដូចជា រថយន្ត ទូក កាណូត កប៉ាល់ សាឡង់ ។ល។

១០. ពាក្យ "**លិខិតមានលក្ខណៈគតិយុត្ត**" សំដៅដល់លិខិតមានលក្ខណៈគតិយុត្តស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។

១១. ពាក្យ "**សន្តតិកម្ម**" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ តាមរយៈ ÷

- បណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬ
- បញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ
- សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់។

១២. ពាក្យ "**អចលនទ្រព្យ**" សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី ឬមិនបានចុះបញ្ជី ដោយរដ្ឋបាលសុរិយោដី។

**ប្រការ ៥.-**

**ក. ការលើកលែងពន្ធ**

ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងដូចខាងក្រោម ÷

១. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ពីដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬ/និងធ្វើកសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ។

២. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ក្នុងរង្វង់ញាតិ ÷

- ការធ្វើសន្តតិកម្ម រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើត និងចៅបង្កើត
- ការធ្វើប្រទានកម្ម រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើត និងចៅបង្កើត សម្រាប់តែការផ្ទេរលើកទីមួយប៉ុណ្ណោះ។

៣. ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

ការផ្ទេរ និងការលើកលែងប្រាក់ពន្ធប្រថាប់ត្រាចំពោះកថាខណ្ឌ២ និងកថាខណ្ឌ៣ នៃប្រការនេះ មិនមានអនុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួច និងការផ្ទេរមុនការចេញប្រកាសនេះទេ។

៤. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ដែលត្រូវកត់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននានា នៃព្រះរាជាណាចក្រកម្ពុជា។

៥. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្តរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

៦. ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ។ ដោយឡែក ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្តដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការនិងដឹកជញ្ជូន មិនត្រូវបានលើកលែងពន្ធប្រថាប់ត្រានេះទេ។

៧. អ្នកវិនិយោគមូលបត្រដែលទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាមរយៈការជួញដូរមូលបត្រក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់។

ការផ្ទេរភាគហ៊ុន ការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ដូចជា ការបំបែកភាគហ៊ុន (Share split) របស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុងវិស័យមូលបត្រ ទោះបីតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះត្រូវមានលិខិតបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា។

ករណីក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបាន ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុននេះត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុនកន្លងមក ដោយអនុលោមតាមប្រកាសនេះ លើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីគណៈកម្មការមូលបត្រកម្ពុជា ដោយផ្អែកលើមូលហេតុសមស្រប ដូចជា ករណីប្រធានសក្តិជាដើម។

**ខ. ការអនុគ្រោះពន្ធ**

ពន្ធប្រថាប់ត្រាត្រូវបានអនុគ្រោះ ដូចខាងក្រោម ÷

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត និងរវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ២០០ ០០០ ០០០ (ពីររយលាន) រៀល ចំពោះការធ្វើសន្តតិកម្ម និង ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះការធ្វើប្រទានកម្ម
- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដដែល ជាប្រទានកម្មក្នុងរង្វង់ញាតិ រវាងឪពុក-ម្តាយបង្កើតនិងកូនបង្កើត រវាងប្តីនិងប្រពន្ធ និងរវាងយាយ-តាបង្កើតនិងចៅបង្កើត ចាប់ពីលើកទី២តទៅ ត្រូវបានអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធប្រថាប់ត្រា ១០០ ០០០ ០០០ (មួយរយលាន) រៀល។

ការលើកលែង ឬការអនុគ្រោះពន្ធប្រថាប់ត្រាក្នុងរង្វង់ញាតិខាងលើ ត្រូវមានឯកសារជាភស្តុតាងបញ្ជាក់ទំនាក់ទំនងអំពីញាតិ ដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង/ឬឯកសារដទៃទៀត ដែលអាចបញ្ជាក់ទំនាក់ទំនងរវាងបុគ្គលមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៤ នៃប្រកាសនេះ។

ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ឬការអនុគ្រោះពន្ធ មានប្រាក់ពន្ធស្មើ ០ (សូន្យ) រៀល ក៏ត្រូវអនុវត្តតាមនីតិវិធី និងបែបបទនៅរដ្ឋបាលសារពើពន្ធជាធរមាន ដើម្បីចុះបញ្ជី និងកត់ត្រាទិន្នន័យនូវរាល់ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះ។ ដោយឡែក ចំពោះការលើកលែងពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ មិនតម្រូវឱ្យយកឯកសារមកបំពេញនីតិវិធីនៅរដ្ឋបាលសារពើពន្ធនោះទេ។

**ប្រការ ៦.-**

អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រា មានដូចខាងក្រោម ÷

១. ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។

២. ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្ត ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ។

៣. ០,១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

៤. ០,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ។

៥. ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ប្រភេទគឺ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន និងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា (រួមទាំងលិខិតរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ ដូចមានចែងក្នុងកថាខណ្ឌនេះ)។

**ប្រការ ៧.-**

តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ ដូចខាងក្រោម ÷

១. អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់តម្លៃអចលនទ្រព្យ និងតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្តសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២. ភាគហ៊ុន ត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុននោះកើតឡើង។

៣. កិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា។

៤. លិខិតមានលក្ខណៈគតិយុត្ត ត្រូវកំណត់ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

**ប្រការ ៨.-**

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រថាប់ត្រា ឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣ខែ ÷

១. ចំពោះអចលនទ្រព្យដែលបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ) បន្ទាប់ពីការសម្រេចនៃកំណត់បង្ហាញរបស់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងអចលនទ្រព្យដែលមិនទាន់ចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) បន្ទាប់ពីមានការបញ្ជាក់ពីមេឃុំ ចៅសង្កាត់ អភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

២. ចំពោះមធ្យោបាយដឹកជញ្ជូនឬយានយន្ត បន្ទាប់ពីថ្ងៃចុះហត្ថលេខារបស់អ្នកទទួលសិទ្ធិលើសំណុំឯកសារ "ពាក្យសុំផ្ទេរកម្មសិទ្ធិយានយន្ត" របស់មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ។

៣. ចំពោះភាគហ៊ុន បន្ទាប់ពីប្រតិបត្តិការផ្ទេរភាគហ៊ុនកើតឡើង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរភាគហ៊ុន។

៤. ចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងកិច្ចសន្យានេះ។

៥. ចំពោះលិខិតមានលក្ខណៈគតិយុត្ត បន្ទាប់ពីការសម្រេចរបស់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងលិខិតនេះ។

ចំពោះការផ្ទេរ ឬប្រតិបត្តិការទិញ លក់ ដូចខាងក្រោម ពុំចាំបាច់យកមកប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធនោះទេ ÷

- ការផ្ទេរ ឬការទទួលសិទ្ធិកាន់កាប់ភាគហ៊ុនពាក់ព័ន្ធនឹងវិស័យមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌ ៧ នៃប្រការ ៥ នៃប្រកាសនេះ
- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃប្រការ ៥ នៃប្រកាសនេះ
- ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ ដូចមានចែងក្នុងកថាខណ្ឌ ៦ នៃប្រការ ៥ នៃប្រកាសនេះ។

**ប្រការ ៩.-**

១. អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកទទួលសិទ្ធិលើភាគហ៊ុន និងអ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្តអនុលោមតាមប្រកាសនេះ ដែលមិនបានបង់ពន្ធប្រថាប់ត្រាទាន់ពេលវេលាកំណត់ដូចមានចែងក្នុងប្រការ ៨ ត្រូវពិន័យស្មើនឹងចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់។

២. ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ថ្មីនោះ មិនបានបង់ពន្ធប្រថាប់ត្រាតាមច្បាប់នោះទេ ÷

- រដ្ឋបាលសុរិយោដី មិនអាចចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យថ្មីនោះទេ
- អាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឬក្រុង ស្រុក ខណ្ឌ) មិនអាចមានសិទ្ធិផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនបានបង់ពន្ធប្រថាប់ត្រា ឬបង់ពន្ធប្រថាប់ត្រាក្រៅប្រព័ន្ធពន្ធដារនោះបានទេ ទោះជាអចលនទ្រព្យនោះបានចុះបញ្ជី ឬមិនបានចុះបញ្ជីក្តី ហើយត្រូវជំរុញនិងបញ្ជូនរាល់ករណីស្នើសុំផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យទាំងនោះឱ្យមកបង់ពន្ធប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធតាមច្បាប់ជាធរមាន
- ចំពោះការផ្ទេរកម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូន សម្រាប់រថយន្តគ្រប់ប្រភេទ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងលើស១៥០សេះ ស្ថាប័នសាធារណការ និងដឹកជញ្ជូន មិនអាចមានសិទ្ធិចេញប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូនឬយានយន្តថ្មីនោះដោយមិនបានបង់ពន្ធប្រថាប់ត្រានោះទេ លើកលែងតែការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

**ប្រការ ១០.-**

ប្រកាសលេខ ៧៣៥ សហវ.ប្រក.អពជ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធប្រថាប់ត្រា ត្រូវទុកជានិរាករណ៍។

**ប្រការ ១១.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ